សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

Université Royale de Droit et des Sciences Économiques

Royal University of Law and Economic

## សារណាបញ្ចប់ការសិក្សា

# ការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅ ព្រះរាជាណាចក្រកម្ពុជា

ស្រាវជ្រាវចាប់ពីថ្ងៃទី ០៨ ខែមេសា ឆ្នាំ២០២៤ ដល់ ថ្ងៃទី ១០ ខែសីហា ឆ្នាំ២០២៤


ស្រាវជ្រាវដោយ

និស្សិតឈ្មោះ **លោក អៀម ប៊ុនថន**

**លោក ស៊ុន ម៉េងអ៊ី**

ណែនាំដោយ

សាស្ត្រាចារ្យជំនួយ **សុខ ចិន្តា**


ថ្នាក់បរិញ្ញាបត្រ **នីតិសាស្ត្រ**

ជំនាន់ទី ២៤

ឆ្នាំចូលសិក្សា ២០២០

ឆ្នាំសរសេរសារណា ២០២៤

# សេចក្តីថ្លែងអំណរគុណ

ខ្ញុំបាទឈ្មោះ **អៀម ម៉ុនថន** និង ខ្ញុំបាទឈ្មោះ **ស៊ុន ម៉េងអ៊ី** ជានិស្សិត ថ្នាក់បរិញ្ញាបត្រ ផ្នែកនីតិសាស្ត្រ ឆ្នាំទី៤ ជំនាន់ទី២៤ ឆ្នាំសិក្សា ២០២០-២០២៤ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច។

**យើងខ្ញុំសូមសម្តែងនូវការគោរពដ៏ខ្ពង់ខ្ពស់ និងគោរពនូវការដឹងគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះ ៖**

| | | | |
|---|---|---|---|
| លោកឪពុក | **ឥន្ទ សោភ័ណ** | លោកឪពុក | **ស៊ុន ម៉ុនធី** |
| អ្នកម្តាយ | **ញ៉ែម សុខា** | អ្នកម្តាយ | **រ៉ុន ណារ៉េត** |

ដែលលោកទាំងពីរ បានផ្តល់កំណើតដល់កូន ខិតខំប្រឹងប្រែងយកចិត្តទុកដាក់ចំពោះកូនទាំងកម្លាំងកាយចិត្ត ចិញ្ចឹមបីបាច់ថែរក្សា ទូន្មានប្រៀនប្រដៅ ផ្តល់ដំបូន្មានល្អៗ ការលើកទឹកចិត្តគាំទ្រកូនតាំងពីពេលកូននៅជាកុមារភាពរហូតលុះកូនធំពេញវ័យដោយមិនគិតពីការនឿយហត់ ទោះបីមានឧបសគ្គយ៉ាងណាក៏ដោយ ក៏នៅតែខិតខំពុះពារដោយមិនរារែកដើម្បីកូន និងឧបត្ថម្ភដល់ការសិក្សា រៀនសូត្រតាំងពីថ្នាក់មត្តេយ្យ រហូតដល់ថ្នាក់បរិញ្ញាបត្រដើម្បីឲ្យកូនមានអនាគតភ្លឺស្វាង និងអភិវឌ្ឍខ្លួនក្លាយជាកូនល្អ សិស្សល្អ ពលរដ្ឋល្អ នៅក្នុងសង្គមជាតិនឹងប្រកបដោយភាពជោគជ័យមកទល់នឹងបច្ចុប្បន្ននេះ។

យើងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ **សាស្ត្រាចារ្យជំនួយ សុខ ចិន្តា** ដែលជាសាស្ត្រាចារ្យណែនាំក្នុងការសរសេរសារណាបញ្ចប់ការសិក្សារបស់រូបខ្ញុំទាំងពីរនាក់ អ្នកគ្រូបានចំណាយពេលវេលាយ៉ាងមានតម្លៃក្នុងកាផ្តល់នូវដំបូន្មាន គំនិត ចំណេះដឹង ការលើកទឹកចិត្ត មតិយោបល់ល្អៗ បង្ហាញផ្លូវក្នុងការកែសម្រួល នូវកំហុសខុសឆ្គងចំពោះការសរសេរសារណារបស់យើងខ្ញុំកន្លងមក ចាប់តាំងពីថ្ងៃដែលយើងខ្ញុំទាំងពីរនាក់ផ្តើមសរសេរ រហូត ដល់ទទួលបានស្នាដៃមួយនេះជោគជ័យជាស្ថាពរ ប្រសិនបើគ្មានវត្តមានអ្នកគ្រូសាស្ត្រាចារ្យ **សុខ ចិន្តា** រូបខ្ញុំទាំងពីរនាក់ក៏មិនអាចសម្រេចបាននូវស្នាដៃមួយនេះដែរ។ គុណទាំងនេះ គឺពិតជាមានតម្លៃវិសេសវិសាលឥតកាត់ថ្លៃបានឡើយ ចំពោះរូបខ្ញុំទាំងពីរនាក់។

ជាអវសានកថា យើងខ្ញុំទាំងពីរនាក់មានតែលើកដៃទាំងទ្វេសូមប្រសិទ្ធិពរជ័យ សិរីមង្គល បួងសួងដល់ទេវតា ដែលតាមថែរក្សាព្រះរាជាណាចក្រកម្ពុជាទាំងឡាយ សូមជួយថែរក្សាលោកអ្នកមានគុណទាំងទ្វេ ថ្នាក់ដឹកនាំសាកលវិទ្យាល័យ សាស្ត្រាណែនាំ លោកគ្រូ អ្នកគ្រូ និង មិត្តភក្តិទាំងអស់ មានសុខភាពរឹងមាំ ប្រាជ្ញាវាងវៃ គ្រប់ពេលវេលាសូមឲ្យសុខសប្បាយ សុខទាំងកាយ សុខទាំងចិត្ត ជាពិសេសសូមឲ្យជួបប្រទះនូវពុទ្ធពរទាំងបួនប្រការគឺ **អាយុ វណ្ណៈ សុខៈ** និង**ពលៈ** កុំបីឃ្លៀងឃ្លាតឡើយ ។

# អារម្ភកថា

សារណានេះសរសេរតាក់តែងឡើង នៅក្នុងឱកាសបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្រ្ត ហើយក៏ដើម្បីវាស់ស្ទង់នូវសមត្ថភាព និងកម្រិតចំណេះដឹង ដែលបានមកពីការខិតខំប្រឹងប្រែង និងការសិក្សា កន្លងមកអស់រយៈពេល ៤ ឆ្នាំ នៅ **សាកលវិទ្យាល័យភូមិន្ទនីតិសាស្រ្ត និងវិទ្យាសាស្រ្តសេដ្ឋកិច្ច**។ ដូច្នេះយើងខ្ញុំបានសម្រេចចិត្តជ្រើសរើសប្រធានបទមួយដែលទាក់ទងនឹង **ការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា** យកមកសិក្សាស្រាវជ្រាវ។ សារណាដែលបានសរសេរតាក់តែងឡើងមកនេះ គឺទុកជាស្នាដៃថ្មីមួយរបស់យើងខ្ញុំទុកជាគុណប្រយោជន៍ដល់សិស្សនិស្សិតដែលជាសិស្សប្អូនជំនាន់ក្រោយសម្រាប់ការសិក្សាស្រាវជ្រាវពង្រីកចំណេះដឹងក្នុងការរៀនសូត្របន្ថែម ។

ប្រទេសកម្ពុជាយើង គឺជាប្រទេសមួយក្នុងចំណោមប្រទេសដទៃទៀតដែលធ្លាប់មានសង្រ្គាមកើតឡើងដែលនាំឱ្យមនុស្សស្លាប់រាប់លាននាក់ បាត់បង់សេដ្ឋកិច្ចនិងខូចខាតហេដ្ឋារចនាសម្ព័ន្ធស្ទើរតែទាំងអស់។ ក្រោយពីប្រទេសកម្ពុជាបានទទួលនូវសន្តិភាពពេញលេញរួចមក ការអភិវឌ្ឍន៍នានាក៏ចាប់ផ្តើមមានសន្ទុះ ឡើងមកវិញជាលំដាប់។ ក្នុងនោះ ការផ្តល់សម្បទានដីសេដ្ឋកិច្ច ពិតជាបានរួមចំណែកក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ក្នុងគោលបំណង និងគោលដៅបម្រើផលប្រយោជន៍សេដ្ឋកិច្ច និងផលប្រយោជន៍ជាតិឲ្យកាន់តែរីកចម្រើន។ ស្របពេលដែលមានការផ្តល់សម្បទានដីសេដ្ឋកិច្ច នេះកាន់តែច្រើនឡើងនៅក្នុងដំណើរអភិវឌ្ឍន៍សង្គមកម្ពុជា បែរជាប្រជាពលរដ្ឋកម្ពុជាផ្ទាល់ និងសិស្សនិស្សិតមួយចំនួន ពុំទាន់បានយល់ច្បាស់ពីការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះនៅឡើយ ក៏ព្រោះតែការផ្តល់សម្បទានដីសេដ្ឋកិច្ច នេះមិនមានការផ្សព្វផ្សាយទូលំទូលាយ ដែលជួនកាលបង្កើតឲ្យមាន ការយល់ច្រលំថាការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះ ទន្រ្ទានលើដីប្រជាពលរដ្ឋ ឬដីព្រៃ។

ក្នុងការសម្រេចចិត្តជ្រើសរើសប្រធានបទនេះមកសរសេរសារណា យើងខ្ញុំខិតខំស្វែងរកប្រភពឯកសារដែលពាក់ព័ន្ធនានា និងបានពិភាក្សាជាមួយសាស្រ្តាចារ្យ សិស្សច្បងដោយបំណងគឺចង់ដឹងអំពីលក្ខណៈពិសេសក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដំណើរការនីតិវិធីផ្តល់សម្បទានដីសេដ្ឋកិច្ច និងបញ្ហាជាច្រើនទៀតក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចសម្រាប់ពង្រីកចំណេះដឹង ស្វែងយល់បន្ថែមទាក់ទងនឹងប្រធានបទនេះ ។

តែយ៉ាងណាក៏ដោយការស្រាវជ្រាវលើប្រធានបទនេះគឺនៅមានចំណុចខ្វះចន្លោះទាំងពាក្យពេចន៍ និងអត្ថន័យ ខ្លឹមសារ អាស្រ័យហេតុនេះសូម លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ សិស្សនិស្សិត និងមិត្តអ្នកអានទាំងអស់ មេត្តាខន្តី អភ័យទោសដល់ការស្រាវជ្រាវរបស់យើងខ្ញុំទាំងពីរនាក់ផង ហើយយើងទាំងពីរនាក់មានភាពរីករាយយ៉ាងខ្លាំងក្នុងការទទួលយកនូវការរិះគន់ក្នុងន័យស្ថាបនាពីសំណាក់ លោកគ្រូ អ្នកគ្រូ សាស្រ្តាចារ្យ សិស្ស និស្សិត និងមិត្ត អ្នកអានទាំងអស់ ដើម្បីរួមចំណែកក្នុងការកែលម្អកិច្ចការស្រាវជ្រាវមួយនេះឲ្យមានភាពល្អប្រសើរ ។

# មាតិកា

**ទំព័រ**

**សេចក្តីផ្តើម** ........ ១

១.លំនាំបញ្ហានៃការស្រាវជ្រាវ ........ ១

២.ចំណោទបញ្ហានៃការស្រាវជ្រាវ ........ ១

៣.គោលបំណងនៃការស្រាវជ្រាវ ........ ២

៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ........ ២

៥.សារៈសំខាន់នៃការស្រាវជ្រាវ ........ ៣

៦.វិធីសាស្រ្តនៃការស្រាវជ្រាវ ........ ៣

៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ........ ៣

**ជំពូកទី១**

**សញ្ញាណទូទៅនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច**

**១.១.និយមន័យ** ........ ៥

១.១.១. អត្ថន័យនៃសម្បទានដីសេដ្ឋកិច្ច ........ ៦

១.១.២.កម្មវត្ថុនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច ........ ៧

**១.២.គោលការណ៍នៃការផ្តល់សម្បទានដីសេដ្ឋកិច្ច** ........ ៨

១.២.១.លក្ខណៈវិនិច្ឆ័យលើប្រភេទដី ........ ៨

១.២.២.លក្ខណៈសម្បត្តិរបស់សម្បទានិក ........ ១០

១.២.៣.លក្ខណៈវិនិច្ឆ័យលើសំណើសម្បទានដីសេដ្ឋកិច្ច ........ ១១

១.២.៤.រយៈពេលនៃទំហំដីការផ្តល់សម្បទានដីសេដ្ឋកិច្ច ........ ១១

**ជំពូកទី២**

**នីតិវិធីការផ្តល់សម្បទានដីសេដ្ឋកិច្ច**

**២.១.គម្រោងសម្បទានដីសេដ្ឋកិច្ច** ........ ១៣

២.១.១.ការផ្តួចផ្តើមគម្រោងដោយអាជ្ញាធរមានសមត្ថកិច្ច ........ ១៣

២.១.២. ការផ្តួចផ្តើមគម្រោងដោយអ្នកវិនិយោគ ..... ១៥

**២.២.សមត្ថកិច្ចរដ្ឋបាលនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច ..... ១៧**

២.២.១.អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ..... ១៧

២.២.២.លេខាធិការដ្ឋានបច្ចេកទេស ..... ១៨

២.២.៣. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ..... ១៩

២.២.៤. ក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ខណ្ឌ ..... ២០

២.២.៥.ក្រុមប្រឹក្សាឃុំ សង្កាត់ ..... ២១

**២.៣.កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ..... ២២**

២.៣.១.ការបង្កើតកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ..... ២២

២.៣.២.លក្ខខណ្ឌនៃការកាន់កាប់សម្បទានដីសេដ្ឋកិច្ច ..... ២៦

**២.៤.ការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ..... ២៨**

២.៤.១.សិទ្ធិជាកាតព្វកិច្ចសម្បទាននិក ..... ២៩

២.៤.២.អនុភាពបុព្វសិទ្ធិរបស់រដ្ឋ ..... ៣១

**២.៥.ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ..... ៣២**

២.៥.១.ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចមុនការកំណត់ ..... ៣២

២.៥.២.ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចតាមការកំណត់ ..... ៣៣

**២.៦.លទ្ធផលនៃសម្បទានដីសេដ្ឋកិច្ច ..... ៣៣**

២.៦.១.គុណសម្បត្តិសម្បទានដីសេដ្ឋកិច្ច ..... ៣៤

២.៦.២.គុណវិបត្តិសម្បទានដីសេដ្ឋកិច្ច ..... ៣៦

**ជំពូកទី៣**

**ផលប៉ះពាល់នៃការផ្តល់សម្បទានដីសេដ្ឋកិច្ច**

**៣.១.ផលប៉ះពាល់ ..... ៣៩**

៣.១.១.ផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ ..... ៣៩

៣.១.២.ផលប៉ះពាល់ជាមួយជនជាតិដើមភាគតិច ..... ៤៣

៣.១.៣.ផលប៉ះពាល់ជាមួយបរិស្ថានធម្មជាតិ........................................................................ ៤៥

**៣.២.ដំណោះស្រាយបញ្ហាវិវាទសម្បទានដីសេដ្ឋកិច្ច** ................................................ ៤៥

៣.២.២.យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ................................................................ ៤៥

៣.២.៣.យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ ................................................................ ៤៩

**សេចក្តីសន្និដ្ឋាន**........................................................................................................... ៥១

**អនុសាសន៍** ................................................................................................................... ៥៣

**ឯកសារយោង**

**ឧបសម្ព័ន្ធ**

# បញ្ជីតារាង

តារាង៖ សម្បទានដីសេដ្ឋកិច្ចដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ តាំងពីឆ្នាំ១៩៩៦ ដល់ ២០១២, ទំព័រ ៣៤

# សេចក្តីផ្តើម

## ១.លំនាំបញ្ហានៃការស្រាវជ្រាវ

ប្រទេសកម្ពុជា ធ្លាប់បានឆ្លងកាត់នូវសង្គ្រាមជូរចត់ជាច្រើនទសវត្សមកហើយ ដែលបានកើតឡើងចាប់តាំងពីឆ្នាំ១៩៧៥រហូតដល់ឆ្នាំ១៩៩១។ សង្គ្រាមបានបំផ្លាញស្ទើរតែទាំងស្រុងនូវហេដ្ឋារចនាសម្ព័ន្ធ និងឯកសារនានាដែលបញ្ជាក់ពីសិទ្ធិលើកម្មសិទ្ធិ ជាពិសេសបញ្ហាសេដ្ឋកិច្ចនិងការគ្រប់គ្រងខាងដីធ្លី ។ រហូតមកទល់ឆ្នាំ ១៩៩៣ ប្រទេសកម្ពុជាក៏បានធ្វើការប្រកាសខ្លួនជាប្រទេសមួយដែល ប្រកាន់យកនូវរបបប្រជាធិបតេយ្យសេរីពហុបក្សជាលើកដំបូង។

រដ្ឋាភិបាលអាណត្តិទីមួយបានរៀបចំប្រទេសកម្ពុជាឡើងវិញ ប្រទេសជាតិចាប់ផ្តើមមានការអភិវឌ្ឍន៍ឥតឈប់ឈរ ដោយមានការវិនិយោគពីក្រុមហ៊ុន ក្នុងស្រុក និង ក្រុមហ៊ុនក្រៅស្រុក។ ដើម្បីជាកាតាលីករក្នុងការពន្លឿនសេដ្ឋកិច្ចបន្ថែម នាថ្ងៃទី៩ ខែកក្កដា ឆ្នាំ ២០០៥ រាជរដ្ឋាភិបាល បានចេញសារាចរណ៍ណែនាំ ស្តីពីការផ្តល់សម្បទានដីសេដ្ឋកិច្ច សម្រាប់វិនិយោគក្នុងទិសដៅជំរុញលើកទឹកចិត្តការអនុវត្តន៍គម្រោងវិនិយោគនានាពិសេសក្នុងវិស័យកសិកម្ម និង ឧស្សាហកម្មដែលត្រូវការចាំបាច់មិនអាចខ្វះបាននូវសម្បទានដីសេដ្ឋកិច្ច។ ក្រោយមកនៅថ្ងៃ ទី២៧ ខែ ធ្នូ ឆ្នាំ ២០០៥ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចដែលជាមូលដ្ឋានគតិយុត្ត។

ទន្ទឹមនឹងការអភិវឌ្ឍន៍នេះ ការផ្តល់សម្បទានដីសេដ្ឋកិច្ចត្រូវបានទទួលការរិះគន់ថាអនុវត្តមិន គោរពកិច្ចសន្យា និងបទប្បញ្ញត្តិផ្លូវច្បាប់ជាធរមាន។ សម្បទានបានក្លាយជាប្រភពនៃជម្លោះដីធ្លីជាច្រើនដូចជា ការទន្ទ្រានយកដី ការបណ្តេញចេញដោយបង្ខំ និងការធ្វើអាជីវកម្មធនធានធម្មជាតិ។[1] ក្នុងចំណុចវិជ្ជមាន និងចំណុចអវិជ្ជមាន ទាំងនេះហើយដែលធ្វើឲ្យមានការចាប់អារម្មណ៍ក្នុងការស្វែងយល់បន្ថែមដែលទាមទារឲ្យ មានការសិក្សាស្រាវជ្រាវមួយឲ្យបានច្បាស់លាស់។ ដូច្នេះហើយយើងទាំងពីរនាក់ក៏សម្រេចថានឹងធ្វើការសិក្សា ស្រាវជ្រាវអំពីប្រធានបទ "**ការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជា**" ដើម្បីធ្វើជាសារណាសម្រាប់ បញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រនីតិសាស្ត្រ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និង វិទ្យាសាស្ត្រសេដ្ឋកិច្ចនេះ។

## ២.ចំណោទបញ្ហានៃការស្រាវជ្រាវ

រាជរដ្ឋាភិបាលកម្ពុជាបានពង្រឹងសមត្ថភាពក្នុងការងារផែនការ តាមរយៈការរៀបចំផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ប្រទេស។ ក្នុងនោះការផ្តល់សម្បទានដីសេដ្ឋកិច្ច ក៏ជាជម្រើសមួយក្នុង ផែនការអភិវឌ្ឍន៍សេដ្ឋកិច្ច

[1] https://opendevelopmentcambodia.net/km/topics/concessions/ ចូលមើលថ្ងៃទី ៨ ខែមេសា ឆ្នាំ២០២៤

និងសង្គមកម្ពុជាផងដែរ។ ប៉ុន្តែបន្ទាប់មករាជរដ្ឋាភិបាលកម្ពុជាក៏បាន ផ្អាកការផ្តល់ដីសម្បទានថ្មីៗ និងឲ្យមានការពិនិត្យឡើងវិញលើដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់កាលពីឆ្នាំ២០១២។ នេះជាចំណោទបញ្ហាពាក់ព័ន្ធនឹងប្រធានបទដែលយើងខ្ញុំទាំងពីរនាក់បានលើកមកធ្វើការសរសេរសារណានេះផងដែរ។ ហើយក៏មានសំណួរគតិយុត្តមួយចំនួនបានលើកឡើងថា៖ តើការផ្តល់សម្បទានសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាមានលក្ខណៈដូចម្តេច? តើនីតិវិធីដំណើរការការផ្តល់សម្បទានសេដ្ឋកិច្ចទៅបានយ៉ាងដូចម្តេច? ដោយឡែកចំពោះផលប៉ះពាល់ដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ចពិសេសបញ្ហាធ្វើឲ្យមានការផ្អាកសម្បទានដីសេដ្ឋកិច្ចនៅឆ្នាំ ២០១២ តើមានដំណោះស្រាយ បែបណាខ្លះក្នុងការដោះស្រាយផលប៉ះពាល់ដែលកើតមានទាំងនោះ? ដែលចំណុចទាំងបីនេះ នឹងក្លាយជាចំណោទបញ្ហាក្នុងការស្រាវជ្រាវនេះ។

## ៣.គោលបំណងនៃការស្រាវជ្រាវ

គោលបំណងចម្បងក្នុងការស្រាវជ្រាវលើប្រធានបទមួយនេះ យើងខ្ញុំទាំងពីរនាក់មានគោលបំណងសំខាន់ៗចំនួនពីរដូចខាងក្រោម៖

ទីមួយ ដោយសារការផ្តល់សម្បទានដីសេដ្ឋកិច្ចតែងតែបង្កឲ្យមានបញ្ហាទំនាស់ដីធ្លី ហើយបញ្ហាទាំងនេះទៀតសោតក៏មិនអាចនឹងបញ្ចប់ក្នុងរយៈពេលខ្លីបានដែរ។ ប្រសិនបើបញ្ហានេះ នៅតែកើតមានជាបន្តបន្ទាប់ ហើយការដោះស្រាយពុំទទួលបានប្រសិទ្ធិភាពនោះទេ ពិតណាស់វានិងជះឥទ្ធិពលអវិជ្ជមានដល់ជីវភាពរស់នៅប្រចាំថ្ងៃរបស់ពលរដ្ឋ។ បញ្ហាបែបនេះអាចបង្កឲ្យមានភាពរាំងស្ទះដល់គម្រោងផែនការអភិវឌ្ឍន៍ក្នុងប្រទេសកម្ពុជា។ ដោយសារតែមើលឃើញពីបញ្ហាទាំងអស់នេះហើយ បានជាយើងខ្ញុំទាំងពីរនាក់សម្រេចជ្រើសរើសប្រធានបទមួយនេះ ដើម្បីយល់ដឹងកាន់តែច្បាស់ពីការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។ ហើយតាមរយៈការសិក្សាស្វែងយល់លំអិតនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។ ហើយតាមរយៈការសិក្សាស្វែងយល់ លំអិតនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជានេះ អាចធ្វើឲ្យយើងខ្ញុំទាំងពីរនាក់នឹងធ្វើការវិភាគរកដំណោះស្រាយ រួចចូលរួមក្នុងការផ្តល់ជាអនុសាសន៍ផងដែរ។

ទីពីរ ដោយសារតែប្រធានបទស្តីពីការការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជានេះ ពុំទាន់ឃើញ មានការស្រាវជ្រាវណាបានសិក្សាលំអិតនូវឡើយ។ ការសិក្សាស្រាវជ្រាវនេះ គឺដើម្បីជាជំនួយបន្ថែមសម្រាប់មិត្តៗនិស្សិត និងសិស្សប្អូនជំនាន់ក្រោយចង់ធ្វើការសិក្សាស្រាវជ្រាវបន្ថែមប្រៀបធៀបឲ្យកាន់តែងាយស្រួល និងធំទូលាយជាងនេះទៅទៀត។

## ៤.ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ

សារណាបញ្ចប់ការសិក្សានេះគ្របដណ្តប់លើការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ។ ការសិក្សានេះបាន ផ្អែកទៅលើនីតិវិធីដែលមានចែងក្នុងអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច ច្បាប់ភូមិបាល និង

ក្រមរដ្ឋប្បវេណីនៃកម្ពុជា និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធ។ ទន្ទឹមនឹងនេះដែនកំណត់សិក្សាគឺសិក្សាពីសញ្ញាណនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចរហូតដល់ដំណោះស្រាយនានា ពាក់ព័ន្ធនឹងបញ្ហាវិវាទដីធ្លីសម្បទានដីសេដ្ឋកិច្ចនេះ និងដោយស្របច្បាប់នៅកម្ពុជា។

## ៥.សារៈសំខាន់នៃការស្រាវជ្រាវ

តាមរយៈការសិក្សាលំអិតអំពីការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជានេះ ពិតជាមានសារៈសំខាន់ណាស់ចំពោះយើងខ្ញុំទាំងពីរនាក់ ដើម្បីជាផ្នែកមួយក្នុងការពង្រីកចំណេះដឹងដែលទាក់ទងនឹងប្រធានបទនេះហើយអាចធ្វើការវិភាគរកដំណោះស្រាយបញ្ហាមួយជាក់លាក់ រួចធ្វើការផ្តល់ជាអនុសាសន៍ ។

លើសពីនេះទៅទៀតសិស្សនិស្សិត អាចយល់ដឹងកាន់តែច្បាស់អំពីការផ្តល់សម្បទានដីសេដ្ឋកិច្ច នីតិវិធីនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច ។ ពិសេសប្រជាពលរដ្ឋគួរតែយល់ដឹង ចៀសវាងការកើតមានបញ្ហាដែលប៉ះពាល់ពេលមាន ការផ្តល់សម្បទានដីសេដ្ឋកិច្ចផងដែរ។ ជាពិសេសតាមរយៈការយល់ដឹងរបស់ប្រជាពលរដ្ឋអំពីការផ្តល់សម្បទានដីសេដ្ឋកិច្ច ក៏អាចជួយឲ្យការដោះស្រាយទំនាស់ដីធ្លី អាចបញ្ចប់ដោយមានប្រសិទ្ធិភាព និងចំណេញពេលវេលា។ ជាពិសេសប្រទេសយើងអាចកាត់បន្ថយវិវាទដែលកើតមាន ប្រាកដណាស់វាក៏ជាកត្តាមួយដែលជំរុញផែនការអភិវឌ្ឍន៍ប្រទេសកម្ពុជា ស្របតាមគោលនយោបាយរបស់រដ្ឋាភិបាលហើយឈានទៅរកការរីកចម្រើននិងភាពសម្បូរបែបជាមិនខាន។

## ៦.វិធីសាស្ត្រនៃការស្រាវជ្រាវ

ការសរសេរសារណាបញ្ចប់ការសិក្សាប្រធានបទនេះបានសម្រេចជាស្ថាពរបាន គឺយើងខ្ញុំទាំងពីរនាក់បានស្រាវជ្រាវឯកសារនៅបណ្ណាល័យដែលចងក្រងដោយសាស្ត្រាចារ្យ សិស្សនិស្សិត និងតាមប្រព័ន្ធអ៊ីនធឺណែត និងច្បាប់លិខិតបទដ្ឋានគតិយុត្តិដែលពាក់ព័ន្ធផ្សេងៗទៀត។ ជាពិសសនោះគឺមានការណែនាំពីសាស្ត្រាចារ្យជំនួយ សុខ ចិន្តា ដែលជាសាស្ត្រាចារ្យដឹកនាំការសរសេរ សារណានេះផ្ទាល់តែម្តងដែលបានទទួលការណែនាំ ជួយតម្រង់ទិសរហូតបានសម្រេចជាសមិទ្ធផល។

## ៧.រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

ក្នុងការបកស្រាយប្រធានបទសារណារនេះ យើងខ្ញុំទាំងពីរនាក់បានធ្វើការបែងចែកជាបីជំពូករួមមានដូចខាងក្រោម៖

សេចក្តីផ្តើម

ជំពូកទី១ សញ្ញាណទូទៅនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច

ជំពូកទី២ នីតិវិធីការផ្តល់សម្បទានដីសេដ្ឋកិច្ច

ជំពូកទី៣ ផលប៉ះពាល់នៃការផ្តល់សម្បទានដីសេដ្ឋកិច្ច

សេចក្តីសន្និដ្ឋាន

អនុសាសន៍

ឯកសារយោង

ឧបសម្ព័ន្ធ។

ចំពោះខ្លឹមសារ ដែលទាក់ទងទៅនឹងចំណោទបញ្ហាដែលបានចោទឡើងក៏ដូចជារាល់ ចំណុចដែលបាន លើកឡើងខាងលើយើងខ្ញុំទាំងពីរនាក់ នឹងធ្វើការអត្ថាធិប្បាយខ្លឹមសារក្នុងអត្ថបទស្រាវជ្រាវនេះ។

# ជំពូកទី១

# សញ្ញាណទូទៅនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច

បន្ទាប់ពីរួចផុតពីសម័យសង្គ្រាម កម្ពុជាបានខិតខំស្តារប្រទេសជាតិឡើងវិញ និងធ្វើការអភិវឌ្ឍប្រទេសជាតិឲ្យរីកចម្រើន ប្រទេសកម្ពុជាបានឈានទៅដល់សម័យសាកលភាវូបនីយកម្មសេដ្ឋកិច្ច ការពង្រីកការនាំចេញយ៉ាងរហ័ស និងកំណើនវិនិយោគទុនបរទេស ។ ក្នុងនោះការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺជាវិធីសាស្ត្រមួយដែលអាចទាក់ទាញអ្នកវិនិយោគធំៗ ឱ្យមកវិនិយោគលើដីនៃព្រះរាជាណាចក្រកម្ពុជា។ ដោយហេតុនេះហើយនាំឱ្យរដ្ឋាភិបាលបង្កើតនូវគោលនយោបាយផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះឡើង។ រាជរដ្ឋាភិបាលកម្ពុជា បានអនុញ្ញាតឲ្យមានការជួលដីក្នុងទំហំធំសម្រាប់ផលប្រយោជន៍ពាណិជ្ជកម្មតាមរយៈសម្បទានសេដ្ឋកិច្ច។ សម្បទានដីសេដ្ឋកិច្ច ត្រូវបានយកមកប្រើក្នុងស្ថានភាពលើកទឹកចិត្តរាល់ការវិនិយោគិនក្នុងវិស័យកសិកម្ម និងកសិ-ឧស្សាហកម្ម ដែល អាចជាប្រភពចំណូលមួយសម្រាប់រដ្ឋ តាមរយៈគម្រោងសម្បទានដីសេដ្ឋកិច្ច ដើម្បីបង្កើតចំណូលរដ្ឋ និងចំណូលខេត្ត ក្រុង ឃុំ សង្កាត់ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ ដី ពន្ធ និងកម្រៃលើសេវាពាក់ព័ន្ធ។ សម្រេចឱ្យបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគសម្រាប់ ការអភិវឌ្ឍន៍ដីក្នុងលក្ខណៈសមស្រប និងប្រកបដោយចីរភាព ដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់ទាំង នោះ ។ បង្កើតភាពមានការងារធ្វើនៅជនបទក្នុងក្របខណ្ឌនៃការធ្វើប្រពលវប្បកម្ម និងការធ្វើឱ្យមានកាលានុវត្ត ភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរបែប និង ក្នុងក្របខណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិ តាម ប្រព័ន្ធអេកូឡូស៊ីសមស្រប ។ សម្បទានដីសេដ្ឋកិច្ច ជាយន្តការមួយក្នុងចំណោមយន្តការឯទៀតដើម្បីឱ្យរដ្ឋផ្តល់ដី ឯកជនរបស់រដ្ឋសម្រាប់ប្រើប្រាស់ផលិតផល ហើយយន្តការនេះ មានសារៈសំខាន់ណាស់ពីព្រោះជាយន្តការតែ មួយគត់ដែលមានគោលដៅផ្អែកសេដ្ឋកិច្ច ។ ដូច្នេះយន្តការនេះមានតួនាទីសំខាន់ក្នុងការរកចំណូលចូលរដ្ឋ និងរកការងារឱ្យប្រជាពលរដ្ឋតាមជនបទ ។ សម្បទានដីសេដ្ឋកិច្ច ចាំបាច់ត្រូវតែឆ្លើយតបទៅនឹងប្រយោជន៍សង្គមជាតិ និងប្រយោជន៍សេដ្ឋកិច្ច ។ សម្បទានដីសេដ្ឋកិច្ចត្រូវតែ អនុញ្ញាតឱ្យ អ្នកទទួលប្រយោជន៍រៀបចំដីដើម្បីសាងសងលំនៅដ្ឋានឬដាំដំណាំនៅលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋដើម្បី ធានាការចិញ្ចឹមជីវិត។ បន្ថែមលើនេះទៀត ក៏អនុញ្ញាតឱ្យអ្នកទទួលប្រយោជន៍កាប់ឆ្ការទាញយកផលពីអាជីវកម្ម កសិកម្ម និងកសិ-ឧស្សាហកម្មលើដីនៃព្រះរាជាណាចក្រកម្ពុជា។ តាមរយៈការឆ្លុះបញ្ចាំងទាំងនេះ យើងឃើញថាការផ្តល់សម្បទានដីសេដ្ឋកិច្ច ពិតជាមានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើឲ្យប្រទេសជាតិមានការរីកចម្រើន។

## ១.១.និយមន័យ

មូលហេតុដោយសារតែបញ្ហាដែលចេះតែកើតមានផលប៉ះពាល់នៃដីសម្បទានសេដ្ឋកិច្ច លើសហគមន៍ និងបរិស្ថានក្នុងការអនុវត្តគោលនយោបាយសម្បទានដីសេដ្ឋកិច្ច ហេតុនេះហើយបានជារដ្ឋាភិបាលកម្ពុជា

បានឲ្យកែសម្រួលបង្កើតនូវបទបញ្ញត្តិក្នុងច្បាប់និងបានបង្កើតលិខិតបទដ្ឋានគតិយុត្តច្បាប់ថ្មីនានា ដើម្បីឱ្យគោលនយោបាយនេះ អាចអនុវត្តបានប្រកបដោយប្រសិទ្ធភាព។ បញ្ញត្តិស្តីពីសម្បទានដីសេដ្ឋកិច្ច មានចែងក្នុងច្បាប់ ភូមិបាល ឆ្នាំ ២០០១ រួចបន្ទាប់មក វាត្រូវបានគេយកមកចែងលម្អិតក្នុង អនុក្រឹត្យ លេខ ១៤៦ អន ក្រ/បក ចុះថ្ងៃទី២៧ ធ្នូ ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យនីតិវិធី យន្តការ និងការរៀបចំស្ថាប័នសម្រាប់ការ ផ្តួចផ្តើម និងការផ្តល់សម្បទានដីសេដ្ឋកិច្ច សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសម្រាប់ការ ត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ច ដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្រប តាមការកំណត់នៃច្បាប់ភូមិបាល ឆ្នាំ ២០០១ ។[2] មួយរយៈក្រោយមក ក៏មានការកែប្រែខ្លះ តាមរយៈ អនុក្រឹត្យលេខ១៣១ អនក្រ/បក ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ចុះថ្ងៃទី១៧ តុលា ២០០៨និងទំនាក់ទំនងជាមួយច្បាប់ពាក់ព័ន្ធដទៃទៀតដែលចូលជាធរមាន។ ច្បាប់ភូមិបាល អនុក្រឹត្យ និងសារាចរណែនាំស្តីពីសម្បទានដីសេដ្ឋកិច្ច ផ្តល់នូវមូលដ្ឋានគ្រឹះខាងផ្លូវច្បាប់សម្រាប់កិច្ចការនេះ។ យ៉ាងណាមិញសម្បទានដីសេដ្ឋកិច្ចក៏ត្រូវមានកិច្ចសន្យាសម្បទានដី សេដ្ឋកិច្ចមួយរវាង សម្បទានិក និងរដ្ឋមួយជាក់លាក់ដើម្បីឱ្យសម្បទានិកប្រើប្រាស់សម្រាប់ អាជីវកម្មកសិកម្ម និង កសិ-ឧស្សាហកម្ម ។

**១.១.១. អត្ថន័យនៃសម្បទានដីសេដ្ឋកិច្ច**

ពាក្យថា សម្បទានដី ជាការផ្តល់ដីទៅឲ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ដើម្បី កាន់កាប់ និង ប្រើប្រាស់សិទ្ធិលើដីនោះដោយស្របច្បាប់។ ចំណែកឯពាក្យ សេដ្ឋកិច្ច គឺសំដៅទៅលើមុខរបរ ដែលមានប្រយោជន៍សំខាន់ក្នុងប្រទេសនីមួយៗ។[3] ដូច្នេះ សម្បទានដីសេដ្ឋកិច្ច គឺជាការផ្តល់ដីដល់សម្បទានិកទាំងឡាយ ដើម្បីប្រកបមុខរបរ ដែលមានប្រយោជន៍សំខាន់ក្នុងប្រទេសនីមួយៗ។

យ៉ាងណាមិញ នៅក្នុងអនុក្រឹត្យ លេខ ១៤៦ បានផ្តល់អត្ថន័យប្រហាក់ប្រហែលគ្នាដែរសម្បទានដីសេដ្ឋកិច្ច គឺសំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ច សន្យាសម្បទានមួយ ទៅឱ្យសម្បទានិកដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម។[4] ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម គឺសំដៅដល់ការដាំដំណាំស្បៀង ឬដំណាំ ឧស្សាហកម្ម រាប់បញ្ចូលទាំងការដាំឈើជាចំការឈើ

[2] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា១

[3] ដកស្រង់ចេញពីវចនានុក្រមខ្មែរ ភាគទី១ កម បោះត្រាទី៥ ការផ្សាយរបស់ពុទ្ធសាសនបណ្ឌិត ព ស ២៥១១ ឆ្នាំ ១៩៦៧

[4] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២

ការចិញ្ចឹមសត្វនិងវារីវប្បកម្ម ការងារសាង សង់ ដូចជា រោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានា សម្រាប់កែច្នៃវត្ថុធាតុដើម ដែលជា កសិផលក្នុងស្រុក។[5]

ម្យ៉ាងទៀតបើតាមច្បាប់ភូមិបាលសម្បទានដី គឺជាសិទ្ធិស្របច្បាប់ ដែលមានចែងក្នុងឯកសារគតិយុត្ត ចេញដោយ អាជ្ញាធរ មានសមត្ថកិច្ច តាមអំណាចឆន្ទានុសិទ្ធិឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បី កាន់កាប់ដី និងប្រើប្រាស់សិទ្ធិលើដី តាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ២០០១។[6] សូមបញ្ជាក់ផងដែរថាតាម ច្បាប់ភូមិបាលការផ្តល់សម្បទានដី គឺអាជ្ញាធរមានសមត្ថកិច្ចផ្តល់ឱ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ប៉ុន្តែច្បាប់ ភូមិបាលមិនបានកំណត់អំពីសញ្ជាតិរបស់រូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្សទេថា តើបុគ្គល ទាំងអស់នោះត្រូវតែមានសញ្ជាតិខ្មែរ ឬមានសញ្ជាតិបរទេសទេ? បើតាមច្បាប់ភូមិបាលមិនបានបញ្ជាក់បន្ថែម នោះទេ។ ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺត្រូវតែឆ្លើយតបទៅនឹងផលប្រយោជន៍សេដ្ឋកិច្ច ដែលអនុញ្ញាតឱ្យ អ្នកទទួល បានប្រយោជន៍ កាប់ឆ្ការទាញយកផលដោយធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម លើដីនៃប្រទេសកម្ពុជា ដែលផ្ទុយនឹងសម្បទានដីសង្គមកិច្ច គឺត្រូវឆ្លើយតបទៅនឹងប្រយោជន៍សង្គម អនុញ្ញាតឱ្យអ្នកទទួល ប្រយោជន៍រៀបចំដី ដើម្បីសង់លំនៅឋាន ឬដាំដំណាំលើដីដែលជាកម្មសិទ្ធិរបស់រដ្ឋ ដើម្បីធានាការ ចិញ្ចឹម ជីវិត។[7]

### ១.១.២.កម្មវត្ថុនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច

សម្បទានដីសេដ្ឋកិច្ចត្រូវបាន រាជរដ្ឋាភិបាលយកចិត្តទុកដាក់ជាខ្លាំង ដោយយោងទៅលើ ផល ប្រយោជន៍ ដែលកម្ពុជាទទួលបានពីការបើកទូលាយឱ្យឯកជនចូលរួមក្នុងភាពជាដៃគូនៃកិច្ចអភិវឌ្ឍប្រទេស ជាតិ។ គោលបំណងសំខាន់គឺការកាត់បន្ថយភាពក្រីក្រ ដោយផ្អែកលើកំណើនសេដ្ឋកិច្ចកម្រិតខ្ពស់ និង ការ បែងចែកទូលំទូលាយនូវផ្លែផ្កា នៃកំណើនសេដ្ឋកិច្ច។ មានចក្ខុវិស័យអភិវឌ្ឍន៍ វិស័យកសិកម្ម និងកសិ-ឧស្សាហ កម្ម ជនបទនៅកម្ពុជា កាន់តែច្បាស់លាស់។ ម្យ៉ាងវិញទៀត ការផ្តល់សម្បទានដីសេដ្ឋកិច្ច ក៏ជួយអភិវឌ្ឍ សកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម ព្រោះប្រជាជនកម្ពុជា ៨០% ទៅ ៨៥%ជា កសិករ ដែលរស់នៅជនបទ គឺប្រកបរបរកសិកម្មដោយសារតែប្រទេសកម្ពុជាអំណោយផលច្រើនក្នុងវិស័យ នេះ។ ដូច្នេះ ការអភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម ជាគោលនយោបាយមួយ ក្នុង ការអភិវឌ្ឍវិស័យ សេដ្ឋកិច្ចជាតិ។ ហើយសម្រាប់ការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់គឺទុនវិនិយោគចាប់ ពី ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀលឡើង ដែលមានទំហំដី សម្បទានចាប់ពី ១.០០០ (មួយពាន់)

---

[5] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣

[6] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៤៨

[7] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៤៩

ហិកតាឡើងទៅ និងទុន វិនិយោគក្រោម ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀល ដែលមានទំហំដីសម្បទានក្រោម ១.០០០ (មួយពាន់)ហិចតា។[៨] ការសម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពី អ្នកវិនិយោគសម្រាប់ការអភិវឌ្ឍន៍ ក្នុងលក្ខណៈសមស្រប និង ប្រកបដោយចីរភាពដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ។ បង្កើនភាពមានការងារធ្វើនៅជនបទក្នុងក្របខណ្ឌនៃការធ្វើ ប្រពលវប្បកម្ម និងការធ្វើឲ្យមានកាលានុវត្តភាព នៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈ សម្បូរបែប និង ក្នុងក្របខណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិតាមបែបប្រព័ន្ធ អេកូឡូស៊ីសមស្រប។ លើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច បង្កើនចំណូលរដ្ឋ ឬ ចំណូលរាជធានី ខេត្ត ឃុំ សង្កាត់ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ពន្ធ និង កម្រៃលើសេវាពាក់ព័ន្ធ។[៩]

ដូចនេះគោលបំណងនៃការធ្វើសម្បទានដីសេដ្ឋកិច្ចគឺដើម្បីសកម្មភាពកសិកម្មតាមបែបប្រពលវប្បកម្មដែលជាដំបូងតម្រូវឲ្យមានការវិនិយោគត្រឹមត្រូវ។ នៅក្នុងកិច្ចព្រមព្រៀងសម្បទានដីរដ្ឋប្រគល់សិទ្ធិឲ្យវិនិយោគិន ប្រើប្រាស់ទ្រព្យដែល ជាធនធានរបស់រដ្ឋ គឺដើម្បីទទួលបានមកវិញនូវការយល់ព្រមអភិវឌ្ឍន៍លើដី និងការបង្កើតការងារពីវិនិយោគិន។ ម្យ៉ាងវិញទៀត សម្បទានត្រូវមានលក្ខណៈសមស្រប តែនៅក្នុងពេលរដ្ឋមានបំណង ចង់ទាក់ទាញឲ្យមានការប្រើប្រាស់ប្រភេទដីណាមួយ និង ការវិនិយោគលើដីនោះ។

## ១.២.គោលការណ៍នៃការផ្តល់សម្បទានដីសេដ្ឋកិច្ច

ជាទូទៅសម្បទានដីជាគោលការណ៍គឺជាការប្រគល់ដីជាកម្មសិទ្ធិឯកជនរបស់រដ្ឋ ដោយអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋទៅឲ្យរូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដើម្បីកាន់កាប់និងប្រើប្រាស់តាមការកំណត់នៃច្បាប់។ ការប្រគល់ដីដ៏ធំទូលាយទៅឲ្យអ្នកវិនិយោគទុន គឺដើម្បីបំរើប្រយោជន៍ខាងសេដ្ឋកិច្ចដែលការឲ្យនេះភ្ជាប់និងកាតព្វកិច្ចឲ្យអ្នកវិនិយោគទុននោះបង់ប្រាក់ជូនរដ្ឋ។ អ្នកទទួលបានសម្បទានដីពីរដ្ឋាភិបាលត្រូវ មានសិទ្ធិដាំដុះ និងធ្វើអាជីវកម្មកសិឧស្សាហកម្ម។ ហើយមុននឹងឈានដល់ដំណាក់កាលសម្រេចផ្តល់ដីសម្បទានដីសេដ្ឋកិច្ចទៅឲ្យសម្បទានិករដ្ឋាភិបាលក៏ត្រូវមានគម្រោងផែនការក្នុងការកំណត់នូវលក្ខខណ្ឌទូទៅមួយចំនួនដែលតម្រូវឱ្យសម្បទានិកត្រូវតែបំពេញមុនការផ្តល់ដីសម្បទានសេដ្ឋកិច្ចមានដូចជា លក្ខណៈវិនិច្ឆ័យលើប្រភេទដី លក្ខណៈសម្បត្តិរបស់សម្បទានិក លក្ខណៈវិនិច្ឆ័យលើសំណើសម្បទានដីសេដ្ឋកិច្ច និងរយៈពេលនៃទំហំដីការផ្តល់សម្បទានដីសេដ្ឋកិច្ច។

### ១.២.១.លក្ខណៈវិនិច្ឆ័យលើប្រភេទដី

[៨] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២៩

[៩] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣

ក្នុងការផ្តល់ដីសម្បទានដីសេដ្ឋកិច្ច រដ្ឋដែលជាអាជ្ញាធរមានសមត្ថកិច្ចចាំបាច់ណាស់ត្រូវចូលរួមត្រួតពិនិត្យពីប្រភេទដីដែលអាចត្រូវផ្តល់ទៅឲ្យអ្នកវិនិយោគបាន។ សម្បទានដីសេដ្ឋកិច្ចអាចត្រូវបាន ផ្តល់ឱ្យសម្បទានិកចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យទាំង ៥ ដូចខាងក្រោម ៖

ទីមួយ ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រង ដីរដ្ឋ និងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យ ស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។

ទីពីរ ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ហើយការប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ ។

ទីបី ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន ។

ទីបួន ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មាន ការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅ កាន់ដី ឯកជន។

ទីប្រាំ ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬ សំណើសម្បទានដីសេដ្ឋកិច្ចជាមួយ អាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់។[10]

ការផ្តល់សម្បទានដីសេដ្ឋកិច្ចអាចធ្វើឡើងបានតែទៅលើដីដែលជាចំណែក នៃទ្រព្យសម្បត្តិឯកជនរបស់រដ្ឋតែប៉ុណ្ណោះទើបអាជ្ញាធរមានសមត្ថកិច្ចអាចធ្វើការផ្តល់ទៅឲ្យសម្បទានិកបាន។ ដូច្នេះយើងគម្បីស្វែងយល់ឲ្យកាន់តែស៊ីជម្រៅថាតើអ្វីទៅជាអចលនទ្រព្យឯកជនរបស់រដ្ឋ? ទ្រព្យឯកជនរបស់រដ្ឋ មានន័យថាសំដៅលើដីទាំងឡាយណា ដែលមិនមែនជាដីសាធារណៈរបស់រដ្ឋ មិនមែនជាដីដែលកាន់កាប់ដោយភោគៈស្របច្បាប់ ឬជាកម្មសិទ្ធិបុគ្គលឯកជន ឬសមូហភាពស្របតាមច្បាប់កំណត់។ ដីឯកជនរបស់រដ្ឋមានរួមបញ្ចូលដូចជាទ្រព្យនិទាយាទ ភាពទាំងអស់ ឬទ្រព្យដែលម្ចាស់ប្រគល់ឱ្យរដ្ឋដោយស្ម័គ្រចិត្ត ឬទ្រព្យដែលមិនអាចកំណត់បាននូវ អត្តសញ្ញាណភោគី ឬកម្មសិទ្ធិករស្របច្បាប់។[11] ហើយប្រសិនបើដីនោះជាដីសាធារណៈរបស់រដ្ឋ គឺទាមទារឲ្យមានការធ្វើអនុប្បយោគឲ្យទៅជាដីឯកជនរបស់រដ្ឋជាមុនសិន តាមច្បាប់អនុប្បយោគ។ កាលណាទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋក្លាយទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ នោះទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ដែល

[10] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៤

[11] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨ អនក្រ/បក ចុះថ្ងៃទី០៧ តុលា ២០០៥ មាត្រា៥

បានធ្វើអនុប្បយោគរួចនឹងអាចផ្តល់សម្រាប់សម្បទានដីសេដ្ឋកិច្ចបាន។ ការធ្វើអនុប្បយោគ គឺត្រូវគោរពតាមល័ក្ខខ័ណ្ឌមួយចំនួនដូចជា ទ្រព្យសម្បត្តិនោះលែងជាតម្រូវការនៃផលប្រយោជន៍សាធារណៈ ឬ ទ្រព្យសម្បត្តិនោះ បាត់បង់លក្ខណៈសម្បត្តិពេញលេញរបស់ខ្លួនក្នុងការបម្រើប្រយោជន៍សាធារណៈ ឬ ទ្រព្យសម្បត្តិនោះលែងជាការប្រើប្រាស់ដោយផ្ទាល់ ដោយសាធារណជន។[12] ម្យ៉ាងវិញទៀតការធ្វើអនុបយោគ ទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ អាចធ្វើទៅបានតែចំពោះទ្រព្យសម្បត្តិទាំងឡាយណា ដែលបានចុះក្នុងបញ្ជីសារពើភ័ណ្ឌទ្រព្យ សម្បត្តិរបស់រដ្ឋរួចជាស្រេច។[13]

លើសពីនេះទៅទៀត សម្បទានដីសេដ្ឋកិច្ច គឺមិនអាចប៉ះពាលដីជាចំណីផ្លូវ និង ដីចាំបាច់សម្រាប់ថែទាំ ក៏ដូចជា ផ្លូវទឹក ត្រពាំង បឹង និង ដែនទឹកបម្រុង ដែលមានប្រយោជន៍ដល់ការរស់នៅរបស់ប្រជាពលរដ្ឋឡើយ។[14] នេះបានសេចក្តីថា ការផ្តល់សម្បទាន គឺមិនអាចធ្វើបានទេចំពោះតំបន់ ដែលមានជាប្រយោជន៍សម្រាប់ ការរស់នៅរបស់ប្រជាពលរដ្ឋ និង ប៉ះពាល់ដល់ជីវភាពរបស់ពួកគាត់។ ប៉ុន្តែចំពោះ ការផ្តល់សម្បទានដីសេដ្ឋកិច្ចមួយចំនួន គឺប៉ះពាល់ដល់តំបន់រស់នៅរបស់ប្រជាពល រដ្ឋ។ ដូចនេះ រដ្ឋ អាចជម្លៀសប្រជាជនបានដោយផ្តល់ជាសំណង ឬ ការដោះដូរ ជាលំនៅដ្ឋាននៅតំបន់ថ្មីវិញ។

### ១.២.២.លក្ខណៈសម្បត្តិរបស់សម្បទានិក

សម្បទានដីសេដ្ឋកិច្ចជាសិទ្ធិស្របច្បាប់ ដែលបានចែងនៅក្នុងឯកសារគតិយុត្ត ចេញដោយអាជ្ញាធរមាន សមត្ថកិច្ច តាមអំណាចឆន្ទានុសិទ្ធិ ផ្តល់ឲ្យរូបវន្តបុគ្គល ឬ នីតិបុគ្គល ឬ ក្រុមមនុស្ស ដើម្បីកាន់កាប់ដី និង ប្រើប្រាស់សិទ្ធិលើដីនោះ ដូចដែលមានចែងក្នុងមាត្រា ៤៨ នៃច្បាប់ភូមិបាលឆ្នាំ ២០០១។ ហើយបើតាមបទបញ្ញត្តិនៃច្បាប់ភូមិបាលនេះបុគ្គលដែលមានលក្ខណៈសម្បត្តិអាចស្នើសុំសម្បទានដីសេដ្ឋកិច្ចបាន គឺអាចជារូបវន្តបុគ្គល ឬ ជានីតិបុគ្គល។

ជាទូទៅសម្រាប់សម្បទានិកដែលមានសិទ្ធិអាច ទទួលបាននូវដីសម្បទានសេដ្ឋកិច្ច មិនត្រូវបានគេកំណត់សញ្ជាតិនោះទេ ក្នុងពេលផ្តល់សម្បទានដីសេដ្ឋកិច្ចកន្លងមកយើងសង្កេតឃើញថាមានទាំងវិនិយោគិនក្នុងស្រុក និងបរទេស ហើយភាគច្រើននៃសម្បទានិកគឺជានីតិបុគ្គលតែប៉ុណ្ណោះ។ នេះប្រហែលជានីតិបុគ្គលមានសមត្ថភាព និងមានលក្ខខណ្ឌគ្រប់គ្រាន់ដែលរដ្ឋអាចផ្តល់ដីសម្បទានសេដ្ឋកិច្ចជូនបាន។

---

[12] ព្រះរាជក្រឹត្យស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ,លេខនស/រកត/០៨/០៦/៣៣៩,០៣ សីហា ២០០៦,មាត្រា៣

[13] ព្រះរាជក្រឹត្យស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ,លេខនស/រកត/០៨/០៦/៣៣៩,០៣ សីហា ២០០៦,មាត្រា៤

[14] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៥៨

បន្ថែមពីនេះទៅទៀត សម្បទានិកត្រូវតែមានគម្រោងនិងផែនការអភិវឌ្ឍន៍របស់ខ្លួនឲ្យបានច្បាស់លាស់ក្នុងពេលទទួលបានដីសម្បទានសេដ្ឋកិច្ចហើយត្រូវសម្រេចឲ្យបានតាមគោលបំណងចង់បានរបស់រដ្ឋាភិបាលដែលបានចែងក្នុង មាត្រា៣ ក្នុងអនុក្រឹត្យសម្បទានដីសេដ្ឋកិច្ច។

### ១.២.៣.លក្ខណៈវិនិច្ឆ័យលើសំណើសម្បទានដីសេដ្ឋកិច្ច

មុននឹងធ្វើការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺត្រូវធ្វើការវាយតម្លៃលើសំណើសម្បទានដីសេដ្ឋកិច្ចជាមុនសិន ព្រោះវាជាលក្ខខណ្ឌចាំបាច់មួយក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះ។ ការវាយតម្លៃសំណើសម្បទានដីសេដ្ឋកិច្ច ត្រូវផ្អែកលើលក្ខណវិនិច្ឆ័យដូចខាងក្រោម៖

- ការបង្កើនផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដោយប្រើប្រាស់បច្ចេកទេសទំនើប
- ការបង្កើតឱ្យមានការងារធ្វើកាន់តែច្រើន
- ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព
- ការចៀសវាង ឬការកាត់បន្ថយឱ្យនៅតិចបំផុតនូវហេតុប៉ះពាល់អវិជ្ជមានសង្គម
- ការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ចប្រសិនបើមាន
- ការកែច្នៃវត្ថុធាតុដើម ជាកសិផលដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាសម្បទាន។[15]

ការវាយតម្លៃនេះគឺមានគោលបំណងលើកកម្ពស់ការរស់នៅរបស់ប្រជាជន បង្កើតឲ្យមានការងារធ្វើកាន់តែច្រើន ការការពារបរិស្ថាននិង ការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព។ ក្នុងករណីក្រុមហ៊ុនដែលទទួលបានសម្បទានដីសេដ្ឋកិច្ចរួចហើយ បែរជាអនុវត្តផ្ទុយនឹងលក្ខខណ្ឌដែលបានកំណត់ក្នុងការវាយតម្លៃនោះ អាជ្ញាធរមានសមត្ថកិច្ចអាចដកហូតយកដីសម្បទានដីសេដ្ឋកិច្ចពីក្រុមហ៊ុននោះវិញបាន ដោយហេតុថាវាផ្ទុយនឹងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥។

### ១.២.៤.រយៈពេលនៃទំហំដីការផ្តល់សម្បទានដីសេដ្ឋកិច្ច

ជាទូទៅសម្រាប់រយៈពេលសម្បទានដីសេដ្ឋកិច្ចពីមុនមានរយៈពេលវែងជាងឥឡូវពេលគឺ ៩៩ (កៅសិបប្រាំបួន) ឆ្នាំយ៉ាងច្រើនបំផុត។ ប៉ុន្តែចាប់តាំងពីឆ្នាំ២០១៥ រដ្ឋាភិបាលបានកែសម្រួលរយៈពេលដីឯកជនរបស់រដ្ឋ ដែលបានធ្វើសម្បទានសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុនឯកជនកន្លងមក ដែលមានរយៈពេល ៩៩ (កៅសិបប្រាំបួន) ឆ្នាំ គឺដាច់ខាតត្រូវកាត់រយៈពេលមកត្រឹម ៥០(ហាសិប)ឆ្នាំ វិញ។ ការកាត់បន្ថយនេះ គឺដោយសាររដ្ឋាភិបាលមើលឃើញថា គម្រោងអភិវឌ្ឍនៅក្នុងដីសម្បទាននោះមិនគួរមានរយៈពេលដល់ទៅជិត

[15] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៥

១០០(មួយរយ) ឆ្នាំនោះឡើយ។ មានន័យថាកិច្ចសន្យាសម្បទាន អាចធ្វើបានយូរបំផុត គឺ ៥០ (ហាសិប)ឆ្នាំ ហើយនៅពេលដល់ កាលបរិច្ឆេទ សិទ្ធិរបស់សម្បទានិកលើដីសម្បទាន គឺត្រូវបានបាត់បង់។ សម្រាប់រយៈពេលដែលបានកាត់បន្ថយនេះក៏ចែងក្នុងមាត្រា៣៩ និងមាត្រា៥៣ នៃច្បាប់ស្ដីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ អនុម័តកាលពីថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០។

សម្រាប់ទំហំដីនៅក្នុងការផ្ដល់ដីសម្បទានសេដ្ឋកិច្ច ទោះជាយ៉ាងណាក៏ដោយ ត្រូវតែកំណត់តាមមាត្រា៥៩ នៃច្បាប់ភូមិបាល ឆ្នាំ២០០១ ចែងថា សម្បទានដីអាចមានទំហំច្រើនបំផុតត្រឹមតែ១០.០០០ (មួយម៉ឺន) ហិកតា ប៉ុណ្ណោះ។ ការកំណត់នេះ បានបង្ហាញថា សម្បទានដីសេដ្ឋកិច្ច គឺអាចធ្វើបានជាអតិបរមាត្រឹម ១០.០០០ (មួយម៉ឺន) ហិកតា ហើយរូបវន្តបុគ្គល ឬ នីតិបុគ្គលម្នាក់ ដែលជាសម្បទានិក មិនអាចទទួលបានដីសម្បទានសរុបលើសពី ១០.០០០(មួយម៉ឺន)ហិកតាឡើយ។ សម្រាប់អ្នកដែលទទួលបន្ទុកផ្ដល់ដីសម្បទានសេដ្ឋកិច្ចគឺរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្ដល់សម្បទានដីសេដ្ឋកិច្ចដែលមានដើមទុនវិនិយោគចាប់ពី ១០.០០០.០០០.០០០ (ដប់ពាន់លានរៀល) ឡើង ឬ មានទំហំដី សម្បទានចាប់ពី១.០០០ (មួយពាន់) ហិកតា ឡើង ។[16] រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលទទួលសិទ្ធិប្រទានពីនាយករដ្ឋមន្ត្រី អាចមានសិទ្ធចុះហត្ថលេខានៅលើកិច្ចសន្យា ផ្ដល់សម្បទានដីសេដ្ឋកិច្ច ចាប់ពី ១.០០០ (មួយពាន់) ហិកតា ឡើងទៅបាន ។ រីឯអភិបាលខេត្ត ក្រុង មានសិទ្ធិនិងទទួលខុសត្រូវក្នុងការផ្ដល់សម្បទានដីសេដ្ឋកិច្ច ដែលមានដើមទុនវិនិ យោគក្រោម ១០.០០០.០០០.០០០(ដប់ពាន់លានរៀល) និងមានទំហំដីក្រោម១.០០០ (មួយពាន់) ហិចតា។[17] ប៉ុន្តែ អភិបាលខេត្ត ក្រុងត្រូវស្នើសិទ្ធិប្រទានពីនាយករដ្ឋមន្ត្រីដើម្បីចុះហត្ថលេខាលើកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ។ ក្នុងទិដ្ឋភាពជាក់ស្ដែងគេសង្កេតឃើញថា៩៩% នៃដីសម្បទានសេដ្ឋកិច្ចគឺ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលជាអ្នកទទួលបន្ទុកផ្ដល់ឲ្យវិនិយោគិន។

[16] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២៩

[17] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២៩

# ជំពូកទី២
# នីតិវិធីការផ្តល់សម្បទានដីសេដ្ឋកិច្ច

ជាទូទៅការផ្តល់សម្បទានដីសេដ្ឋកិច្ច ប្រព្រឹត្តិទៅតាមនីតិវិធីការរៀបចំស្នើគំរោងនោះឡើងនៅក្នុងការផ្តល់ដីសេដ្ឋកិច្ចដោយធ្វើឡើងមានរូបភាពពីរផ្សេងពី គ្នាគឺការផ្តួចផ្តើមគម្រោងដោយអាជ្ញាធរមានសមត្ថកិច្ច និង ការផ្តួចផ្តើមគម្រោងដោយដោយអ្នកវិនិយោគ ។ នៅក្នុងបេសកម្មការអនុវត្តគម្រោងផែនការទាំងពីរនេះគឺត្រូវទាមទារធ្វើ ទៅតាមដំណាក់កាលនីតិវិធីនីមួយៗ ដែលដំណាក់កាលនីតិវិធីមួយទៅដំណាក់កាលនីតិវិធីមួយទៀតមានភាពខុសប្លែកគ្នា តែមានភាពប្រទាក់ក្រឡាគ្នាដែលមិនអាចកាត់ផ្តាច់ពីគ្នាបានឡើយ ។

លើសពីនេះទៀតផងដែរ ការធ្វើគម្រោងណាមួយ មិនត្រឹមតែគម្រោងដែលស្ថិតនៅក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ចប៉ុណ្ណោះទេ គម្រោងអភិវឌ្ឍន៍ដទៃទៀតក៏តម្រូវឲ្យមានការវាយតម្លៃផ្នែកបរិស្ថានទាំងអស់។ ដូចនេះដើម្បីឲ្យយល់កាន់តែច្បាស់អំពីនីតិវិធីនៃការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចយើងខ្ញុំធ្វើការសិក្សាលំអិត និង ស្វែងយល់ឱ្យកាន់តែច្បាស់អំពីនីតិវិធី នៃការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ យើងខ្ញុំទាំងពីរនាក់សូមធ្វើការពន្យល់បកស្រាយលំអិតនៅខាងក្រោមការបែងចែកចំណុចមកធ្វើការបកស្រាយ(ចំណុចលំអិតនីមួយៗ មានរៀបរាប់នៅក្នុងមាតិការួចជាស្រេច)។

## ២.១.គម្រោងសម្បទានដីសេដ្ឋកិច្ច

ជាទូទៅក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ចអាចធ្វើបាននៅពេលមានការអំពាវនាវ ប្រសិនបើគ្មានការអំពាវនាវទេ អ្នកវិនិយោគអាចធ្វើការស្នើសុំទៅរដ្ឋដើម្បីសុំការអនុញ្ញាតបាន។ ហើយអ្នកដាក់សំណើគម្រោងត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្មស្របតាមច្បាប់ស្តីពីវិធានពាណិជ្ជកម្មនិងបញ្ជីពាណិជ្ជកម្មនៃព្រះរាជាណាចក្រកម្ពុជាមុនចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។ សម្រាប់នៅក្នុងនីតិវិធីនៃគម្រោងសម្បទានដីសេដ្ឋកិច្ចនេះ អាចធ្វើឡើងក្នុងករណីពីរគឺតាម ការផ្តួចផ្តើមគម្រោងដោយអាជ្ញាធរមានសមត្ថកិច្ច និង ការផ្តួចផ្តើមគម្រោងដោយអ្នកវិនិយោគសំណើសម្បទានដីសេដ្ឋកិច្ច ។

### ២.១.១.ការផ្តួចផ្តើមគម្រោងដោយអាជ្ញាធរមានសមត្ថកិច្ច

គម្រោងសម្បទានដីសេដ្ឋកិច្ចកើតចេញពីសំណើមានការអំពាវនាវ ដែលផ្តួចផ្តើមឡើងដោយអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ជាអ្នកលើកសំណើគឺអាជ្ញាធរត្រូវ រៀបចំឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ចហើយទម្រង់ឯកសារដំបូងនេះត្រូវបង្កើតឡើងដោយលេខាធិការដ្ឋានបច្ចេកទេស។ ឯកសារដំបូងមានសារៈសំខាន់ណាស់ដើម្បីឲ្យអ្នកមានបំណងវិនិយោគ ធ្វើការបំពេញនូវលក្ខខណ្ឌដែលមានកំណត់ក្នុងឯកសារព្រមទាំងត្រួតពិនិត្យយ៉ាងល្អិតល្អន់លើឯកសារទាំងនោះ។ កាលណាអ្នកវិនិយោគបានបំពេញនូវលក្ខខណ្ឌដែលបានកំណត់ក្នុងឯកសារដំបូងនេះ អ្នកវិនិយោគអាចដាក់ពាក្យស្នើសុំសម្បទានសេដ្ឋកិច្ចនេះបាន

តែប្រសិនបើមិនបំពេញត្រូវតាមលក្ខខណ្ឌឯកសារដំបូងទេនោះអ្នកវិនិយោគមិនអាចដាក់ពាក់ស្នើសុំបានទេ ។ សម្រាប់ឯកសារដំបូង ត្រូវមានទម្រង់គោលការណ៍ដែលច្បាប់បានតម្រូវដូចជា ទីតាំង ទំហំ ប្រភេទ លេខសម្គាល់ក្បាលដីដែលចុះក្នុងសៀវភៅគោលបញ្ជីដីធ្លីនិងព័ត៌មានទូទៅអំពីតំបន់ដែលដីនោះស្ថិតនៅ។[18] មិនតែប៉ុណ្ណោះវាតម្រូវឲ្យមានការរៀបចំ ឲ្យមានការវាយតម្លៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច។ ប្រសិនបើការវាយតម្លៃអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម បង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬកម្រិតខ្ពស់ គឺត្រូវរៀបចំឲ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ។[19] ហើយបន្ទាប់មកអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបញ្ជូនឯកសារដំបូង ទៅលេខាធិការដ្ឋានបច្ចេកទេសដើម្បីធ្វើការពិនិត្យសិក្សានិងផ្តល់អនុសាសន៍ជាបឋមដោយផ្អែកលើគោលបំណង នៃសម្បទានដីសេដ្ឋកិច្ចនិងការវាយតម្លៃសំណើសម្បទានដីសេដ្ឋកិច្ច។ បន្ទាប់មកឯកសារដំបូងដែលមានបញ្ចូលអនុសាសន៍ទាំងអស់ និងរបាយការណ៍នានាដែលជាលទ្ធផលនៃជំហានរៀបរាប់ខាងលើគឺជាមូលដ្ឋានក្នុងការរៀបចំឯកសារពេញលេញស្តីពីលក្ខខណ្ឌ សម្រាប់ការដាក់សំណើដែលមានការអំពាវនាវរួចរាល់ សម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច។

បន្ទាប់ពីធ្វើការសិក្សាចប់រួចរាល់ហើយ លេខាធិការដ្ឋានបច្ចេកទេសនៅពេលទទួលបានឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចពីអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវរៀបចំឯកសារ ដោយមានការអំពាវនាវឲ្យដាក់សំណើសុំសម្បទានដីសេដ្ឋកិច្ច ដែលរួមមានដូចជា សេចក្តីជូនដំណឹង ឯកសារ ស្តីពីលក្ខខណ្ឌ និង ពាក្យសុំផងដែរ។[20] លេខាធិការដ្ឋានបច្ចេកទេស ត្រូវផ្សព្វផ្សាយឲ្យបានទូលំទូលាយ នូវសេចក្តីជូនដំណឹងឲ្យដាក់សំណើ និងបញ្ជូនសេចក្តីជូនដំណឹងនោះ ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ ហើយសេចក្តីជូនដំណឹងនេះ ត្រូវបញ្ជាក់ពីរបៀបនៃការដាក់ពាក្យ ទីកន្លែង និងរយៈពេលសម្រាប់ការដាក់សំណើ ដោយកំណត់នូវកាលបរិច្ឆេទទួល និងឈប់ទទួលពាក្យ។ ការដាក់សំណើមានរយៈពេលយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង។[21] ម្យ៉ាងទៀតលេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំការប្រជុំជាសាធារណៈ ដើម្បីបំភ្លឺអំពីចំណុចមួយចំនួននៃឯកសារអំពាវនាវឲ្យដាក់សំណើនេះ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទបិទទទួលសំណើ ហើយការបំភ្លឺដែលបានធ្វើឡើងត្រូវកត់ត្រាទុកជាឯកសារ

[18] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៨

[19] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៧

[20] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៩

[21] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា១០

សាធារណៈ។[22] សម្រាប់សំណើអ្នកវិនិយោគ ដែលបានដាក់ពាក្យស្នើសុំត្រូវមានភ្ជាប់ព័ត៌មានលំអិតអំពីផែនការឲ្យគ្រប់លក្ខខណ្ឌដែលបានដាក់ដោយអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា។

បន្ទាប់មកទៀតសំណើសម្បទានដីសេដ្ឋកិច្ច ដែលបានពិនិត្យឃើញថាគ្រប់លក្ខខណ្ឌដែលសមស្របតាមការទាមទាររួចហើយ ត្រូវដាក់សំណើនៅលេខាធិការដ្ឋានបច្ចេកទេស ក្នុងស្រោមសំបុត្របិទជិត និងមានចុះហត្ថលេខា ឬបោះត្រារបស់ម្ចាស់សំណើលើស្នាមបិតមុខសំបុត្រ។ សំណើដែលដាក់ក្រោយកាលបរិច្ឆេទបិទការទទួលសំណើ គឺត្រូវបង្វិលទៅឲ្យម្ចាស់សំណើវិញដោយមិនត្រូវបានបើកស្រោមសំបុត្រឡើយ។[23] បន្ទាប់ពីការពិចារណាលើអនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធ្វើការវាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើដែលមានលក្ខណៈឆ្លើយតបទាំងអស់ និងរៀបចំរបាយការណ៍វាយតម្លៃសំណើដែលមានលក្ខណៈឆ្លើយតប ហើយផ្តល់របាយការណ៍វាយតម្លៃនោះមួយច្បាប់ឱ្យម្ចាស់ សំណើនីមួយៗ។[24] អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវអញ្ជើញម្ចាស់សំណើដែលជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេ មកធ្វើការចរចាកិច្ចសន្យាសម្បទាន។ ប្រសិនបើការចរចាមិនអាចឈានដល់ការសម្រេចបានកិច្ចសន្យាសម្បទាននោះទេការចរចជាមួយម្ចាស់សំណើត្រូវបញ្ឈប់ ហើយត្រូវអញ្ជើញអ្នកដាក់សំណើដែលជាប់លំដាប់ថ្នាក់បន្ទាប់មកធ្វើការចរចាកិច្ចសន្យាជាបន្តបន្ទាប់រហូតដល់ការសម្រេចបាននូវសេចក្តីព្រាងកិច្ចសន្យាសម្បទានហើយឱ្យម្ចាស់សំណើបំពេញលក្ខខណ្ឌ។

### ២.១.២. ការផ្តួចផ្តើមគម្រោងដោយអ្នកវិនិយោគ

ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចដោយអ្នកវិនិយោគ គឺជានីតិវិធីមួយដែលបុគ្គលឯកជនជាអ្នកផ្តួចផ្តើមក្នុងការស្នើសុំសម្បទានដីសេដ្ឋកិច្ច ដែលអាចហៅបានថាការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈសំណើមិនមានការអំពាវនាវ។ ក្នុងការដាក់សំណើមិនមានការអំពាវនាវដោយបុគ្គលឯកជនអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទាន អាចធ្វើការពិចារណាលើសំណើសម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវណាមួយបាន ក្នុងករណីម្ចាស់សំណើសន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខខណ្ឌពិសេស ដើម្បីសម្រេចនូវគោលបំណងនៃសម្បទានដីសេដ្ឋកិច្ច មានដូចជា ការនាំមកនូវបច្ចេកវិទ្យាថ្មី ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ចទៅនិងសម្បាទានដីសង្គមកិច្ច លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃ ឬទីផ្សារនាំចេញ។ ផ្ទុយទៅវិញអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវទទួលយកមកពិចារណានូវសំណើ

[22] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា១៣

[23] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា១៥

[24] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា១៦

សម្បទានដីសេដ្ឋកិច្ចមិនមានការអំពាវនាវទេប្រសិនបើសំណើនោះទាក់ទងទៅនឹងដីដែលជាកម្មវត្ថុនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ដែលបានផ្សព្វផ្សាយសេចក្ដីជូនដំណឹងឱ្យដាក់សំណើរួចហើយ ។[25]

ប្រសិនបើមានការពិចារណាមួយហើយលេខាធិការដ្ឋានបច្ចេកទេស មានតួនាទីត្រូវរៀបចំពាក្យសុំសម្រាប់លើកសំណើមិនមានការអំពាវនាវដោយបញ្ចូលសេចក្ដីពណ៌នាសង្ខេប អំពីសាវតាផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុរបស់ម្ចាស់សំណើ គោលគំនិត ស្ដីពីការវិនិយោគដែល ស្នើឡើង ព្រមទាំងព័ត៌មានទាក់ទងទៅនឹងទំហំដី និងទីតាំងដី។ ហើយម្ចាស់សំណើ អាចដាក់ពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅ អនុគណៈកម្មការវិនិយោគខេត្ត ក្រុង ។ ប្រសិនបើពាក្យសុំសម្រាប់សំណើ មិនមានការអំពាវនាវ ត្រូវបានដាក់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្តក្រុង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មការវិនិយោគខេត្តក្រុង ត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ក្នុងរយៈពេល ០៧ (ប្រាំពីរ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យសុំ។[26] ម្យ៉ាងទៀតម្ចាស់សំណើក៏អាចដាក់ពាក្យទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានដីដោយផ្ទាល់បាន។

ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្រេច ធ្វើការពិចារណាសំណើមិនមានការអំពាវនាវ អាជ្ញាធរត្រូវធ្វើការពិគ្រោះយោបល់ ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង និងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច។ បន្ទាប់មកអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវរៀបចំបំពេញលក្ខណវិនិច្ឆ័យទាំង៥ សម្រាប់ការជ្រើសរើសដីធ្វើសម្បទានហើយស្នើឱ្យម្ចាស់សំណើផ្ដល់ជូននូវឯកសារលំអិតនៃសំណើ។ បន្ទាប់មកទៀតអាជ្ញាធរមានសមត្ថកិច្ចត្រូវបញ្ជូនឯកសារលំអិតទៅលេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុងដើម្បីពិនិត្យនិងផ្ដល់អនុសាសន៍ថាគួរ ឬ មិនគួរធ្វើការចរចារលើកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនោះ។[27] ហើយការចរចាចុះកិច្ចសន្យានេះ ត្រូវធ្វើឡើងក្នុងរយៈពេលយ៉ាងច្រើន២៨ (ម្ភៃប្រាំបី) ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃផ្ដើមការចរចា។ បើការចរចាមិនឈានដល់ការសម្រេចសេចក្ដីព្រាងកិច្ចសន្យា សម្បទានក្នុងរយៈពេលកំណត់នេះទេអាជ្ញាធរមានសមត្ថកិច្ច ចុះកិច្ចសន្យាអាចបញ្ឈប់ការពិចារណាលើសំណើនោះ។[28] លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំទម្រង់ស្តង់ដារ នៃកិច្ចសន្យាសម្បទានដែលត្រូវប្រើសម្រាប់រាល់សម្បទានដីសេដ្ឋកិច្ចដោយត្រូវពិគ្រោះយោបល់ និងកំណត់ប្រកាសរួម រវាងក្រសួងសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ។[29]

---

[25] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា១៨

[26] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា១៩

[27] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២១

[28] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២២

[29] អនុក្រឹត្យស្ដីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២៤

## ២.២.សមត្ថកិច្ចរដ្ឋបាលនៃការផ្តល់សម្បទានដីសេដ្ឋកិច្ច

នៅក្នុងដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ច ក៏មិនខុសពីការធ្វើកម្រោងផ្សេងៗទៀតដែរ គឺចាំបាច់ទាមទារឲ្យមាននូវគណៈកម្មាធិការមានសមត្ថកិច្ចខាងរដ្ឋបាល គឺដើរតួយ៉ាងសំខាន់ក្នុងការពិនិត្យសម្រប សម្រួលគ្រប់គ្រងទៅលើការផ្តល់សម្បទានដីសេដ្ឋកិច្ចទាំងអស់ក្នុងប្រទេសកម្ពុជា និងទទួលខុសត្រូវក្នុងការធានាឲ្យមានការអនុវត្តន៍កិច្ចសន្យាសម្បទាននិងនីតិវិធីលក្ខខណ្ឌក្នុងកិច្ចសន្យា។ ដោយផ្អែកតាមមាត្រា ២៨ នៃអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចសមត្ថកិច្ចរដ្ឋបាលក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចមានដូចជា អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា លេខាធិការដ្ឋានបច្ចេកទេស គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ និងក្រុមប្រឹក្សាឃុំ សង្កាត់។

### ២.២.១.អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច គឺ សំដៅទៅដល់ អាជ្ញាធរមានសិទ្ធិអំណាចតាមផ្លូវច្បាប់ ក្នុងការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ក្នុងនាមជារាជរដ្ឋាភិបាលកម្ពុជាដោយអនុវត្តសិទ្ធិនេះតាមការផ្តល់សិទ្ធិប្រទានពីនាយករដ្ឋមន្ត្រី។ អាជ្ញាធរមានសមត្ថកិច្ច ក្នុងការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចមានរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ នេសាទ និងអភិបាលខេត្ត ក្រុង។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មានតួនាទី ភារៈកិច្ចផ្តួចផ្តើម និង រៀបចំឯកសារគម្រោងសម្បទានដីសេដ្ឋកិច្ច សម្រាប់ អំពាវនាវមានឲ្យមានការដាក់សំណើ ឬ អាចពិចារណាសំណើគម្រោង សម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវ និងវាយតម្លៃ និង កំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើហើយចរចាលក្ខខណ្ឌសម្រាប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនិងដាក់ឲ្យអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។ ព្រមទាំងរាយការណ៍អំពីការគ្រប់គ្រងលើការអនុវត្តន៍កិច្ចសន្យាសម្បទានដី សេដ្ឋកិច្ច ជូនគណៈរដ្ឋមន្ត្រី ជារៀងរាល់ ០៦ (ប្រាំមួយ) ខែ ម្តង និងតាមការចាំបាច់សម្របសម្រួលប្រមូលពត៌មាននិងទិន្នន័យពីក្រសួងសេដ្ឋកិច្ចនិង ហិរញ្ញវត្ថុនិង ក្រសួងការពារជាតិចំពោះដីក្នុងតំបន់អភិវឌ្ឍន៍យោធាលើលក្ខខណ្ឌដែលត្រូវដាក់ ចូលក្នុងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។ លើសពីនេះទៅទៀតពិនិត្យយោបល់របស់លេខាធិការដ្ឋានបច្ចេកទេសអំពីសំណើកែប្រែកិច្ចសន្យាសម្បទានណាមួយ។[30]

គួរបញ្ជាក់ផងដែរថានៅក្នុងឆ្នាំ២០០៨ រាជរដ្ឋាភិបាល បានបង្កើតអនុក្រឹត្យមួយ ស្តីពីការកែសម្រួលអនុក្រឹត្យស្តីពី សម្បទានដីសេដ្ឋកិច្ច ឆ្នាំ២០០៥។ អនុក្រឹត្យនេះ បានកំណត់ដកហូតសិទ្ធិរបស់អភិបាល

[30] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣០

រាជធានី ខេត្ត ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច។ ដូច្នេះ រាល់ការផ្តល់សម្បទានដីសេដ្ឋកិច្ចទាំងអស់ អាជ្ញាធរដែលមានសមត្ថកិច្ច មានតែ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទតែមួយគត់។

**២.២.២.លេខាធិការដ្ឋានបច្ចេកទេស**

លេខាធិការដ្ឋានបច្ចេកទេស ក៏មានតួនាទីសំខាន់នៅក្នុងដំណើរការផ្តល់សម្បទានដីសេដ្ឋកិច្ចផងដែរ។ លេខាធិការដ្ឋានបច្ចេកទេស សំដៅដល់លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច។[31] សមាជិក ៨រូប នៃលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច ត្រូវបានតែងតាំងដោយនាយករដ្ឋមន្ត្រី នៅថ្ងៃទី៣០ខែមិថុនាឆ្នាំ២០០៦។[32] សម្រាប់សមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេសមានដូចខាងក្រោម ៖

- តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រធាន
- តំណាងក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ សមាជិក
- តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា សមាជិក
- តំណាងក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់ សមាជិក
- តំណាងក្រសួងមហាផ្ទៃ សមាជិក
- តំណាងក្រសួងបរិស្ថាន សមាជិក
- តំណាងក្រសួងពាណិជ្ជកម្ម សមាជិក
- សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ សមាជិក[33]

មន្ត្រីជំនាញការរបស់លេខាធិការដ្ឋានបច្ចេកទេស ត្រូវតែង តាំងដោយប្រកាសរបស់រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ តាមសំណើរបស់លេខាធិការដ្ឋាន បច្ចេកទេស លេខាធិការដ្ឋាននេះមានទីតាំងនៅក្រសួងកសិកម្មរុក្ខាប្រមាញ់ និង នេសាទ។ ហើយនាថ្ងៃទី១ ខែសីហា ឆ្នាំ២០០៦ ក្រសួងកសិកម្មរុក្ខាប្រម៉ាញ់ និងនេសាទ បានបង្កើតក្រុមជំនួយការមួយក្រុម ដែលមានសមាសភាពមន្ត្រីក្រសួងនានា ដើម្បីជួយលេខាធិការដ្ឋានបច្ចេកទេស ក្នុង ការអនុវត្តន៍ភារកិច្ចរបស់ខ្លួន។ លេខាធិការដ្ឋានបច្ចេកទេសមានតួនាទី និងភារកិច្ច រៀបចំគម្រោងដីសម្បទានសេដ្ឋកិច្ច និងរៀបចំឯកសារអំពាវនាវដាក់សំណើសម្បទានដីសេដ្ឋកិច្ច ព្រមទាំងផ្តល់អនុសាសន៍ចំពោះសំណើសម្បទានដីសេដ្ឋកិច្ចទាំងអស់ ហើយតាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច។ លើសពីនេះផ្តល់អនុសាសន៍ពីការត្រួតពិនិត្យឡើងវិញនូវសម្បទានដីដែលមាន

[31] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា២

[32] បទបង្ហាញរបស់ លោក ចាយ សាគុណ អនុប្រធានមន្ទីរផែនការ និងស្ថិតិ នៃក្រសួងកសិកម្ម រុក្ខាប្រម៉ាញ់ និងនេសាទ ដល់ក្រុការងារបច្ចេក ទេសព្រៃឈើ និងបរិស្ថាន ខែធ្នូ ឆ្នាំ២០០៦

[33] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣១

ស្រាប់។[34] និងធ្វើការណែនាំដល់ក្រុមហ៊ុននានា ក្នុងការរៀបចំធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និង សង្គម ។

### ២.២.៣. គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានទីតាំងក្នុងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង និងមានសិទ្ធិប្រើប្រាស់ត្រារបស់សាលាខេត្ត ក្រុង ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង ជាអ្នកធ្វើផែនការបែងចែកសម្រាប់ការប្រើប្រាស់ផ្សេងៗ នូវដីឯកជនរបស់រដ្ឋ ដែលបានចុះបញ្ជីរួចនៅក្នុងខេត្ត ក្រុង ហើយដែលរដ្ឋមិនទាន់បានប្រគល់ទៅឱ្យស្ថាប័ន សាធារណៈ ឬអាជ្ញាធរណាមួយកាន់កាប់នៅឡើយ ។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីជួយក្នុងកិច្ចការរដ្ឋបាល និងកិច្ចការបច្ចេកទេសមានជាអាទិ៍។ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្ត ក្រុង មានសមាសភាពដូចតទៅៈ

- អភិបាលខេត្ត ក្រុង ជាប្រធាន
- ប្រធានមន្ទីររៀបចំដែនដីនគរូបនីយកម្មនិងសំណង់និងសុរិយោដីខេត្ត ក្រុង ជាសមាជិកអចិន្ត្រៃយ៍
- មេបញ្ជាការតំបន់ប្រតិបត្តិការសឹករងខេត្ត ក្រុង ជាសមាជិក
- ស្នងការនគរបាល រាជធានី ខេត្ត ជាសមាជិក
- ប្រធានមន្ទីរសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរបរិស្ថាន ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរធនធានទឹកនិងឧតុនិយមខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរឧស្សាហកម្មរ៉ែ និងថាមពល ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរសាធារណៈការ និង ដឹកជញ្ជូន ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរវប្បធម៌ និង វិចិត្រសិល្បៈ ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរទេសចរណ៍ ខេត្ត ក្រុង ជាសមាជិក
- ប្រធានមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត ក្រុង ជាសមាជិក
- នាយខណ្ឌរដ្ឋបាលព្រៃឈើ ដែលពាក់ព័ន្ធ ខេត្ត ក្រុង ជាសមាជិក
- អគ្គលេខាធិការសាលា ខេត្ត ក្រុង ជាសមាជិក

[34] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣២

សមាសភាពដែលមានចែងខាងលើត្រូវអញ្ជើញចូលរួមប្រជុំ តាមការអញ្ជើញ របស់ប្រធាន ហើយប្រធាន គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋ ខេត្ត ក្រុង អាច អញ្ជើញតំណាងដែលពាក់ព័ន្ធផ្សេងទៀតចូលរួមជាសមាជិកតាម តម្រូវការនៃករណី នីមួយៗ។[35] ចំពោះមុខងារ និង ភារកិច្ចរបស់គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត គឺដឹកនាំក្រុមការងារថ្នាក់ ក្រុង ស្រុក ខណ្ឌ ក្នុងការធ្វើអត្តសញ្ញាណ កម្ម និង ការធ្វើផែនទីដីរដ្ឋ និងសម្របសម្រួលជាមួយក្រសួងស្ថាប័ន អាជ្ញាធរដែនដី អំពីអាណត្តិ កាន់កាប់ និង ឋានៈនៃដីរដ្ឋព្រមទាំងប្រមូល និង ចងក្រងឯកសារពត៌មាន អំពីទីតាំង ឋានៈ និង ការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋជាងនេះទៅទៀតផ្តល់មតិយោបល់ជូនក្រសួងរៀបចំដែនដី នគរូបនីយកម្ម និង សំណង់ ឬ ក្រុមប្រឹក្សា គោលនយោបាយដីធ្លី អំពីអាណត្តិកាន់កាប់ និង ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ។ ថែរក្សា និង ធ្វើចរន្តការប្រព័ន្ធទិន្នន័យ និង ផែនការដីរដ្ឋប្រចាំ ខេត្ត ក្រុង។ ហើយជាចុងក្រោយសម្រេច និង ត្រួតពិនិត្យ លើការរៀបចំផែនការសកម្មភាពប្រើប្រាស់ដីថ្នាក់ឃុំ សង្កាត់ដោយមានការចូលរួមផ្តល់មតិយោបល់លើគម្រោងដីធ្លី និងសហការតាមដានការអនុវត្តគម្រោងទាំងនោះនិងសហការក្នុងការរៀបចំពិគ្រោះយោបល់ជាសាធារណៈ លើគម្រងសម្បទានដីធ្លីព្រមទាំងលើកគម្រោងថវិការប្រចាំឆ្នាំ។[36]

### ២.២.៤. ក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ខណ្ឌ

ក្រុមការងារដីរដ្ឋថ្នាក់ក្រុង ស្រុក ខណ្ឌ ត្រូវស្ថិតនៅក្រោមការណែនាំផ្នែករដ្ឋបាល គឺ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត និង ក្រោមការណែនាំ ផ្នែកបច្ចេកទេសពីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និង សំណង់។ ចំពោះសមាសភាពនៃក្រុមការងារដីរដ្ឋ ថ្នាក់ស្រុក ខណ្ឌដូចតទៅៈ

- អភិបាលក្រុង ស្រុក ខណ្ឌ ជាប្រធាន
- ប្រធានការិយាល័យរៀបចំដែនដីនគរូបនីយកម្ម សំណង់ និង ភូមិបាលក្រុង ស្រុក ខណ្ឌ ជាសមាជិកអចិន្ត្រៃយ៍
- ប្រធានការិយាល័យជំនាញថ្នាក់ ក្រុង ស្រុក ខណ្ឌពាក់ព័ន្ធ និង នាយផ្នែករដ្ឋបាលព្រៃឈើដែលពាក់ព័ន្ធ ជាសមាជិក
- មេឃុំចៅសង្កាត់ពាក់ព័ន្ធ ក្រុង ស្រុក ខណ្ឌ ជាសមាជិក

ប្រធាន និង សមាសភាពនៃក្រុមការងារដីថ្នាក់ ក្រុង ស្រុក ខណ្ឌ ត្រូវតែងតាំងដោយអភិបាលរាជធានីខេត្ត។[37] ក្រុមការងារដីរដ្ឋថ្នាក់ ក្រុង ស្រុក ខណ្ឌ មានមុខងារ និងភារកិច្ចជាអ្នក ប្រមូល និង ចងក្រងឯកសារ

[35] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨ អនក្រ/បក ចុះថ្ងៃទី០៧ តុលា ២០០៥ មាត្រា២៤
[36] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨ អនក្រ/បក ចុះថ្ងៃទី០៧ តុលា ២០០៥ មាត្រា២៥
[37] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨ អនក្រ/បក ចុះថ្ងៃទី០៧ តុលា ២០០៥ មាត្រា២៧

ព័ត៌មានដើម្បីធ្វើអត្តសញ្ញាណកម្មនិង ធ្វើផែនទីដីរដ្ឋ ជួយសម្របសម្រួលជាមួយស្ថាប័ន អាជ្ញាធរ ឬ អ្នកកាន់កាប់ដីរដ្ឋ អំពីអាណត្តិកាន់កាប់ដីរដ្ឋ និងស្វែងរកការឯកភាពលើព្រំប្រទល់ប្រហាក់ប្រហែល ឋានៈ និងការប្រើប្រាស់បច្ចុប្បន្ននៃដីរដ្ឋ។ ធ្វើការបិទផ្សាយជាសាធារណៈនូវសំណៅព័ត៌មាន និង ផែនទី ដីរដ្ឋនៅតាមទីប្រជុំជន និង តាមឃុំ សង្កាត់ពាក់ព័ន្ធ និងទទួលមតិយោបល់ពីសារធារណៈជនតាមកាលបរិច្ឆេទ និងសង្ខេបមតិយោបល់សាធារណៈជនដែលបានទទួល និង រៀបចំទិន្នន័យ និង ឯកសារចាំបាច់ រួមទាំងផែនទីដីរដ្ឋដែលបញ្ជាក់ ព័ត៌មានទាំងអស់ ជូនគណៈកម្មាធិការដីរដ្ឋថ្នាក់រាជធានី ខេត្ត ហើយចូលរួមធ្វើផែនការប្រើប្រាស់ដីធ្លីរដ្ឋ និង ផ្តល់មតិយោបល់ក្នុង ការធ្វើចំណាត់ថ្នាក់ដីរដ្ឋឡើងវិញ ព្រមទាំងរៀបចំការពិគ្រោះយោបល់ និង ចូលរួមផ្តល់មតិយោបល់លើ គម្រោងសម្បទានដីធ្លី ព្រមទាំងសហការតាមដានការអនុវត្តន៍ កម្រោងសម្បទានដីសេដ្ឋកិច្ច ។[38]

## ២.២.៥.ក្រុមប្រឹក្សាឃុំ សង្កាត់

ដំណើរការក្រុមប្រឹក្សាឃុំ សង្កាត់ត្រូវជ្រើសរើសឡើងតាមការបោះឆ្នោត ដោយប្រជាពលរដ្ឋនៃឃុំសង្កាត់របស់ខ្លួនស្របទៅតាមនីតិវិធីដែលកំណត់ដោយច្បាប់ស្តីពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំសង្កាត់។[39] ការបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់នៅក្នុងប្រទេសកម្ពុជាចាប់ផ្តើមដំបូងដែលបានប្រព្រឹត្តទៅនៅថ្ងៃទី ០៣ ខែមិនា ឆ្នាំ២០០២ មានលេចឡើងនូវតួនាទីរបស់ក្រុមប្រឹក្សាឃុំសង្កាត់ ក្នុងការគ្រប់គ្រងដីរដ្ឋ។ ក្រុមប្រឹក្សាឃុំសង្កាត់ ជាអាជ្ញាធរនៅក្នុងរដ្ឋបាលថ្នាក់ក្រោមជាតិដើម្បីគ្រប់គ្រង ចាត់ចែង និងប្រើប្រាស់ក្នុងគោលបំណងលើកកម្ពស់ប្រសិទ្ធភាព និងគុណភាពនៃការផ្តល់សេវាសាធារណៈ និងការអភិវឌ្ឍមូលដ្ឋានឆ្លើយតបទៅនឹងតម្រូវការរបស់ប្រជាពលរដ្ឋដែលស្ថិតនៅក្នុងដែនសមត្ថកិច្ចរបស់ខ្លួន ។ តួនាទីក្រុមប្រឹក្សា សង្កាត់ ក្នុងការអភិវឌ្ឍផែនការប្រើប្រាស់ ដីធ្លីការពាក់ព័ន្ធរបស់ក្រុមប្រឹក្សាឃុំ សង្កាត់ក្នុងការ ប្រើប្រាស់ និង ការបែងចែកដីរដ្ឋនិង ការតាមដានត្រួតពិនិត្យការប្រើប្រាស់ដីរដ្ឋ ក្នុងមណ្ឌលដែនដីរបស់ខ្លួនទាំងនេះ តម្រូវឲ្យយកចិត្តទុកដាក់បន្ថែមទៀត។

ម្យ៉ាងទៀត ក្រុមប្រឹក្សាឃុំ សង្កាត់ ក៏មាន តួនាទីក្នុងការត្រួតពិនិត្យ និង ផ្តល់យោបល់ចំពោះគម្រោងនៃការធ្វើគំរោងសម្បទានដីសេដ្ឋកិច្ច ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងតំណាងប្រជាពលរដ្ឋនៅក្នុងមូលដ្ឋានក្រោយពីទទួលបានឯកសារលម្អិត នៃគម្រោងសម្បទានដី សេដ្ឋកិច្ចមានការអំពាវនាវ ឬ ឯកសារលំអិតនៃសំណើមិនការអំពាវនាវដោយបញ្ជូន ឯកសារនោះមួយច្បាប់ទៅក្រុមប្រឹក្សាឃុំសង្កាត់ដែលដីសម្បទានតាំងនៅ ដើម្បីត្រួត ពិនិត្យ និង ផ្តល់យោបល់ក្នុងរយៈពេលយ៉ាងច្រើន២៨ថ្ងៃ នៃថ្ងៃ

[38] អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ លេខ ១១៨ អនក្រ/បក ចុះថ្ងៃទី០៧ តុលា ២០០៥ មាត្រា២៨

[39] ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ លេខនស/ រកម/០៣០១/០៥ ចុះថ្ងៃទី០១ខែ កុម្ភៈ ឆ្នាំ ២០០១ មាត្រា១០

ធ្វើការដោយ គិតចាប់ពីថ្ងៃដែលក្រុមប្រឹក្សា ឃុំ សង្កាត់បានទទួលសំណៅឯកសារលំអិតនៃគម្រោងសម្បទានដីមានការអំពាវនាវ ឬឯកសារលំអិតនៃសំណើមិនមានការអំពាវនាវ ។[40] ប្រសិនបើគម្រោងសម្បទានដីសេដ្ឋកិច្ច មានផលប្រយោជន៍ ឬមានផលប៉ះពាល់ក្រុមប្រឹក្សាឃុំសង្កាត់ពាក់ព័ន្ធអាចលើកមតិយោបល់ទៅកាន់ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ធ្វើការពិចារណាលើមតិយោបល់។ ក្នុងករណីអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា បដិសេធយោបល់ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវផ្តល់ហេតុផលច្បាស់លាស់ ។

## ២.៣.កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

ជាទូទៅកិច្ចសន្យាគឺជាកិរិយាដែលបុគ្គលពីរនាក់ ឬ ច្រើននាក់មានឆន្ទៈត្រូវគ្នាព្រម បង្កើត កែប្រែ ឬ រំលត់នូវកាតព្វកិច្ច ។[41] ដូចគ្នានេះដែរក្នុងការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចក៏ត្រូវមានកិច្ចសន្យាកិច្ចសន្យាមានសារៈសំខាន់សម្រាប់សម្បទានិក និងរដ្ឋ។ ជាវិធីមួយដើម្បីការពារចៀសវាងពីបញ្ហាផលប៉ះពាល់ក្នុងការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចត្រូវមាន ការបង្កើតកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងលក្ខខណ្ឌនៃការកាន់កាប់សម្បទានដីសេដ្ឋកិច្ច ។

ដើម្បីកាន់តែងាយស្រួលយល់ក្នុងចំណុចកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនេះ យើងខ្ញុំទាំងពីរនាក់នឹងធ្វើការពន្យល់បកស្រាយលំអិតនៅចំណុចនីមួយៗដូចនៅចំណុចបន្ទាប់ខាងក្រោម។

### ២.៣.១.ការបង្កើតកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

ជាទូទៅកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច គឺមុននឹងបង្កើតកិច្ចសន្យានេះបាន លុះត្រាតែអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវ ធ្វើការចរចាចុះកិច្ចសន្យាគម្រោងសម្បទានដីជាមុនសិន។ ការចរចានេះនឹងត្រូវប្រានចោលតែម្តងប្រសិនបើគ្មានការព្រមព្រៀង ផ្ទុយទៅវិញប្រសិនបើការចរចារវាងអាជ្ញាធរ និង បុគ្គលឯកជនទទួលបានជោគជ័យដែលអាចឈានទៅដល់ ការចុះកិច្ចសន្យានោះអាជ្ញាធរមានសមត្ថកិច្ច ចុះ កិច្ចសន្យាត្រូវចរចាធ្វើសេចក្តីព្រាងកិច្ចសន្យាសម្បទាន។ ម្យ៉ាងវិញទៀតកិច្ចសន្យាសម្បទាននីមួយៗ ត្រូវស្របទៅតាមបទបញ្ញត្តិនៃលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធ ហើយនៅក្នុងកិច្ចសន្យានេះ អាចបន្ថែមរាល់ "ខ" សន្យាដាក់លក្ខខណ្ឌ ណាដែលចាំបាច់កុំឲ្យតែ "ខ" សន្យាដាក់លក្ខខណ្ឌ ដែលចែងនោះផ្ទុយនឹង បទបញ្ញត្តិដែលមានចែងក្នុងលិខិតបទដ្ឋានគតិយុត្តិ ពាក់ព័ន្ធទាក់ទងសម្បទានដីសេដ្ឋកិច្ច ក្នុងន័យនេះសម្បទានិកអាចទាញយកផលពីដី ដើម្បីជាប្រយោជន៍ផ្ទាល់ខ្លួន និង ធ្វើ អាជីវកម្មលើដីនោះ តាមវិធីណាមួយ ដែលកិច្ចសន្យាមិនបានហាមឃាត់។ សម្បទានដី សេដ្ឋកិច្ចមិនអាចប្រគល់ ឱ្យដោយឥតគិតថ្លៃនោះទេ លើកលែងតែសម្បទានដីសង្គមកិច្ច ដែល

[40] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣៥

[41] ក្រមរដ្ឋប្បវេណីនៃព្រះរាណាចក្រកម្ពុជា , លេខ នស/រកម/១២០៧/០៣០, ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ មាត្រា៣១១

ឆ្លើយតបទៅនិងប្រយោជន៍ សង្គម ដែលប្រគល់ឱ្យគ្រួសារជនក្រីក្រ សម្រាប់តាំងទីលំនៅ និងដាំដំណាំចិញ្ចឹមជីវិត។[42]

សម្បទានិកមានសិទ្ធិប្រើប្រាស់ ដីសម្បទានដីសេដ្ឋកិច្ច មិនត្រូវមានរយៈពេលលើសពី៥០ (ហាសិប) ឆ្នាំឡើយ។[43] ការបង្កើតកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចអាចបន្តសាជាថ្មីបាន ប៉ុន្តែ អំឡុងពេលបន្តសាជាថ្មីមិនអាចលើស ពី ៥០ (ហាសិប) ឆ្នាំឡើយ គិតចាប់ពីថ្ងៃដែលបានបន្តសាជាថ្មី។ ការស្នើសុំធ្វើការវិនិយោគបន្តទៅទៀតអាចធ្វើទៅបាន តែក្នុងករណីមានគោលការណ៍អនុញ្ញាតពីរាជរដ្ឋាភិបាលកម្ពុជា។ ប្រសិនបើការបង្កើតកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចរួចដែលមានអំឡុងពេល លើសពី ៥០(ហាសិប) ឆ្នាំ ត្រូវបន្ថយមកត្រឹម ៥០ (ហាសិប) ឆ្នាំ ហើយត្រូវធ្វើក្នុងអំឡុងពេលដែលបានកំណត់ ដោយការព្រមព្រៀងភាគីទាំងពីរបានឯកភាពគ្នាដែរ។ សម្រាប់ទំហំសម្បទានដីសេដ្ឋកិច្ច អាចមានទំហំច្រើនបំផុតត្រឹមតែ ១០.០០០ (មួយម៉ឺន) ហិកតា ហើយសម្រាប់សម្បទានដីសេដ្ឋកិច្ចដែលសម្រេចហើយ មានទំហំលើសពី ១០.០០០ (មួយម៉ឺន) ហិកតាត្រូវធ្វើការកាត់បន្ថយ។[44] ប្រសិនបើការកាត់បន្ថយ មានឥទ្ធិពលធ្វើឱ្យខូចប្រយោជន៍អាជីវកម្ម ដែលកំពុងមានដំណើរការសម្បទានិក អាចនឹងទទួលបានការលើកលែងចំពោះការកាត់បន្ថយនេះ។

ដូច្នេះក្នុងដំណើរការកាត់បន្ថយដីសម្បទានដីសេដ្ឋកិច្ចរដ្ឋត្រូវត្រួតពិនិត្យមើលចំពោះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ហើយនៅមានសុពលភាពដែលបានផ្តល់ឱ្យមុនអនុក្រឹត្យស្តីសម្បទានដីសេដ្ឋកិច្ច និងច្បាប់ភូមិបាលចូលជាធរមានចាំបាច់ត្រូវដោះស្រាយប្រពន្ធ័សម្បទានដីសេដ្ឋកិច្ចចាស់ទាំងមូល ត្រូវដាក់ឱ្យស្ថិតនៅក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងថ្មីដោយសង្កត់ធ្ងន់លើការបង្កើតការងារធ្វើយកចិត្តទុកដាក់ ចំពោះការកាន់កាប់ដីទាំងឡាយដែលស្ថិតនៅជុំវិញតំបន់សម្បទាន និង ចំពោះផលប៉ះពាល់ ផ្នែកបរិស្ថាន និងសង្គមរបស់សម្បទាន។ ការពិនិត្យឡើងវិញនេះគួរត្រូវបានធ្វើឡើងក្រោមការគាំទ្រនៃលេខាធិការដ្ឋានបច្ចេកទេសសម្បទានដីសេដ្ឋកិច្ច ដែលរៀបចំឡើងក្រោមការឧបត្ថម្ភគាំទ្រក្រុមប្រឹក្សាគោលនយោបាយដីធ្លីស្ថិតនៅ និងដឹកនាំដោយក្រសួងកសិកម្មរុក្ខាប្រមាញ់ និងនេសាទ ។ លេខាធិការដ្ឋានបច្ចេកទេសនេះត្រូវមានតំណាងមក ពីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងរៀបចំដែនដី នគររូបនីបយកម្ម និងសំណង់ ក្រសួង សេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងពាណិជ្ជកម្ម និងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា។ លេខាធិការដ្ឋានបច្ចេកទេសត្រូវបង្កើតសៀវភៅកត់ត្រាសម្បទានសេដ្ឋកិច្ចក្នុងរយៈពេល ៩០ (កៅសិប) ថ្ងៃ បន្ទាប់ពីមានសេចក្តីសម្រេចតែងតាំង និងត្រូវជូនដំណឹងរយៈពេល ៣០ (សាមសិប) ថ្ងៃ ដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដី ទាំងឡាយដែលបានចុះកិច្ចសន្យា

---

[42] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៥១

[43] ច្បាប់ស្តីពីការគ្រប់គ្រងការប្រើប្រាស់និងចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, លេខ នស/រកម/១១២០/០៣០, មាត្រា៥៣

[44] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៥៩

សម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនសម្បទានទាំងអស់ឱ្យបានទូលំទូលាយ។ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ឬ សម្បទានិកទាំងអស់ ត្រូវទទួលខុសត្រូវផ្តល់ព័ត៌មាន និងឯកសារថតចំលងដែលពាក់ព័ន្ធ ដល់លេខាធិការដ្ឋានបច្ចេកទេសក្នុង រយៈពេល ០៦ (ប្រាំមួយ) ខែ បន្ទាប់ពីការជូនដំណឹងឬ ការផ្សព្វផ្សាយសេចក្តីជូនដំណឹងដើម្បីចុះក្នុងសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ។[45]

ម្យ៉ាងទៀតដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេទេស ក្រសួង ស្ថាប័ន ឬ អាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ត្រូវអនុវត្តនូវជំហានត្រួតពិនិត្យឡើងវិញតាមស្ថានភាពនីមួយៗ ទៅលើការអនុវត្តន៍របស់សម្បទានិក ដោយផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យាជាធរមាន ដោយពិចារណាលើកម្រិតនៃការវិនិយោគ ដែលបានធ្វើរួច និងដែលត្រូវធ្វើបន្តទៀត ។ ពិនិត្យប្រាក់ចំណូល និងថ្លៃ ប្រើប្រាស់ដីតាមកិច្ចសន្យាសម្បទាន តើបានបង់គ្រប់ចំនួនដែរឬទេ ។ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បី ប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ចនៅឃុំ សង្កាត់ដែលដីសម្បទាននោះតាំងនៅដើម្បីធ្វើការពិចារណា និងដាក់ជូនអាជ្ញាធរមានសមត្ថកិច្ចសន្យាពិនិត្យនិងសម្រេច ។ ប្រសិនបើសម្បទានិកម្នាក់កាន់កាប់ដី សម្បទានសរុបលើសពី១០.០០០ (មួយម៉ឺន) ហិចតា ត្រូវស្នើឱ្យសម្បទានិកនោះស្ម័គ្រចិត្តកាត់ដីដែលលើសជូនរដ្ឋ វិញ ឬប្រសិនបើសម្បទានិកមិនស្ម័គ្រចិត្តកាត់បន្ថយដីសម្បទាននោះទេ ត្រូវព្យាយាមចរចាលើការកាត់បន្ថយ ។[46] ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ត្រូវធ្វើនិយ័តកម្មដីក្នុងតំបន់ដី សម្បទានដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ ។ ការធ្វើនិយ័តកម្មដី មានរាប់បញ្ចូលការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដីក្នុងតំបន់ត្រួតពិនិត្យឡើងវិញនិង ការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន។[47] លេខាធិការដ្ឋានបច្ចេកទេសក្រោយត្រួតពិនិត្យត្រូវផ្តល់យោបល់លើសេចក្តីព្រាង របាយការណ៍ត្រួតពិនិត្យឡើងវិញនីមួយៗ ជូនទៅក្រសួង ស្ថាប័ន ឬ អាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវបញ្ជាក់ពីកិច្ចសន្យានោះកំពុងដំណើរការដោយពេញលេញ ឬគួរកែប្រែលើចំណុចជាក់លាក់ ដោយបញ្ជាក់ អំពីកិច្ចការដែលត្រូវបំពេញ ដោយភាគីនៃកិច្ចសន្យាដើម្បីទទួលយកបានទាំងសងខាង ឬគួរលុបចោលកិច្ចសន្យា នោះដោយមូលហេតុសម្បទានិកបានបំពានលើកិច្ចសន្យា ។ ចំពោះដីសម្បទានលើសពី ១០.០០០ (មួយម៉ឺន) ហិកតាត្រូវបញ្ជាក់អំពីការស្ម័គ្រចិត្តកាត់បន្ថយទំហំដីដោយសម្បទានិក ឬត្រូវធ្វើការចរចាដើម្បីកាត់បន្ថយ ឬ ហេតុផលចាំបាច់សម្រាប់ការលើកលែងការកាត់បន្ថយដីសម្បទាន ការជ្រើសរើសដីសម្រាប់កាត់បន្ថយ ត្រូវបញ្ចូលផ្អែក

---

45 អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣៦

46 អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣៧

47 អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៤២

ដែលមានទំនាស់ ផ្នែកដែលមិនទាន់កាប់ឆ្ការ ផ្នែកដែលមិនទាន់បានអភិវឌ្ឍ និងផ្នែកដែលជាដី សាធារណៈរបស់រដ្ឋ ។[48] សម្រាប់របាយការណ៍ត្រួតពិនិត្យ និង អនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស និងលទ្ធផលចុងក្រោយ នៃការត្រួតពិនិត្យឡើងវិញលើសម្បទានីមួយៗ ត្រូវរក្សាទុកជាឯកសារសាធារណៈនៅលេខាធិការដ្ឋានបច្ចេកទេស និងនៅគណកម្មាធិការគ្រប់គ្រង់ដីរដ្ឋថ្នាក់ខេត្ត ក្រុង។[49]

នៅក្នុងរយៈពេល ០៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹង ស្តីពីការបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវដាក់របាយការណ៍ជូនគណៈរដ្ឋមន្ត្រីដោយមានភ្ជាប់យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស ទាក់ទងនឹងការត្រួតពិនិត្យឡើងវិញនូវ សម្បទានដីសេដ្ឋកិច្ចដែលខ្លួនបានចុះកិច្ចសន្យា ហើយបន្ទាប់មកទៀត របាយការណ៍នេះត្រូវធ្វើឡើងទៀងទាត់ រៀងរាល់ ០៦ (ប្រាំមួយ) ខែម្តង នៅក្នុងអំឡុងពេល និងក្រោយពេលបញ្ចប់ការត្រួតពិនិត្យឡើងវិញក្រសួងស្ថាប័នឬអាជ្ញាធរដែនដី ដែលបានចុះកិច្ចសន្យា ត្រូវបន្តការតាមដានការអនុវត្តកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា និងមិនត្រូវលុបចោល ឬមានបញ្ហាឱ្យផ្អាកដំណើរការ ហើយរាយការណ៍អំពីការអនុវត្តកិច្ចសន្យាសម្បទានដី សេដ្ឋកិច្ចលើកលែងតែមានសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីផ្ទុយពីនេះ។[50]

នីតិវិធីសម្រាប់ការកាត់បន្ថយទំហំដីសម្បទានដែលមានស្រាប់ដោយស្ម័គ្រ ឬ ដោយការចរចាក្រសួងស្ថាប័ន ឬ អាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ត្រូវស្នើឱ្យសម្បទានិកស្ម័គ្រចិត្ត ជ្រើសរើស ចំណែកណាមួយនៃដីសម្បទានបង្វិលជូនរដ្ឋវិញ ។ ប្រសិនបើសម្បទានិកមិនមានឆន្ទៈស្ម័គ្រចិត្តកាត់បន្ថយទំហំដី សម្បទាននោះទេ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវអញ្ជើញសម្បទានិកនោះមកចរចាអំពីផែនការប្រើប្រាស់ដីសម្បទាន ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេទេស។ ប្រសិនបើការចរចា មិនសម្រេចបានជោគជ័យ នៅក្នុងអំឡុងពេល ០៦ (ប្រាំមួយ) ខែ គិតពីថ្ងៃផ្តើមការចរចាក្រសួង ស្ថាប័ន ឬ អាជ្ញាធរដែនដី ដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវរាយការណ៍ជូនទៅ ទីស្តីការគណៈរដ្ឋមន្ត្រីតាមរយៈលេខាធិការដ្ឋានបច្ចេកទេស។ ប្រសិនបើសម្បទានិកខកខានមិនបានចូលមកចរចាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលលិខិតអញ្ជើញមកចរចាត្រូវបានបញ្ជូនដល់អាសយដ្ឋាន ឬដល់ដៃសម្បទានិក ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលបានចុះកិច្ចសន្យាសម្បទានត្រូវរាយការណ៍ជូនគណៈរដ្ឋមន្ត្រីដើម្បីមានវិធានការ ។[51] គណៈរដ្ឋមន្ត្រីមានសិទ្ធិលើកលែងការកាត់បន្ថយការកាន់កាប់សម្បទានដី

[48] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៤០

[49] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៤១

[50] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣៧

[51] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣៨

សេដ្ឋកិច្ច ដែលមានទំហំសរុបលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ក្នុងករណីដី សម្បទាននោះត្រូវផ្ដល់ឱ្យមុនពេលច្បាប់ភូមិបាលឆ្នាំ២០០១ ចូលជាធរមាននិងការកាត់បន្ថយដីសម្បទាននោះនាំឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការនៅពេលដែល ច្បាប់ភូមិបាលចូលជាធរមាន ។ ការកាប់ឆ្ការដើមឈើ ឬ ដុតព្រៃសំអាតដីមិនត្រូវបានចាត់ទុកជាអាជីកម្មកំពុង ដំណើរការ ឬ ជាការបំពេញតាមលក្ខខណ្ឌនៃការ អភិវឌ្ឍន៍ដីដែលចែងក្នុងកិច្ចសន្យាឡើយ ។[52] សម្បទានិកមិនអាចកែប្រែដីតាមនីតិវិធីដែលនាំ ឲ្យដីនោះមិនអាចយកមកប្រើប្រាស់វិញបាន ឬ អាចធ្វើអាជីវកម្មដែលបំផ្លាញដល់ រចនាសម្ព័ន្ធ ធម្មជាតិ ឬ តាមនីតិវិធីដែលជាការបំផ្លាញនៅចុងបញ្ចប់នៃសម្បទានបានឡើយ ។

### ២.៣.២.លក្ខខណ្ឌនៃការកាន់កាប់សម្បទានដីសេដ្ឋកិច្ច

ជាទូទៅនៅពេលសម្បទានិក ទទួលបានសម្បទានដីសេដ្ឋកិច្ចរួចហើយត្រូវតែទៅចុះបញ្ជីនៅក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ដូចមានចែងក្នុងមាត្រា៥៣នៃច្បាប់ភូមិបាល ឆ្នាំ២០០១។ សម្បទានិកត្រូវទៅធ្វើលេខាចារឹក នៅប័ណ្ណសម្គាល់សិទ្ធិកាន់កាប់អចលនវត្ថុ ឬលើវិញ្ញាបនប័ត្រសម្គាល់ ម្ចាស់អចលនវត្ថុសម្រាប់សម្បទាន។ ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់ ត្រូវចេញវិញ្ញាបនប័ត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច។ ក្រោយពីការទទួលបានសម្បទានដី ក៏ដូចជាការចុះហត្ថលេខាលើ កិច្ចសន្យាសម្បទានរួចរាល់ហើយ មិនមែនមានន័យថាសម្បទានិកអាចធ្វើអ្វីទៅតាមការនឹក ឃើញ ឬ បំណងរបស់ខ្លួនចំពោះដីសម្បទាននោះទេ មានន័យថា សម្បទានិកត្រូវ គោរពតាមលក្ខខណ្ឌកាន់កាប់ដែលច្បាប់ភូមិបាល និងច្បាប់នានាបានបញ្ញត្តិ ជាក់ស្តែង។ លក្ខខណ្ឌនៃការកាន់កាប់បានដាក់កំហិតដល់សម្បទានិកឲ្យធ្វើសកម្មភាពអាជីវកម្មរបស់ខ្លួនបន្ទាប់ពីការផ្តល់ដីសម្បទាន ក្នុងករណីមានការខកខានមិនបានអនុវត្តន៍នូវអ្វីដូច ដែលបានកំណត់ទេ ដូច្នេះ នាំឲ្យ សម្បទានដីដែលផ្តល់ឲ្យនោះនឹងធ្វើការដកហូតមកវិញជាស្វ័យប្រវត្តិ។ រាល់សម្បទានដីសម្រាប់ដំណាំឧស្សាហកម្ម ត្រូវចាប់ផ្តើមធ្វើអាជីវកម្មក្នុងរយៈពេល ១២ (ដប់ពីរ) ខែ បន្ទាប់ពីការផ្តល់សម្បទាន បើមិនដូច្នោះទេ នឹងត្រូវទុកជាមោឃៈ ។ ការខកខានធ្វើអាជីវកម្មរយៈពេលលើសពី ១២ (ដប់ពីរ) ខែ នាំឱ្យមានមោឃភាពសម្បទាន ប្រសិន បើការខកខាននោះ ពុំមានមូលហេតុត្រឹមត្រូវ ។ សម្បទានដីដែលបានផ្តល់ឱ្យមុនច្បាប់នេះចូលជាធរមាន ហើយមិនបានធ្វើអាជីវកម្មចាប់ពី ១២ (ដប់ពីរ) ខែ ឡើងទៅគិតពីថ្ងៃដែលច្បាប់ភូមិបាលចូលជាធរមាន ត្រូវទុកជាមោឃៈ ប្រសិនបើការខកខានមិនបាន ធ្វើអាជីវកម្មនោះ ពុំមានមូលហេតុត្រឹមត្រូវ ។[53]ប៉ុន្តែមាន ករណីលើកលែងប្រសិនបើសម្បទានមានហេតុផលត្រឹមត្រូវ ដែលអាចឲ្យបន្តកាន់ កាប់សម្បទានដីនោះទៀត។ លក្ខខណ្ឌមួយទៀតដែលតម្រូវឲ្យសម្បទានិកធ្វើដែរនោះគឺ សម្បទានិកត្រូវ

[52] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥, មាត្រា៣៩

[53] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៦២

បំពេញតាមសៀវភៅបន្ទុកបើមិនដូច្នេះទេ ក៏នាំឲ្យមានការដកហូតផងដែរ។ ក្នុងករណីនៃការដកហូតសម្បទាន ទោះជាមានមូលហេតុអ្វីក៏ដោយសម្បទានិកគ្មានសិទ្ធិទារសំណងនៃការខូតខាតណាមួយឡើយ ។

ប្រសិនបើសម្បទានិកទទួលមរណៈភាពវិញ កិច្ចសន្យាអាចបន្តទៅឱ្យទាយាទរបស់សម្បទានិកបានប្រសិនបើទាយាទមានបំណងចង់បន្តកិច្ចសន្យានោះ ទាយាទរបស់មតកជន អាចបន្តសិទ្ធិក្នុងកិច្ចសន្យាជួល ឬ សម្បទានដី បានត្រឹមតែក្នុងរយៈពេលនៃសម្បទានដីដែលនៅសល់ក្នុងកិច្ចសន្យាសម្បទានដីតែប៉ុណ្ណោះ។ ការផ្ទេរដីសម្បទានមិនអាចធ្វើឡើងតាមរយៈការផ្ទេរសិទ្ធិបានឡើយ ។ ការផ្ទេរដីសម្បទានអាចធ្វើឡើងតែក្នុងករណីការបង្កើតកិច្ចសន្យាថ្មីនៃសម្បទានដោយអាជ្ញាធរមានសមត្ថកិច្ច និងជាគុណប្រយោជន៍ដល់អ្នកទទួលសិទ្ធិសម្បទានថ្មី។ រូបវន្តបុគ្គល ឬនីតិបុគ្គល ឬក្រុមមនុស្ស ដែលបានទទួលការអនុញ្ញាតឱ្យជួលដីពីរដ្ឋ អាចជួលបន្តទៅ ឱ្យតតីយជនបាន បើមានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចជាមុន។[54] សម្បទានិកអាចផ្ទេរទៅឱ្យឧត្តការីជនរបស់ជនបានដែលហៅថាឧត្តការីជនស្របច្បាប់ គឺជាបុគ្គលទាំងឡាយដែលសម្បទាននិកប្រគល់ឱ្យស្នងកេរមរតករបស់ខ្លួននៅចំពោះមុខច្បាប់ ឬបុគ្គលដែលទទួលស្គាល់ជាញាតិពន្ធ។ ការប្រកាសជូនដំណឹងស្ដីពីរការផ្ទេរ ឬសម្រេចណាមួយទៅឱ្យឧត្តការីជនត្រូវជូនដំណឹងទៅអាជ្ញាធរមានសមត្ថកិច្ចចុះ កិច្ចសន្យាយ៉ាងតិច ៦ (ប្រាំមួយ) ខែ មុនពេលចាប់ផ្ដើមអនុវត្ត។ សម្បទានិកអាចផ្ទេរកិច្ចសន្យា សម្បទានដីសេដ្ឋកិច្ច ឬជួលបន្ត លុះត្រាតែអនុវត្តតាមច្បាប់វិនិយោគនៃព្រះរាជាណាចក្រកម្ពុជា និង មានការយល់ ព្រមពីក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជាតាមសំណើរបស់អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា។[55] ដោយឡែកប្រសិនបើទាយាទមិនមានបំណងចង់បន្តកិច្ចសន្យានេះទេជាហេតុនាំ ឱ្យកិច្ចសន្យាជួលនោះនឹងលែងអនុវត្តទៀតហើយ។ កិច្ចសន្យានឹងក្លាយទៅជាកិច្ចសន្យាដែលគ្មាន ប្រសិទ្ធិភាព។ មានន័យថាក្នុងការផ្ទេរការប្រើប្រាស់ដី សម្បទានទៅឱ្យទាយាទស្របច្បាប់របស់សម្បទានិកបានក្នុងករណីដែលសម្បទានិកទទួលមរណភាពហើយ ទាយាទមានបំណងបន្តការប្រើប្រាស់សិទ្ធិ នោះដោយខ្លួនឯងក្នុងរយៈពេលសម្បទានដែលនៅសល់។ តែបើទាយាទមិនមានបំណងបន្តការប្រើប្រាស់ដី និងកាន់កាប់ដីនោះទេគេអាចបង្វែរដីនោះ ទៅរដ្ឋវិញបាន ។

សម្បទានដី ត្រូវបានដកហូតវិញដោយសេចក្ដីសំរេចខាងរដ្ឋបាល ក្នុងករណីលក្ខខណ្ឌច្បាប់មិនត្រូវបានគោរព។ ករណីនេះសម្បទានិកមានសិទ្ធិប្ដឹងទៅតុលាការ តាមនីតិវិធីដែលច្បាប់បានកំណត់ ។ សម្បទាន

[54] អនុក្រឹត្យស្ដីពីការដាក់បញ្ញាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/ បក, ២៩ សីហា ២០០៧, មាត្រា៨

[55] កិច្ចសន្យា រវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន SOPHEAK NIKA ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥

ដីអាចត្រូវបានទុកជាមោឃៈដោយតុលាការ កាលបើសម្បទានិក មិនគោរពខដោយឡែក ដែលមានចែងក្នុងកិច្ចសន្យា។[56]

## ២.៤.ការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

ការអនុវត្តកិច្ចសន្យាមានសារៈសំខាន់ណាស់ សម្រាប់សម្បទានិក និងរដ្ឋ ក្នុងការផ្តល់ សម្បទានដីសេដ្ឋកិច្ច។ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច គឺ ជាកិច្ចសន្យាដែលរាជរដ្ឋាភិបាលបានចុះ ហត្ថលេខានៅលើកិច្ចសន្យាជាមួយរូបវ័នបុគ្គល ឬ តំណាងនីតិបុគ្គលដើម្បីផ្តល់ សម្បទានដីសេដ្ឋកិច្ចប្រើប្រាស់សម្រាប់អាជីវកម្មកសិកម្ម និង កសិឧស្សាហកម្ម។ នៅក្នុងការអនុវត្តកិច្ចសន្យា ភាគីនៃកិច្ចសន្យាត្រូវតែ អនុវត្តសិទ្ធិ និងកាតព្វកិច្ចរបស់ខ្លួន ស្របទៅតាមខ្លឹមសារនៃកិច្ចសន្យា និងគោលការណ៍សុច្ចរិត ភាពនិងភាពស្មោះត្រង់ ព្រមទាំងមិនផ្ទុយនឹងបទប្បញ្ញត្តិច្បាប់ជាធរមាន ឬផ្ទុយនឹងសណ្តាប់ធ្នាប់ សាធារណៈ និងប្រពៃណីទំនៀមទម្លាប់ដ៏ល្អ។

លើសពីនេះអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវទទួលខុសត្រូវការធានាឲ្យមានការ អនុវត្តកិច្ចសន្យាសម្បទានដោយបង្កើតយន្តការ និង នីតិវិធីសម្រាប់ត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និង រាយការណ៍ជាប្រចាំអំពីការគ្រប់គ្រងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុផ្តល់ព័ត៌មាន ដល់លេខាដ្ឋានបច្ចេកទេស ឬ គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់រាជធានី ខេត្ត ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវសហការជាមួយក្រសួងស្ថាប័នពាក់ព័ន្ធដើម្បីត្រួតពិនិត្យលើការអនុវត្តន៍កិច្ចសន្យាសម្បទានរបស់សម្បទានិក និងទទួលព័ត៌មានពីសម្បទានិក និង ពីក្រសួងស្ថាប័នពាក់ព័ន្ធទាក់ទងនឹងការអនុវត្តកិច្ចសន្យា សម្បទាន។[57] ហើយមុននឹងធ្វើការកែប្រែកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីចុះកិច្ចសន្យា ដោយអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន ។[58]

នៅក្នុងការអនុវត្តកិច្ចសន្យា គឺភាគីនីមួយៗតែងតែ មានសិទ្ធិ និងកាតព្វកិច្ចរៀងៗខ្លួន អាស្រ័យទៅតាមការកំណត់នៅក្នុងកិច្ចសន្យា ។ ដូចគ្នានេះផងដែរ នៅក្នុងការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ក៏អាស្រ័យទៅលើកិច្ចសន្យាដែលភាគីនៃ កិច្ចសន្យាបានព្រមព្រៀងហើយបានបង្កើតនូវ សិទ្ធិជាកាតព្វកិច្ចសម្បទានិក និង អនុភាពបុព្វសិទ្ធិរបស់រដ្ឋរៀងៗខ្លួនស្របតាមកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងបទប្បញ្ញត្តិច្បាប់ជាធរមាន។

---

[56] ច្បាប់ភូមិបាល, លេខ នស/រកម/០៨០១/១៤, ៣០ សីហា ២០០១, មាត្រា៥៥

[57] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥ មាត្រា២៥

[58] អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥ មាត្រា២៥

### ២.៤.១.សិទ្ធិជាកាតព្វកិច្ចសម្បទានិក

ជាទូទៅនៅពេលផ្តល់សម្បទានដីសេដ្ឋកិច្ចទៅសម្បទានិក ក៏ត្រូវការផ្តល់សិទ្ធិជាកាតព្វកិច្ចឱ្យសម្បទានិកដើម្បីអនុវត្តដែរ។ ជាការចាំបាច់ណាស់ក្នុងការអនុវត្តគម្រោងសម្បទានដីសេដ្ឋកិច្ចដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាផ្តល់ឱ្យសិទ្ធសម្បទានិក មានសិទ្ធិក្នុងការរៀបចំ និងគ្រប់គ្រងនៅក្នុងទីតាំងដីសម្បទាននោះ ត្រឹមកំឡុងពេលដែលបានកំណត់ គឺទទួលបានតាមការកំណត់នៅក្នុងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចដែលស្របតាមបទប្បញ្ញត្តិច្បាប់និងអនុក្រឹត្យជាធរមាន។

ជាគោលការណ៍ក្នុងការអនុវត្តសិទ្ធិរបស់សម្បទានិកនៅក្នុងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច គឺមានត្រឹមតែសិទ្ធិប្រើប្រាស់ដីនិងអាស្រ័យផលប៉ុណ្ណោះមិនអាចឱ្យសម្បទានិកទទួលបាននូវសិទ្ធិជាកម្មសិទ្ធិទេ។ មានន័យថាសិទ្ធិរបស់សម្បទានិកលើដីដែលបានផ្តល់ជាសម្បទានក្នុងកំឡុងពេល នៃសម្បទានគឺជាសិទ្ធិដែលទទួលស្គាល់ដូចជាកម្មសិទ្ធិករ ទាស់ត្រង់ថាកម្មសិទ្ធិករមានសិទ្ធិបីគឺ សិទ្ធិប្រើប្រាស់ សិទ្ធិអាស្រ័យផល និង សិទ្ធិចាត់ចែង ដែល សិទ្ធិនេះអនុញ្ញាតឲ្យកម្មសិទ្ធិករមាន ប៉ុន្តែសិទ្ធិចាត់ចែង លក់ដូរ ឬផ្ទេរសិទ្ធិនេះមិនបានផ្តល់ឲ្យសម្បទានិកទេ។ សម្បទានិកមានសិទ្ធិជាពិសេសក្នុងការការពារស្ថានភាពរបស់ខ្លួន ដោយអាជ្ញាធរមានសមត្ថកិច្ច។ សម្បទានិកអាចការពារដីដែលបានផ្តល់ជាសម្បទានឱ្យខ្លួនពីការរំលោភបំពានរបស់អ្នកដទៃចំពោះការទន្ទ្រាន ឬការប៉ះពាល់ទោះជា តាមរូបភាពណាក៏ដោយ ហើយការការពារត្រូវស្រមតាមផ្លូវច្បាប់។ សម្បទានិកមិនត្រូវប្រើប្រាស់សិទ្ធិនេះឲ្យហួសព្រំដែនដែលកំណត់នៅក្នុងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនោះទេ។ មានន័យថាព្រំដែននៃសិទ្ធិរបស់សម្បទានិកគឺមានត្រឹមតែអ្វីដែលកំណត់នៅ ក្នុងកិច្ចសន្យាសេដ្ឋកិច្ចនៃការប្រើប្រាស់ដីប៉ុណ្ណោះ។

រាល់អចលនទ្រព្យ និង ហេដ្ឋារចនាសម្ព័ន្ធព្រមទាំងសមិទ្ធិផលទាំងអស់ដែលបង្កើតឡើងដោយសម្បទានិកត្រូវស្ថិត នៅក្រោមការគ្រប់គ្រងរបស់សម្បទានិករហូតផុតសុពលភាពនៃកិច្ចសន្យា។ សម្បទានិកអាចទាញយកនូវផលិតផលពីដីរបស់ខ្លួន ធ្វើការរៀបចំ ដាំដុះ ស្របតាមគោលបំណងនៃ សម្បទាន។ សម្បទានិកត្រូវធ្វើផែនការគ្រប់គ្រងនិង អភិវឌ្ឍន៍ទីតាំងឱ្យបានយ៉ាងយូរ ៦ (ប្រាំមួយ) ខែ ក្រោយពីថ្ងៃចុះកិច្ចសន្យាផែនការគ្រប់គ្រងនេះ ត្រូវមានផែន ការនៃការអភិវឌ្ឍន៍ យុទ្ធសាស្ត្រ កម្មវិធីការប្រើប្រាស់ទីតាំង ការប្រើប្រាស់បច្ចេកទេសផ្សេងៗ និងតុល្យភាពនៃ ផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុក្នុងកិច្ចការអភិវឌ្ឍន៍រយៈពេលវែង ។ សម្បទានិកមានសិទ្ធិជ្រើសរើសកម្លាំងពលកម្ម ឬ អ្នកឯកទេសក្នុងប្រទេសដើម្បីជួយណែនាំឬបង្ហាត់បង្ហាញអំពីការងារ បច្ចេកទេសអាជីវកម្មផលិតកម្មតាមសេចក្តីត្រូវការចាំបាច់របស់ខ្លួនដោយគោរពតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ។ ក្នុងករណីគ្មានអ្នកឯកទេសខ្មែរទើបមានសិទ្ធិជួលអ្នកឯកទេសបរទេស ។ សម្បទានិកត្រូវយកចិត្តទុកដាក់ចំពោះជីវភាពរស់នៅក៏ដូចជាសុខភាព និង ការអប់រំដល់បុគ្គលិក កម្មករ និងគ្រួសារ

របស់គេ ដោយកសាងលំនៅដ្ឋាន មន្ទីរពេទ្យ វត្តអារាម សាលារៀន មណ្ឌលកំសាន្តលំហែកាយសម្រាប់ពួកគេឲ្យបានសមរម្យ ។ សម្បទានិកមានសិទ្ធិរៀបចំធ្វើផលិតកម្ម អាជីវកម្មតាមផែនការដូចមានចែងក្នុងរបាយការណ៍បច្ចេកទេសសេដ្ឋកិច្ចរបស់ខ្លួន ដោយអនុវត្តការងារអាជីវកម្មតាមគំរោងផែនការដូចជា ការកាប់ឆ្ការព្រៃ ការធ្វើផ្លូវ និងការប្រើប្រាស់ដី ដោយត្រូវ គោរពតាមល័ក្ខខ័ណ្ឌនិរន្តរភាពធនធានធម្មជាតិរបស់ទីតាំង និង ផលប៉ះពាល់លើបរិស្ថានដែលបណ្តាលមក ពីការធ្វើអាជីវកម្ម ផលិតកម្ម ។ សម្បទានិកមានសិទ្ធិលក់ដូរប្រមូលទិញ បែងចែក ចរាចរផលិតផលគ្រប់ប្រភេទទាំងនៅក្នុង និងក្រៅប្រទេសតាមគោលការណ៍ និង ច្បាប់រដ្ឋជាធរមានក្នុងគោលដៅបម្រើឱ្យការវិនិយោគ។[59] ម្យ៉ាងទៀតសម្បទានិកមានសិទ្ធិដាក់បញ្ចាំ និងផ្ទេរសិទ្ធិលើសម្បទានដីសេដ្ឋកិច្ច សម្រាប់រយៈពេលដែលនៅសល់តែ មិនអាចលើសរយៈពេលកំណត់នៃកិច្ចសន្យាសម្បទានដី។ ហើយការដាក់បញ្ចាំក្នុងន័យនេះរាល់ការដាក់បញ្ចាំ ឬ ការផ្ទេរនូវសិទ្ធិលើសម្បទានដី មិនមែនជាការដាក់បញ្ចាំដី ឬការផ្ទេរដី ដែលអ្នកវិនិយោគបានទទួលសម្បទានដីពីរដ្ឋឡើយ ។ ចំពោះដីសម្បទានណាដែលពុំទាន់បានដំណើរការស្របតាមលក្ខខណ្ឌនៃកិច្ចសន្យា អ្នកវិនិយោគមិនអាចផ្ទេរ ឬបញ្ចាំបន្តទៀតជាដាច់ខាត ។[60] រាល់ការដាក់បញ្ចាំ ឬការផ្ទេរនូវសិទ្ធិ ត្រូវធ្វើលេខាចារឹកលើលើវិញ្ញាបនបត្រសម្គាល់សិទ្ធិសម្បទានដីសេដ្ឋកិច្ច។[61] ការដាក់បញ្ចាំសិទ្ធិសម្បទានដីសេដ្ឋកិច្ច ម្ចាស់ បំណុលមិនអាចក្លាយជាកម្មសិទ្ធិករ និងគ្មានសិទ្ធិទាមទារសិទ្ធិជាកម្មសិទ្ធិលើដី ដែលកូនបំណុល របស់ខ្លួនបានទទួលពីសម្បទានទេ ប៉ុន្តែម្ចាស់បំណុលអាចប្តឹងកូនបំណុលដែលដាក់បញ្ចាំសិទ្ធិនោះ ទៅតុលាការបាន ដើម្បីដោះស្រាយតាមនីតិវិធីច្បាប់។

លើសពីនេះទៅទៀត សម្បទានិកត្រូវមានកាតព្វកិច្ចបង់នូវប្រាក់កក់និងប្រាក់ឈ្នួលប្រចាំឆ្នាំដែលមាននៅក្នុងកិច្ចសន្យាតាមការកំណត់របស់អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ហើយថ្លៃឈ្នួលប្រចាំឆ្នាំអាចកែប្រែបានដោយផ្អែកលើគោលការណ៍របស់រាជរដ្ឋាភិបាលក្នុងរយៈពេល ០៥ (ប្រាំ) ឆ្នាំម្តង។ ក្នុងករណីដែលសម្បទានិកយឺតយ៉ាវ ក្នុងការបង់ថ្លៃឈ្នួលប្រចាំឆ្នាំអាជ្ញាធរមានសមត្ថកិច្ចត្រូវធ្វើការផាកពិន័យ ចំពោះការបង់យឺតយ៉ាវនេះ តាមការកំណត់ក្នុងកិច្ចសន្យា។ ជាទូទៅការផាកពិន័យចំពោះ ការយឺតយ៉ាវ ក្នុងការបង់ប្រាក់ឈ្នួលប្រចាំឆ្នាំ គឺ២%ក្នុង១ខែលើទឹកប្រាក់ឈ្នួលប្រចាំឆ្នាំនីមួយៗតាមចំនួនខែដែលយឺតយ៉ាវ។ ចំពោះប្រាក់កក់នៅពេលដែល សម្បទានិកមិនបានចាប់ផ្តើមចុះធ្វើសកម្មភាពសិក្សា និងរៀបចំប្លង់មេដាក់ស្តែងនោះទេ កិច្ចសន្យា នឹងចាត់ទុកជានិរាករណ៍ ហើយប្រាក់កក់នោះ នឹងត្រូវបង់ចូលជាថវិការដ្ឋដោយស្វ័យប្រវត្តិ ប៉ុន្តែបើ

[59] កិច្ចសន្យា រវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន SOPHEAK NIKA ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥

[60] អនុក្រឹត្យស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/ បក, ២៩ សីហា ២០០៧, មាត្រា៣

[61] អនុក្រឹត្យស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិសម្បទានដីសេដ្ឋកិច្ច, លេខ១១៤អនក្រ/ បក, ២៩ សីហា ២០០៧, មាត្រា៦ កថាខណ្ឌ២

សម្បទានិកបានចាប់ផ្តើមចុះធ្វើសកម្មភាពសិក្សា និងរៀបចំប្លង់មេជាក់ស្តែងរួចហើយ ប្រាក់កក់ត្រូវ បង្វិលទៅសម្បទានិកនោះវិញ។ ក្រៅពីការបង់ប្រាក់កក់ និងថ្លៃឈ្នួលប្រចាំឆ្នាំ សម្បទានិកមានកាតព្វកិច្ចទទួលខុសត្រូវលើការបង់ពន្ធផ្សេងៗទៀតជូនរដ្ឋស្របតាមច្បាប់ជាធរមាន។ សម្បទានិកត្រូវអនុញ្ញាតឲ្យ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យានិងស្ថាប័នពាក់ព័ន្ធតាមដានត្រួតពិនិត្យវាយ តម្លៃសកម្មភាពរបស់ក្រុមហ៊ុនខ្លួនអំពីផលប៉ះពាល់បរិស្ថាន។ ត្រូវអនុវត្តតាមការណែនាំរបស់អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យានិងស្ថាប័នពាក់ព័ន្ធក្នុងកិច្ចការពារបរិស្ថាន។[62]

## ២.៤.២.អនុភាពបុព្វសិទ្ធិរបស់រដ្ឋ

រដ្ឋក៏មានបុព្វសិទ្ធិ សំខាន់ផងដែលនៅក្នុងការផ្តល់ដីសម្បទានសេដ្ឋកិច្ចនិងសិទ្ធិការទទួលបានប្រាក់ឈ្នួលប្រចាំឆ្នាំពីសម្បទានិក។ មុននឹងធ្វើការផ្តល់សម្បទានដីសេដ្ឋកិច្ចឱ្យទៅក្រុមហ៊ុនវិនិយោគ ដើម្បីបញ្ចៀសបញ្ហាពាក់ព័ន្ធនានានៅពេលកំពុងដំណើរអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនេះ រដ្ឋមានសិទ្ធិ ធ្វើការសិក្សាស្រាវជ្រាវ និងវាយតម្លៃយ៉ាងល្អិតល្អន់ផងដែរ ទៅលើផលប៉ះពាល់ដល់ សង្គម ដូចជា ការប៉ះពាល់ដល់លំនៅដ្ឋាននិងជីវភាពរបស់ប្រជាពលរដ្ឋ នៅក្នុងតំបន់ផ្តល់សម្បទានដីសេដ្ឋកិច្ច និងការវាយតម្លៃហេតុប៉ះពាល់ដល់បរិស្ថាន។ បើធ្វើការសិក្សានិងវាយតម្លៃឃើញថាមានការប៉ះពាល់ដល់ប្រជាពលរដ្ឋ និងបរិស្ថានរដ្ឋមិនអាចផ្តល់សម្បទានដីសេដ្ឋកិច្ចនៅក្នុងតំបន់នោះឱ្យទៅក្រុមហ៊ុនឯកជនទេ។

ក្នុងពេលដំណើរការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចរដ្ឋមានសិទ្ធិជាពិសេស ទៅលើមុខងារតួនាទីសំខាន់ជាចាំបាច់នៅក្នុងកិច្ចការងារលើការគ្រប់គ្រងតាមដាន ឃ្លាំមើលការធ្វើសកម្មភាពអនុវត្តកាតូកិច្ចរបស់សម្បទានិក ដែលតម្រូវឱ្យបំពេញគោរពតាមកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងបទប្បញ្ញត្តិច្បាប់ជាធរមានកំណត់។ រដ្ឋត្រូវចូលរួមពិនិត្យរាល់សំណើការសាងសង់ហេដ្ឋារចនាសម្ព័ន្ធផ្សេងៗដូចជា ទំនប់ប្រឡាយ ដែលឱ្យអាចមានផលប៉ះពាល់ដល់តំបន់ជុំវិញពិសេសផលប៉ះពាល់បរិស្ថាន។ ត្រូវតាមដានត្រួតពិនិត្យលើការងារបច្ចេកទេស និង កម្មវិធីផលិតកម្មអាជីវកម្មរបស់សម្បទាននិក។ រដ្ឋមានសិទ្ធិជួយអន្តរាគមន៍ទៅស្ថាប័នដែលពាក់ព័ន្ធ ដើម្បីដោះស្រាយឧប្បត្តិហេតុណាមួយដែលមានអ្នកប្រព្រឹត្តបទល្មើសរំលោភលើសិទ្ធិសម្បទានិក។

ជាទូទៅពេលដំណើរការគម្រោងវិនិយោគក្នុងតំបន់ដីសម្បទានរបស់ក្រុមហ៊ុន ប្រសិនបើមានទំនាស់ដីធ្លី កើតឡើងជាមួយប្រជាពលរដ្ឋ និងសម្បទានិកអាជ្ញាធរមានសមត្ថកិច្ចជារដ្ឋ មានសិទ្ធិបង្អកដីសម្បទាននេះទុកដើម្បីធ្វើការដោះស្រាយ ហើយរដ្ឋមានសិទ្ធិក្នុងការព្យួរការអនុវត្តកាតូកិច្ចតាមកិច្ចសន្យា សម្បទានដី

[62] កិច្ចសន្យា រវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុន SOPHEAK NIKA ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ២០០៥

សេដ្ឋកិច្ចលើផ្នែកណាមួយ ឬទាំងស្រុងនៃទីតាំងសម្បទាន សម្រាប់រយៈពេលណាមួយជាកំណត់ ដែលមាននៅក្នុងកិច្ចសន្យា។

## ២.៥.ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច

កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចត្រូវព្រមព្រៀងគ្នាចុះដោយសម្បទានិកនិងអាជ្ញាធរមាន សមត្ថកិច្ចចុះកិច្ចសន្យាដែលមានកំណត់រយៈពេលច្បាស់លាស់ស្របតាមកិច្ចសន្យា និងបទប្បញ្ញត្តិច្បាប់ជាធរមាន ។ ក្នុងការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច មានពីរទម្រង់គឺរួមមាន ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចមុនការកំណត់ និង ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចតាមការកំណត់។

### ២.៥.១.ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចមុនការកំណត់

នៅក្នុងការអនុវត្តន៍ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ទោះមិនទាន់ដល់ពេលកំណត់ក៏ដោយ ក៏កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនេះ អាចត្រូវបានបញ្ចប់បានដែរ។ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចរដ្ឋមានសិទ្ធិ បញ្ចប់កិច្ចសន្យាមុនពេលកំណត់បាន ប្រសិនបើសម្បទានិកមិនបានបំពេញឲ្យបានត្រឹមត្រូវតាមលក្ខខណ្ឌដែលបានចែងក្នុងកិច្ចសន្យា ហើយប្រព្រឹត្តសកម្មភាពផ្ទុយនឹងច្បាប់ឬអនុក្រឹត្យជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។ មានន័យថា សម្បទានិកបានធ្វើនូវទង្វើណាមួយ ដែលនាំឲ្យខូចខាតទ្រព្យ ឬ ផលប្រយោជន៍របស់រដ្ឋដូចជាមានបំណងទុច្ចរិត ទៅលើដីជួលរួមមានការយកដីដែលជួលនោះលក់ឲ្យអ្នកដទៃ ឬ បន្តំធ្វើកម្មសិទ្ធិករដីដែលជួលនោះ ឬសម្បទានិក ប្រើប្រាស់ទីតាំងសម្បទានដីសេដ្ឋកិច្ច ដើម្បីធ្វើសកម្មភាពដែលផ្ទុយ នឹងច្បាប់កម្ពុជា ដូចជាការផលិតគ្រឿងញៀន ឬស្តុកឈើដែលកាប់ខុសច្បាប់។ គឺរដ្ឋមានសិទ្ធិ ធ្វើការបញ្ចប់កិច្ចសន្យាជួលបាន ហើយសម្បទានិកត្រូវទទួលខុសត្រូវរួមបញ្ចូលទាំងការទទួលខុសត្រូវផ្នែករដ្ឋប្បវេណីនិងការទទួលខុសត្រូវផ្នែកព្រហ្មទណ្ឌ។[63]

ជាទូទៅកិច្ចសន្យាបានកំណត់យ៉ាងច្បាស់លាស់អំពីគោលបំណងនៃការប្រើប្រាស់ដី។ ការប្រើប្រាស់ណាមួយដែលមិនសមស្របទៅតាមលក្ខខណ្ឌដែលបានកំណត់ក្នុងកិច្ចសន្យាអាចបណ្តាល ឲ្យមានការដកហូតដីសម្បទាន នោះ។ ជាសំខាន់ត្រូវកត់សំគាល់ថាការដកហូតនោះអាចធ្វើទៅបានតាមរយៈសេចក្តីសម្រេចរបស់រដ្ឋាភិបាលប៉ុណ្ណោះហើយសម្បទានិក មានសិទ្ធិប្តឹងតវ៉ាចំពោះសេចក្តីសម្រេចនោះទៅតាមតុលាការ។

ម្យ៉ាងទៀតក្នុងករណីកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច បានកំណត់ពីហេតុផលមួយចំនួនច្បាស់លាស់ករណី សម្បទានិកក្ស័យធន អលទ្ធភាពក្នុងការអនុវត្តបន្ត ឬ បាត់បង់នីតិបុគ្គលដែលអនុវត្ត ដោយមូលហេតុការរំលាយក្រុមហ៊ុននោះរដ្ឋអាច បញ្ចប់កិច្ចសន្យាមុនកាលកំណត់បាន ដោយសេចក្តីសម្រេចរបស់តុលាការ

[63] អត្ថបទ "គោលនយោបាយសម្បទានដីសេដ្ឋកិច្ច" ចូលមើលថ្ងៃទី ១៤ ខែមេសា ឆ្នាំ ២០២៤

មានសមត្ថកិច្ចនៃព្រះរាជាណាចក្រកម្ពុជា។ សម្បទានិកចង់បញ្ចប់កិច្ចសន្យាជួលមុនពេលកំណត់ត្រូវជូនដំណឹង មុនយ៉ាងតិច ១ (មួយ) ខែ ឬ ២ (ពីរ) ខែ យ៉ាងយូរ។

### ២.៥.២.ការបញ្ចប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចតាមការកំណត់

កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចក៏មិនខុសគ្នាពីកិច្ចសន្យាទូទៅដែរ គឺមានការកំណត់រយៈពេលមួយច្បាស់លាស់នៅក្នុងកិច្ចសន្យាហើយដល់ពេលវេលាការកំណត់ត្រូវមកដល់ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនោះក៏ត្រូវបានបញ្ចប់ដែរ។ កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចអាចត្រូវបានបញ្ចប់តាមការកំណត់ដោយកត្តាមួយចំនួន ដូចជា ការបញ្ចប់កិច្ចសន្យាតាមការព្រមព្រៀងរវាង រដ្ឋ និង សម្បទានិកដែលមានបំណងចង់បញ្ចប់កិច្ចសន្យា ឬ កិច្ចសន្យានោះត្រូវបានបញ្ចប់ហេតុថាវត្ថុនៃការជួលនោះត្រូវទទួលរងនៃការខូចខាតឬការអន្តរាយធ្ងន់ធ្ងរណាមួយ ដែលគេមិនអាចបន្តកិច្ចសន្យានេះទៅទៀតបានទេ។ ការកំណត់រយៈពេលកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចគឺអាស្រ័យទៅលើភាគីរដ្ឋ និងភាគីសម្បទានិកអាចព្រមព្រៀងគ្នាដោយកំណត់យកថេរវេលាដែលបានកំណតពិតប្រាកដណាមួយដែលជាអាជ្ញាយុកាលដើម្បីរំលត់សិទ្ធិ និងកាតព្វកិច្ចរបស់រដ្ឋ និងសម្បទានិក ទាំងសងខាង ដូចដែលបានចែងនៅក្នុងកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចនោះ។ ហើយរយៈពេលនៃកិច្ចសន្យាជួលអាចត្រូវបាន កំណត់ឡើងដោយឆន្ទៈព្រមព្រៀងរវាងរដ្ឋ និងសម្បទានិក ថាកិច្ចសន្យាដែលត្រូវបានធ្វើហើយមានរយៈពេលមិនលើសពី៥០ឆ្នាំ និង បញ្ចប់នៅក្នុងអំឡុងពេលកំណត់មួយជាក់លាក់។ កិច្ចសន្យាត្រូវបានបញ្ចប់ ដោយស្វ័យប្រវត្តនៅពេលកាលបរិច្ឆេទ នៃការបញ្ចប់កិច្ចសន្យាជួលបានមកដល់។

## ២.៦.លទ្ធផលនៃសម្បទានដីសេដ្ឋកិច្ច

តាមស្ថិតិពីគេហទំព័ររបស់ក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទបានបង្ហាញថា ក្រុមហ៊ុនវិនិយោគដីសម្បទានសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាជាមួយក្រសួងកសិកម្មរុក្ខាប្រមាញ់និងនេសាទ គិតត្រឹមថ្ងៃទី៨ ខែមិថុនា ឆ្នាំ២០១២ មានក្រុមហ៊ុនចំនួន១១៧ វិនិយោគលើផ្ទៃដីចំនួន ១.១៨១.៥២២ ហិកតា។[64] ប៉ុន្តែនៅក្នុងរបាយការណ៍របស់អង្គការសិទ្ធិមនុស្សអាដហុកបានបង្ហាញថា ក្នុងឆ្នាំ២០១១ រដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ច សរុបប្រមាណ ២.២៧៦.៣៤៩ ហិកតា ឲ្យទៅក្រុមហ៊ុនឯកជនចំនួន ២២៥ ក្រុមហ៊ុនតាមរយៈក្រសួងកសិកម្មនិងតាមរយៈអនុក្រឹត្យ ផ្តល់ដីសម្បទានសេដ្ឋកិច្ច។ ហើយផ្ទៃដី ២ ភាគ ៣ បានកាត់ចេញពីដីការពារដោយព្រះរាជក្រឹត្យ ដែលជាតំបន់ការពារសត្វព្រៃ និងព្រៃឈើ។[65]

[64] គេហទំព័រក្រសួងកសិកម្ម: www.maff.gov.kh/elc, ២០១៥

[65] របាយការណ៍ស្តីពីសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន២០១១ របស់អង្គការអាដហុក(ខែមីនា ឆ្នាំ២០១២)

មួយវិញទៀតដោយផ្អែកលើការបូកសរុបទិន្នន័យគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ កំឡុង ឆ្នាំ១៩៩៦–២០១២ ក្រសួងកសិកម្មបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនចំនួន១១៨ ដែលមានផ្ទៃដីសរុប១.២៣២.៤៧៤ហិកតា។ ត្រឹមដើមខែមករាឆ្នាំ២០១៣ចំណុចសម្បទានដីសេដ្ឋកិច្ច នៅលើគេហទំព័ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទពុំមានបង្ហាញ ឯកសារអ្វីឡើយ។

តារាង៖ សម្បទានដីសេដ្ឋកិច្ចដែលផ្តល់ដោយក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ តាំងពីឆ្នាំ១៩៩៦ ដល់ ២០១២[66]

| ឆ្នាំ | ចំនួនសម្បទានដីសេដ្ឋកិច្ចផ្តល់ដោយក្រសួងកសិកម្ម | ទំហំផ្ទៃដី (ហ.ត) |
|---|---|---|
| ១៩៩៦ - ១៩៩៩ | ៧ | ៤៤.១២៤ |
| ២០០០ - ២០០១ | ៦ | ៤០៨.៤០៤ |
| ២០០៤ | ២ | ៦.១០០ |
| ២០០៥ | ៨ | ៦៧.៥៨០ |
| ២០០៦ | ១៦ | ១៣៦.៣៦០ |
| ២០០៧ | ០៥ | ៣២.១៨៥ |
| ២០០៨ | ១៥ | ៩៩.៩៦៨ |
| ២០០៩ | ១៦ | ១១៧.៧៨៥ |
| ២០១០ | ១៥ | ១១៧.៧៨៥ |
| ២០១១ | ២៤ | ១៨៥.៥៧៦ |
| ២០១២ | ០៤ | ១៦.៦០៧ |
| **សរុប** | **១១៨** | **១.២៣២.៤៧៤** |

ជាលទ្ធផលទទួលបានក្នុងពេលដំណើរការ សម្បទានដីសេដ្ឋកិច្ចយើងឃើញថាគោលនយោបាយសម្បទានដីនេះអាចផ្តល់ជាគុណសម្បត្តិ និង គុណវិបត្តិនៅពេលអនុវត្តហើយយើងខ្ញុំទាំងពីរនាក់និងបកស្រាយបន្ថែមឲ្យកាន់តែច្បាស់លាស់នៅចំណុចនីមួយៗដូចខាងក្រោមនេះ។

### ២.៦.១.គុណសម្បត្តិសម្បទានដីសេដ្ឋកិច្ច

ជាទូទៅជុំវិញការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចនៅកម្ពុជាគឺបានជួយការពង្រីក កសិកម្ម និងកសិ-ឧស្សាហកម្ម នឹងដើរតួសំខាន់ក្នុងការបង្កើតការងារបន្ថែម ការបង្កើនចំណូលសាធារណៈ និងរូបិយវត្ថុបរទេស។ ប្រទេសកម្ពុជាសម្រេចបានការរីកចំរើនឆាប់រហ័សនៅជនបទ និងកាត់បន្ថយបាននូវភាពក្រីក្រ

[66] អង្គការ Forest Trend, ២០១៥

ចាំបាច់ត្រូវមានខ្សែសង្វាក់បង្កើនតម្លៃទៅលើផលិតផលកសិកម្ម ត្រូវបង្កើនទិន្នផល ស្រូវ និងមានមូលដ្ឋានកសិផលសម្រាប់ធ្វើពាណិជ្ជកម្មឱ្យកាន់តែសម្បូរបែប ពង្រីកផ្ទៃដីដាំដុះដំណាំដែល មានតម្លៃខ្ពស់ និងបង្កើនផ្ទៃដីដាំដុះទៅតាមប្រព័ន្ធអេកូឡូស៊ីប្រកបដោយចីរភាព។ ដីដែលបានបរិច្ចាគសម្រាប់សម្បទានដីសេដ្ឋកិច្ចត្រូវរួមចំណែកក្នុងទិសដៅបង្កើតភាពមានការងារធ្វើនៅជនបទ ផលិតទំនិញមានតម្លៃសម្រាប់ទីផ្សារក្នុងស្រុក និង ទីផ្សារនាំចេញរួមចំណែកក្នុងការបន្ថែមតម្លៃទៅតាមខ្សែសង្វាក់បង្កើតតម្លៃ តាមរយៈការប្លែងភាព និងការតភ្ជាប់ សេវាកម្មជនបទ ដូចជា ការកែឆ្នៃ ការដឹកជញ្ជូន និងការវេចខ្ចប់ ហើយរាល់សកម្មភាពទាំងនេះនឹងបង្កើត ចំណូលសម្រាប់រដ្ឋ ។ ក្រសួងកសិកម្ម រុក្ខា ប្រមាញ់ និងនេសាទប្រមូលចំណូលរដ្ឋបាន៥លានដុល្លាអាមេរិចក្នុងមួយឆ្នាំពីសម្បទានដីសេដ្ឋកិច្ចនៅក្នុងឆ្នាំ២០១៥។ គិតត្រឹម ខែសីហា ឆ្នាំ២០២២ មាន៧២ ក្រុមហ៊ុន បានបង់ថ្លៃសម្បទានដីសេដ្ឋកិច្ចជូនរដ្ឋចំនួន ២.០៥៦.៣៨១,០៦ លានដុល្លារ ខណៈក្រុមហ៊ុនសម្បទានដីដទៃទៀតនឹងបន្តបង់រហូតដល់ចុងឆ្នាំនេះ។[67]

ត្រង់ចំណុចនេះបានធ្វើឲ្យយើងអាចដឹងថាសម្បទានដីសេដ្ឋកិច្ច ជាគោលនយោបាយមួយដែលបានបង្កើតដោយរាជរដ្ឋាភិបាលក្នុងការជួយពន្លឿនការអភិវឌ្ឍមានគុណសម្បត្តិ ចំពោះសង្គម និងចំពោះសេដ្ឋកិច្ចជាច្រើន។ ដើម្បីយល់ឲ្យស៊ីជម្រៅច្បាស់លាស់យើងខ្ញុំទាំងពីរនាក់និងធ្វើការរៀបរាប់ដូចខាងក្រោម៖

**ចំពោះសង្គម៖** នៅពេលមានការផ្តល់សម្បទានដីសេដ្ឋកិច្ចច្រើន រដ្ឋទទួលបានផលចំណេញ យ៉ាងច្រើនក្នុងការបង្កើនសេដ្ឋកិច្ចជាតិ ដែលមានជាថវិការក្នុងការជួយសង្គមដោយ ការកាត់បន្ថយភាពក្រីក្រ។ ក្រោយពីរដ្ឋាភិបាលផ្តល់គោលនយោបាយដីសម្បទានសេដ្ឋកិច្ចរួចមក បាន ធ្វើឲ្យសង្គមជាតិយើងមានការរីកចម្រើនស្របពេលជាមួយគ្នានឹង ការទទួលបានផលប្រយោជន៍ដល់សង្គម ប្រជាជន ដែលជាកោសិកានៃសង្គម ក៏ផ្តល់នូវជាប្រយោជន៍ គឺការទទួលបានជំនាញ និង ការទទួលបានលំនៅដ្ឋាន។ មិនត្រឹមតែប៉ុណ្ណោះការកាត់បន្ថយប្រជាពលរដ្ឋដែលតែងតែចូលចិត្តនិងមានបំណងធ្វើចំណាកស្រុក ដើម្បីស្វែងរកការងារធ្វើនៅឯប្រទេសជិតខាង ដោយសារបរិមាណការងារនៅក្នុងស្រុកស្រូបយកអ្នកធ្វើការនៅមានកម្រិត ឬក៏យើងហៅថាវាមិនទាន់សមស្របទៅតាមតម្រូវការទីផ្សារ។ ចាប់តាំងពីរាជរដ្ឋាភិបាលបានផ្តល់គោលនយោបាយយន្តការផ្តល់សម្បទានដីសេដ្ឋកិច្ច បានធ្វើឲ្យអ្នករស់នៅជិតតំបន់នោះ ឬ អ្នកដែលនៅឆ្ងាយពីតំបន់នោះគាត់មានការងារធ្វើ ហើយធ្វើឲ្យកម្រិត ជីវភាពធូធារ។ ពីព្រោះថាក្រុមហ៊ុនវិនិយោគ គឺត្រូវការកំលាំងពលកម្មដើម្បីដំណើរការផលិត កម្មរបស់ខ្លួន ហើយកម្មកររបស់ខ្មែរមានកំលាំងពលកម្មថោក ដូចនេះប្រជាជនខ្មែរ គឺមានអតិភាពខ្ពស់ក្នុងទទួលបានការងារ។ ប្រសិនបើ ពួកគាត់ទទួលការងារបន្ថែម ពួកគាត់ គឺអាចទទួលបាន

[67] ប្រសាសន៍របស់ឯកឧត្តម វេង សាខន រដ្ឋមន្ត្រី ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ នៅថ្ងៃទី២៥ ខែសីហា

ចំណេះដឹងពីការបង្ហាត់បង្រៀនរបស់ក្រុមហ៊ុនដែលទទួល បានសម្បទានដីសេដ្ឋកិច្ច។ បន្ថែមពីការទទួលបានការងារ ប្រជាជនអាចធ្វើការប្រកបរបរលក់ដូរចំណី អាហារនៅក្បែរទីតាំងក្រុមហ៊ុន ដែលពួកគាត់អាចរកបានចំណូលបន្ថែមទៀតផង។ ឧទាហរណ៍ ដូចជាការលក់ដូរចំណីអាហារនៅក្បែររោងចក្រជាដើម។ វាគឺជាចំណែក មួយដ៏សំខាន់នៃការផ្តល់ចំណូលចិញ្ចឹមជីវិតរបស់ប្រជាពលរដ្ឋដែលធ្វើឲ្យប្រជាពលរដ្ឋមានជីវភាពធូរធារ កាត់បន្ថយភាពក្រីក្រ ស្របទៅតាមគោលបាយរបស់រាជរដ្ឋាភិបាល ដែលជាត្រីវិស័យដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិឲ្យមានការរីកចំរើន លើគ្រប់វិស័យដែលបង្កភាពងាយស្រួលឲ្យ ស្របទៅតាមសេចក្តីត្រូវការរបស់ទីផ្សារសេរីក្នុងសម័យសកលភាវូនីយកម្ម។

**ចំពោះសេដ្ឋកិច្ចៈ** រដ្ឋាភិបាលបង្កើតនូវគោនយោបាយការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺបានជួយជាចំណែកមួយផ្នែកដល់ចំណូលថវិកាជាតិនៅក្នុងប្រទេសឲ្យមានការរីកចម្រើន ប្រកបដោយចីរភាពជាកម្លាំងចលករ ដើម្បីពន្លឿនលើវិស័យសេដ្ឋកិច្ច។ រដ្ឋ គឺទទួលបានថវិការ ឬ ការដោះដូរ ពីសម្បទានិក តាមរយៈការធ្វើសម្បទានដីឯកជនរបស់រដ្ឋ ដែលរដ្ឋពុំមានលទ្ធភាពក្នុងការអភិវឌ្ឍន៍ ហើយដីទុកនៅទំនេរ។ រដ្ឋនឹងទទួលបានប្រាក់ឈ្នួល និង ប្រាក់ពន្ធលើការនាំចេញនាំចូលនូវវត្ថុធាតុដើម និងឧបករណ៍ផ្សេងៗសម្រាប់ផលិតកម្មរបស់ក្រុមហ៊ុននេះ។ ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺការបើកឱកាសដល់អ្នកវិនិយោគជាតិ ឬបរទេស ដែលមានបំណងចង់ធ្វើការវិនិយោគនៅកម្ពុជា ហើយក៏ជាការជួយសម្រួលដល់ការវិនិយោគ។ ភាពងាយស្រួលនេះហើយ គឺជាការលើកទឹកចិត្ត និង ការទាក់ ទាញដល់វិនិយោគិន មកបណ្តាក់ទុននៅកម្ពុជា។ ដើម្បីឲ្យដំណើរការនៃការវិនិយោគ ទទួលបានជោគជ័យ វិនិយោគិន គឺត្រូវរៀបចំរចនាសម្ព័ន្ធ ដែលរួមមានទាំង ហេដ្ឋារចនាសម្ព័ន្ធផងដែរ ក្នុងការផ្តល់ភាពងាយស្រួល។ ដូចនេះ ការអភិវឌ្ឍផ្លូវ ស្ពាន អគារ ប្រព័ន្ធទឹកភ្លើងគឺជៀសមិនផុត។ រាល់ការចំណាយទាំងអស់នេះ គឺជាចំណូលមួយសម្រាប់ប្រទេសកម្ពុជា ជាមួយគ្នានេះយើងនឹងទទួលបាននូវការអភិវឌ្ឍលើហេដ្ឋារចនាសម្ព័ន្ធ។ លើសពីនេះទៅទៀតការអភិវឌ្ឍន៍តាមរយៈសម្បទានដីសេដ្ឋកិច្ចពេលខ្លះគឺជាតំបន់ទេសចរណ៍ថែមទៀត។ តំបន់ទេសចរណ៍ក៏ជាប្រភពមួយយ៉ាងសំខាន់ ក្នុងការទាញរកចំណូលឲ្យរដ្ឋ។ សម្បទានដីសេដ្ឋកិច្ចត្រូវបានឆ្លើយតបទៅនឹងប្រយោជន៍សេដ្ឋកិច្ច ដូច្នេះសម្បទានដីសេដ្ឋកិច្ចត្រូវតែមានការចំណាយប្រាក់ឲ្យរដ្ឋាភិបាល។ ហើយការចំណាយត្រូវធ្លាក់ទៅលើរតនាគារជាតិ។ ដូចនេះហើយរដ្ឋាភិបាលមានចំណូលគ្រប់គ្រាន់ ដែលជាកូនសោមួយសម្រាប់ធ្វើការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិរបស់ខ្លួន។ បើនិយាយឲ្យចំរាជរដ្ឋាភិបាល បានស្រូបយកថវិការរបស់អ្នកវិនិយោគមកចាក់បញ្ចូលទៅក្នុងវិស័យសេដ្ឋកិច្ចដើម្បីការអភិវឌ្ឍន៍ប្រទេសយើងមិនឲ្យចាញ់ប្រទេសដែលមានការអភិវឌ្ឍន៍ជឿនលឿននោះទេ។

### ២.៦.២.គុណវិបត្តិសម្បទានដីសេដ្ឋកិច្ច

ជាទូទៅដីដែលបានបរិច្ចាគសម្រាប់សម្បទានដីសេដ្ឋកិច្ចក៏មាន ផលវិបាកក្នុងការអនុវត្តគោលនយោបាយផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ បង្កឲ្យមានរឿងរ៉ាវចម្រូងចម្រាសជាច្រើនចាក់ស្រេះក្នុងសង្គមកម្ពុជា។ បញ្ហាចម្បងគឺបញ្ហាក្រុមហ៊ុនមួយចំនួនដែលទទួលបានគោលការណ៍អនុញ្ញាតពី រាជរដ្ឋាភិបាលរួចហើយតែមិនបានអនុវត្តតាមនីតិវិធីច្បាប់ជាធរមាន និងតាមកិច្ចសន្យា ដោយកាប់ ឈើលក់ ហើយបែរជាមិនធ្វើការអភិវឌ្ឍលើដីសម្បទានសេដ្ឋកិច្ច ទន្ទ្រានដីបន្ថែមទុកដីចោលទំនេរ សម្រាប់លក់បន្ត និងការធ្វើអាជីវកម្មខុសពីលក្ខខណ្ឌនៃកិច្ចសន្យាជាដើម។ នៅថ្ងៃទី៧ ខែឧសភា ឆ្នាំ២០១២ លោកនាយក រដ្ឋមន្ត្រី ហ៊ុន សែន បានប្រកាសថាលោកបានចុះហត្ថលេខា លើបទបញ្ជាមួយធ្វើការផ្អាកជាបណ្តោះអាសន្នផ្លូវការស្តីពី ការផ្តល់សម្បទានដីសេដ្ឋកិច្ចថ្មីៗ និងពង្រឹងអ្វីដែលហៅថា គោលនយោបាយ " ស្បែកខ្លា" ពាក់ព័ន្ធនឹងសម្បទានដីសេដ្ឋកិច្ច ដែលមានស្រាប់ដើម្បីផាត់ចោលតំបន់ ដែលមានពលរដ្ឋរស់នៅពីសម្បទាន និងសម្រាលការទន្ទ្រានយកដីលើដីសហគមន៍ និងដីកសិករ។ បទបញ្ជាលេខ០០១ បង្កើតឡើងដើម្បីឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា និងអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត ពិនិត្យមើលការអនុវត្តច្បាប់ឱ្យបានតឹងរ៉ឹង លើការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ហើយបើអាជ្ញាធរមានសមត្ថកិច្ច ឬអាជ្ញាធរពាក់ព័ន្ធផ្សេងទៀត រកឃើញថា ក្រុមហ៊ុនដែលទទួលបានសម្បទាននោះ បានរំលោភបំពានកិច្ចសន្យាសម្បទាន ឬបទប្បញ្ញត្តិច្បាប់ អាជ្ញាធរមានសមត្ថកិច្ចត្រូវដកហូតសម្បទានដីសេដ្ឋកិច្ចនោះមកវិញ ។[68]

ជាក់ស្តែងបញ្ហាក្រុមហ៊ុនហេង ហ៊ាប គឺជាក្រុមហ៊ុនមួយក្នុងចំណោមក្រុមហ៊ុន៣២ផ្សេងទៀតដែលត្រូវបាននិរាករណ៍ដែលមានទីតាំងស្ថិតនៅក្នុងឃុំយ៉ាទុង ស្រុកអូយ៉ាដាវ ខេត្តរតនៈគីរី ។ យោងតាមរបាយការណ៍វាយតម្លៃរបស់ក្រុមការងារក្រសួងកសិកម្ម បង្ហាញថាក្រុមហ៊ុនហេង ហ៊ាប មិនបានបំពេញតាមលក្ខខណ្ឌមួយចំនួនដែលបានកំណត់ដោយច្បាប់ដូចជា គ្មានរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថានមិនបានធ្វើអនុបយោគដីទៅជាដីឯកជនរបស់រដ្ឋ ការចុះបញ្ជីដីរដ្ឋ មិនបានពិគ្រោះយោបល់ជាមួយពលរដ្ឋដែលរងផលប៉ះពាល់ឱ្យបានសមស្រប ពិសេសជនជាតិដើមភាគតិចដែលកំពុងរស់នៅក្នុងតំបន់នោះ។ អនុលោមតាម ស.ជ.ណ លេខ៦២៦ ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាសម្រេចនិរាករណ៍ក្រុមហ៊ុន ហេង ហ៊ាប និងបានផ្ទេរដីសម្បទាននេះទៅ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងអាជ្ញាធរខេត្តរតនៈគីរីដើម្បីគ្រប់គ្រង។ បន្ទាប់ពីការត្រួតពិនិត្យ និងវាយតម្លៃក្នុងឆ្នាំ២០១៤ ក្រុម ហ៊ុន ហេង ហ៊ាប វិនិយោគត្រូវបានត្រួតពិនិត្យមើលយ៉ាងតឹងរ៉ឹងដោយក្រុមការងារក្រសួងកសិកម្ម។ មន្ទីរ អាជ្ញាធរមូលដ្ឋាន និងមន្ត្រីថ្នាក់ស្រុកបានលើកឡើងថា ក្រុមហ៊ុននេះមិនគោរពតាមច្បាប់របស់រដ្ឋាភិបាលបានចូលរួមប្រព្រឹត្តបទល្មើសព្រៃឈើ និង

[68] ផ្លូវបេត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា,សមាគមអាដហុក (ខែកុម្ភៈ ២០១៣)

គ្មានឆន្ទៈក្នុងការ វិនិយោគ។ បើតាមសំដីមន្ត្រីរដ្ឋាភិបាល និងសហគមន៍ បានត្អូញត្អែលថា ក្រុមហ៊ុនមិនបានគោរពតាមច្បាប់ ហើយបានចូលរួមចំណែកដល់ការប្រព្រឹត្តបទល្មើសព្រៃឈើ រំលោភ សិទ្ធិមនុស្ស បង្កើតឱ្យមានជម្លោះដីធ្លីជាមួយសហគមន៍ជនជាតិដើមភាគតិច។ សហគមន៍បានសង្កេតឃើញថា ម្ចាស់ក្រុមហ៊ុនមិនមានឆន្ទៈក្នុងការវិនិយោគនៅលើដីនេះទេ បន្ទាប់ពីឈូស ឆាយព្រៃឈើរួចរាល់។ យោងតាមការអង្កេតនៅទីតាំងក្រុមហ៊ុន គឺថាក្រុមហ៊ុនដាំដុះដំណាំកៅស៊ូបានតិចតួចនិងដាំដំឡូងមី តាមបណ្តោយស្ទឹង និងផ្ទៃដីដែលនៅសល់យ៉ាងធំល្វឹងល្វើយមិនបានដាំដុះនោះទេ។ នៅឆ្នាំ២០១៣ ការសែតឌឹកាំបូឌាដេលី បានចុះផ្សាយថា ប្រាសាទរតនៈគិរីឥឡូវនេះស្ថិតនៅក្នុងដីសម្បទានសេដ្ឋកិច្ច បានបញ្ជាក់ថា ប្រាសាទបុរាណរបស់ជនជាតិចារ៉ាយឈ្មោះថា ប្រាសាទតាណាង បានកសាងឡើងជា ច្រើនសតវត្សមកហើយ ហើយមានទីតាំងស្ថិតនៅក្នុងតំបន់សម្បទានដីសេដ្ឋកិច្ចរបស់ក្រុមហ៊ុន ហោង ហ៊ាប វិនិយោគ។ ម្ចាស់ក្រុមហ៊ុនក៏បានដឹងថាមានប្រាសាទនេះដែរតាមរយៈព័ត៌មានពីសាលាខេត្តប៉ុន្តែនៅតែធ្វើសកម្មភាពផ្សេងៗនៅតំបន់នេះដដែល។ យោងលើច្បាប់ស្តីពីការការពារបេតិកភណ្ឌវប្បធម៌ ឆ្នាំ១៩៩៦ លើកឡើងថា សកម្មភាពណាមួយ ឬការងារសាងសង់ត្រូវតែបញ្ឈប់នៅទីតាំងបេតិកភណ្ឌ រហូតដល់មានការវាស់វែងតំបន់នោះចេញដើម្បីរក្សាទុកការពារ។[69] ទង្វើខុសច្បាប់របស់ក្រុមហ៊ុនភាគច្រើនបានបង្កឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរ ដល់សិទ្ធិដីធ្លីរបស់សហគមន៍សិទ្ធិលំនៅដ្ឋាន ជីវភាពរស់នៅ សហគមន៍ព្រៃឈើនិងការរំលោភសិទ្ធិមនុស្ស។

របាយការណ៍សរុបរបស់ ក្រសួង កសិកម្មដែលបានឲ្យដឹងថាចាប់ពីឆ្នាំ ១៩៩៣ ដល់ឆ្នាំ ២០០៩ រដ្ឋាភិបាលបានផ្តល់ដីសម្បទានទំហំ ១.៣០០.០០០ ហិកតាដល់ក្រុមហ៊ុនឯកជន។ រដ្ឋបានលុបចោលកិច្ចសន្យាដីសម្បទានសេដ្ឋកិច្ចពីក្រុមហ៊ុនចំនួន៤១ ដែលមានផ្ទៃ ដីទំហំ ៣៧៩.០៣៤ ហិកតារបន្ទាប់ពីក្រុមហ៊ុនទាំងនោះយកដីទុកមិនបានអភិវឌ្ឍន៍។[70]

---

[69] របាយការណ៍វាយតម្លៃ ស្ថានភាពនិរាករណ៍សម្បទានដីសេដ្ឋកិច្ចៈករណីសិក្សាពីខេត្តភាគឧត្តរនៃប្រទេសកម្ពុជា
[70] វិទ្យុអាស៊ីសេរី ថ្ងៃទី ២៦ ខែឧសភា ឆ្នាំ ២០១០ បកស្រាយដោយលោកតាំង សារ៉ាដា

# ជំពូកទី៣

# ផលប៉ះពាល់នៃការផ្ដល់សម្បទានដីសេដ្ឋកិច្ច

ជាទូទៅ ផលប៉ះពាល់នេះតែងតែកើតមានឡើងនៅកន្លែងណាដែលមានការពាក់ព័ន្ធ ទៅលើសិទ្ធិ ការអាស្រ័យផល ការគ្រប់គ្រងទ្រព្យសម្បត្តិ ឬកន្លែងណាដែលអាចនឹងទាញយកផលប្រយោជន៍បានជាដើម។ ជាក់ស្ដែង នៅក្នុងការធ្វើសម្បទានដីសេដ្ឋកិច្ចក៏ដូចគ្នា យើងអាចកត់សម្គាល់ឃើញថាកន្លែងណាដែលមានការអភិវឌ្ឍមានការរីកចម្រើនជាបន្តបន្ទាប់ កន្លែងនោះតែងតែកើតមានផលប៉ះពាល់លេចឡើងមកស្របជាមួយគ្នាផងដែរ។ វិវាទដែលប៉ះពាល់ទាំងនោះ អាចនឹងកើតមានឡើងនៅ អំឡុងពេលសម្បទានដី សេដ្ឋកិច្ច ឬពេលដែលមានការទូទាត់សំណងសម្បទានដីសេដ្ឋកិច្ចជាដើមដែលបញ្ហាទាំងនេះពិតជា ទាមទារឲ្យរដ្ឋាភិបាលដាក់ចេញនូវវិធានការផ្សេងៗ និងស្វែងរកដំណោះស្រាយឲ្យខាងតែបានចៀសវាង នាំឲ្យមានការអាក់ខាននូវកិច្ចការអភិវឌ្ឍប្រទេសជាតិ។ គោលនយោបាយរបស់រដ្ឋាភិបាលក្នុងការផ្ដល់សម្បទានដីសេដ្ឋកិច្ច ដែលបានបង្កើតឡើងក្នុងគោលបំណងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជាតិប្រទេសកម្ពុជាឲ្យបានជឿនលឿន មានភាពរីកចម្រើនយ៉ាងខ្លាំង តាមរយៈការបន្តាក់ទុនវិនិយោគរបស់វិនិយោគិនដែលមានផលវិជ្ជមានដល់ប្រជាជន សង្គម និងសេដ្ឋកិច្ចជាតិ។

ម្យ៉ាងទៀតស្របពេលជាមួយគ្នានេះដែរ ដោយសារការធ្វើសម្បទានដីសេដ្ឋកិច្ច បានធ្វើឲ្យមានការប៉ះពាល់មួយចំនួនធំ។ ហើយភាគច្រើនគេសង្កេតឃើញមាន ផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ ផលប៉ះពាល់ជាមួយជនជាតិដើមភាគតិច និងផលប៉ះពាល់ជាមួយបរិស្ថានធម្មជាតិដែលនៅក្នុងតំបន់ដែលបានផ្ដល់សម្បទានដីសេដ្ឋកិច្ចនោះនិងមានផលប៉ះពាល់ផ្សេងៗទៀត។ល។

ដើម្បីកាន់តែងាយស្រួលយល់ក្នុងចំណុចផលប៉ះពាល់នេះ យើងខ្ញុំទាំងពីរនាក់នឹងធ្វើការពន្យល់បកស្រាយលំអិតនៅចំណុចនីមួយៗដូចនៅចំណុចបន្ទាប់ខាងក្រោម។

## ៣.១.ផលប៉ះពាល់

### ៣.១.១.ផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ

ការផ្ដល់ដីសម្បទានសេដ្ឋកិច្ចរបស់រដ្ឋាភិបាលដល់បណ្ដាក្រុមហ៊ុនឯកជនដើម្បីធ្វើការអភិវឌ្ឍបានបន្សល់ជាជម្លោះដីធ្លី ទំហំផលប៉ះពាល់អវិជ្ជមានពីការអនុវត្តគោលនយោបាយនេះ ហាក់មានច្រើនហួសពីការរំពឹងទុក ដែលបានអនុវត្តផ្ទុយនិងការចង់បានពីផលវិជ្ជមាននៃដីសម្បទានដីសេដ្ឋកិច្ចទៅវិញស្របពេលដែលពលរដ្ឋខ្មែរកាន់តែច្រើនឡើងៗបានធ្លាក់ខ្លួនក្រីក្រ ដោយសារតែអំពើប្លាមយកដីធ្លី និងការបណ្ដេញចេញដោយបង្ខំ។ រីឯកេរដំណែលធនធានធម្មជាតិរបស់ប្រទេសជាតិទាំងមូលវិញ ក៏ចេះតែហិនហោចទៅៗ ដោយសារតែវិនាសកម្មកាប់បំផ្លាញព្រៃឈើក្នុងទ្រង់ទ្រាយធំមិនធ្លាប់មានពីមុនមក។ ទោះជាការផ្ដល់ដីម្បទានសេដ្ឋកិច្ច

ចូលរួមចំណែកពង្រឹងខឿនសេដ្ឋកិច្ចរបស់រដ្ឋ និង ផ្តល់ការងារឲ្យពលរដ្ឋក្នុងមូលដ្ឋានក៏ដោយផលប៉ះពាល់អវិជ្ជមានដល់ពលរដ្ឋវិញក៏មានច្រើនហួសប្រមាណ មានការគំរាមកំហែងតាមផ្លូវវាងកាយដូចជាបញ្ហាកន្លងមកមានបញ្ហាបណ្តេញពលរដ្ឋចេញ ពេលប្រជាពលរដ្ឋតវ៉ា មានការបាញ់ប្រហារទៅលើប្រជាពលរដ្ឋមានរងរបួសហើយខ្លះរហូតដល់ស្លាប់ ភាគច្រើនវាជាការណ៍ដែលធ្វើឲ្យប្រជាពលរដ្ឋគាត់ក្លាយទៅជាអ្នក ដែលគ្មានដីគ្មានផ្ទះ។[71]

ការផ្តល់ដីសម្បទានសេដ្ឋកិច្ចមានបញ្ហាជាមួយប្រពលរដ្ឋកើតមានជាញឹកញាប់ រួមមានការមិនបានពិគ្រោះ យោបល់ជាមួយ ប្រជាពលរដ្ឋមូលដ្ឋាន ការមិនបានវាយតម្លៃពីផលប៉ះពាល់បរិស្ថាន ការបដិសេធសិទ្ធិប្រើប្រាស់ដីជាប្រពៃណី ហើយនិងការមិនអនុញ្ញាតឱ្យប្រមូលអនុផលព្រៃឈើ ការជម្លៀសប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន និង ដីកសិកម្មរបស់ពួកគេ ការបាត់បង់របរចិញ្ចឹមជីវិតជាប្រពៃណី ជាគុណប្រយោជន៍ដល់ការបង្កើតការងារមួយចំនួន ដែលមានប្រាក់ឈ្នួលទាបប្រជាពលរដ្ឋនៅតំបន់ជនបទមានទម្លាប់ប្រកបការងារកសិកម្មដែលមានរូបភាពជាគ្រួសារស្វយ័ត ការផ្លាស់ប្តូរពីការងារកសិកម្ម ទៅជាការងារមានប្រាក់ឈ្នួល ទំនាស់កើតមានរវាងក្រុមហ៊ុននានា និង ប្រជាពលរដ្ឋមូលដ្ឋាន ហើយនិងមានការ បំភិតបំភ័យពីកងសន្តិសុខប្រដាប់អាវុធហើយជួនកាលពីយោធិននៃកងយោធពលខេមរភូមិន្ទ ។[72]

ការយល់ដឹងអំពីសិទ្ធិស្របច្បាប់របស់ប្រជាពលរដ្ឋនៅតំបន់ជនបទ នៃប្រទេសកម្ពុជានៅមានកម្រិតដែលបណ្តាលឲ្យមានករណីចំនួនបួន ដែលបានកើតមានឡើងយើងខ្ញុំទាំងពីរនាក់នឹងបកស្រាយខាងក្រោម ក្នុងនោះមានដូចជា៖

**ទី១ ការទន្ទ្រានលើដីកសិកម្ម និងដីសម្រាប់ចិញ្ចឹមសត្វពាហណៈរបស់ប្រជាពលរដ្ឋ៖** សម្បទានដីសេដ្ឋកិច្ច និងការទន្ទ្រានយកដីធ្លីបានបង្ខំប្រជាពលរដ្ឋឲ្យចេញពីដីកសិកម្មរបស់គេដោយមិនបានផ្តល់ឱកាសឲ្យបានគ្រប់គ្រាន់ដើម្បីទទួលបានដីនៅកន្លែងផ្សេងៗទៀត។ ការទន្ទ្រានលើដីកសិកម្ម និងដីវាលស្មៅសម្រាប់ចិញ្ចឹមសត្វ ដែលនាំដល់ការបាត់បង់របរចិញ្ចឹមជីវិត នៅតែជាកង្វល់រួមដែលបានលើកឡើងដោយសហគមន៍ហើយបញ្ហានេះកើតមានស្ទើរតែគ្រប់សម្បទានដែលកំពុងតែមាន សកម្មភាពទាំងអស់។ ជាក់ស្តែងការផ្តល់សម្បទានដីដល់ក្រុមហ៊ុន កោះកុងស៊ូហ្គ័រអីនដាសស្ត្រី និង ក្រុមហ៊ុនកោះកុង ផ្លេនថេសិន ក្នុងខែសីហា ឆ្នាំ ២០០៦ ត្រូវបានធ្វើឡើងដោយ គ្មានការពិគ្រោះយោបល់ជាសាធារណៈ។ សម្បទានទាំងនេះស្ថិតក្នុងស្រុកស្រែអំបិល និង ស្រុកបុទុមសាគរដែលអ្នកស្រុកបានធ្វើកសិកម្ម ចាប់តាំងពីឆ្នាំ ១៩៧៩។ ការឈូសឆាយដីស្រែ និង ចំការដំណាំរបស់អ្នកស្រុក ក្នុងស្រុកស្រែអំបិលបានធ្វើ ឲ្យមានផលប៉ះពាល់ប្រជាពលរដ្ឋជាង ៤០០

[71] វិទ្យុអាស៊ីសេរី ថ្ងៃទី ២០ ខែកក្កដា ឆ្នាំ ២០២០ បកស្រាយដោយលោកមាន ឬទ្ធិ

[72] របាយការណ៍ ដីសម្បទានគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ឆ្នាំ២០០៤

គ្រួសារ ដែលគ្រួសារខ្លះនៅសល់ដីបន្តិចបន្តួចឬគ្មាននៅសល់ដីសោះសម្រាប់ធ្វើកសិកម្មហើយរស់នៅដោយស្រូវដែលសល់ពីឆ្នាំមុន។ សម្បទាននេះក៏បានធ្វើឲ្យមានការរឹតត្បិតដល់ដីស្មៅ សម្រាប់ចិញ្ចឹម សត្វពាហនៈរបស់អ្នកស្រុក អ្នកស្រុកបាត់បង់ប្រាក់ចំណូលអ្នកស្រុកកំពុងជួប ប្រទះការលំបាកជាច្រើន។

**ទី២ ប្រជាពលរដ្ឋដែលត្រូវគេបណ្តេញចេញពីលំនៅឋានប្រឈមមុខទៅនឹងបញ្ហាជាច្រើនក្រៅពីបញ្ហាបាត់បង់កម្មសិទ្ធិ៖** រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា បញ្ជាក់ថា ប្រជាពលរដ្ឋខ្មែរគ្រប់រូប មានសិទ្ធិជាម្ចាស់កម្មសិទ្ធិលើដីធ្លីដែលការដកហូតកម្មសិទ្ធិអំពីជនណាម្នាក់បាន លុះត្រាតែផលប្រយោជន៍សាធារណៈតម្រូវឲ្យធ្វើ ហើយត្រូវឲ្យស្របច្បាប់ និងត្រូវផ្តល់សំណងជាមុនដោយសមរម្យ និងយុត្តិធម៌។[73] តាមរយៈការផ្តល់សម្បទានដីសេដ្ឋកិច្ច ពួកគេមិនបានទទួលនូវការផ្តល់សំណង ឬ បានទទួល ការផ្តល់សំណងមិនសមរម្យ និងមានការបង្ហាញបញ្ជាក់អំពីផលប៉ះពាល់ប្រយោជន៍ សាធារណៈនៃសម្បទានទាំងនោះឡើយ ហើយដីរបស់ពួកគេត្រូវបានឈូសឆាយអស់ហើយ។ គ្រួសារទាំងនោះត្រូវបានផ្លាស់ប្តូរឲ្យទៅនៅលើដីឡូត៍ស្ថិតនៅតាមដង ផ្លូវដែលវាមានទំហំតូចពេកសម្រាប់ធ្វើការដាំដុះ។ ជាញឹកញាប់ ពួកគាត់ពុំមានទឹកស្អាត សម្រាប់ប្រើប្រាស់ពុំមានអនាម័យ ក្នុងកន្លែងរស់នៅ និងពុំមានអគ្គិសនីប្រើប្រាស់ នៅក្នុងករណីខ្លះបើទោះបីជាពួកគាត់ត្រូវបានបណ្តេញចេញទៅកន្លែងថ្មីរយៈពេល៦ឆ្នាំហើយក៏ដោយ ក៏អាជ្ញាធរមិនទាន់បានផ្តល់សេវាជាចាំបាច់ដល់ពួកគាត់នៅឡើយ។ ប្រជាពលរដ្ឋ ទាំងនេះត្រូវបង្ខំចិត្តទិញទឹកពីអណ្តូងឯកជន និងភ្លើងអគ្គិសនី ពីអ្នកផ្គត់ផ្គង់អគ្គិសនីនៅតាមមូលដ្ឋាន។ ប្រជាពលរដ្ឋដែល រងការបណ្តេញចេញពីតំបន់តាំងទីលំនៅដ្ឋានក្នុងក្រុងទៅកាន់តំបន់តាំងទីលំនៅដ្ឋានថ្មី ជាញឹកញាប់ប្រឈមទៅនឹងបញ្ហា ការងារអប់រំ និងសកម្មភាពរកប្រាក់ចំណូលផ្សេងៗទៀត។ជាក់ស្តែង នៅទីតាំងភូមិអណ្តូង ដែលជាកន្លែងតាំងទីលំនៅថ្មី របស់អតីតប្រជាពលរដ្ឋ សហគមន៍ពីទន្លេបាសាក់ មាន ចម្ងាយប្រមាណជា២០គីឡូម៉ែត្រពីរាជធានីភ្នំពេញ និងទីតាំងភ្នំបាត ដែលជាតំបន់តាំងទីលំនៅដ្ឋានថ្មីរបស់អតីតប្រជាពលរដ្ឋពីដីក្រហម និងបុរីកីឡា មានចម្ងាយ៤០គីឡូម៉ែត្រពីរាជធានី ភ្នំពេញ។ បញ្ហាគឺ មានសាលារៀនចំនួនតិចតួច ប៉ុណ្ណោះដែលមានទីតាំងស្ថិតនៅក្នុង ឬនៅជិតតំបន់តាំងទី លំនៅដ្ឋានថ្មីទាំងនេះប៉ុណ្ណោះ។ កុមារជាច្រើននាក់បានបោះបង់ ការសិក្សា ហើយកុមារដែលអាចបន្តការសិក្សារបស់ខ្លួនទំនង ជាមានបញ្ហាក្នុងការរៀនត្រួតថ្នាក់។ សុខភាពរបស់ ប្រជាពលរដ្ឋ ដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋានដោយ បង្ខំត្រូវរងការប៉ះពាល់យ៉ាងធ្ងន់ធ្ងរ។ គ្រួសារភាគច្រើន ដែលត្រូវបានបណ្តេញចេញពីលំនៅដ្ឋានមានបញ្ហាជំងឺគ្រួសារភាគច្រើនមានអារម្មណ៍ថា សុខភាព របស់សមាជិកគ្រួសារមិនល្អឡើយ។[74]

---

[73] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ឆ្នាំ១៩៩៣ មាត្រា៤៤ ហើយឆ្លុះបញ្ចាំង ក្នុងមាត្រា ៥ នៃច្បាប់ភូមិបាល ឆ្នាំ២០០១

[74] ផ្លូវរបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា,សមាគមអាដហុក (ខែកុម្ភៈ ២០១៣)

**ទី៣ ប្រជាពលរដ្ឋការបាត់បង់សិទ្ធិប្រើប្រាស់ព្រៃឈើដែលជារបរចិញ្ចឹមជីវិតជាប្រពៃណី និងអនុផលព្រៃឈើ៖** តំបន់ព្រៃដែលជាកន្លែងប្រជាពលរដ្ឋធ្វើកសិកម្មពនេចរជាពិសេសការរកជ័រច្បោះ ការប្រើប្រាស់ព្រៃឈើនៅជុំវិញលំនៅស្ថានបានជួយឱ្យគេ អាចទ្រទ្រង់ជីវិតបានអាចរកប្រាក់កំរៃបន្ទាប់បន្សំពីការប្រមូលអនុផលព្រៃឈើនោះបានដែរ។ ប៉ុន្តែក្រុមហ៊ុនបានកាប់ឆ្ការ និងឈូសឆាយព្រៃ ដែលជាព្រៃប្រជាពលរដ្ឋមូលដ្ឋានពឹងពាក់ ក្រុមហ៊ុនទាំងនោះ បានបដិសេធមិនឱ្យប្រជាពលរដ្ឋចូលក្នុងព្រៃ ដើម្បីប្រកបរបរចិញ្ចឹមជីវិត។ ដូចករណីក្នុងខេត្តស្ទឹងត្រែង ដីសម្បទានចំនួន ៥កន្លែង ដែលត្រូវបានផ្តល់ឲ្យក្រុមហ៊ុន គ្របដណ្តប់តំបន់ព្រៃក្នុង ស្រុកសេសាន រួមទាំងតំបន់ព្រៃក្រាស។ សម្រាប់ឃុំទំរីង ប្រជាពលរដ្ឋមូលដ្ឋានពឹងផ្អែកទាំងស្រុងទៅលើការចោះឈើយកជ័រ គ្រួសារខ្លះមានដើមឈើផ្ទាល់ខ្លួនរហូតដល់ជាង១០០ដើមឯណោះ។ គ្រួសារនីមួយៗ អាចរកប្រាក់ចំណូលបាន ១០០ ដុល្លារក្នុងមួយខែពីការដងយកជ័រ។ សកម្មភាពការងាររបស់ក្រុមហ៊ុន បានកំរិតសិទ្ធិអ្នកស្រុកក្នុងការចូលព្រៃដើម្បីចោះយកជ័រ និងប្រមូលអនុផលព្រៃឈើ។ ជាក់ស្តែងការហាមចូលព្រៃក្នុងដីសម្បទាននៃក្រុមហ៊ុនហៃនិញផងដែរបានបង្កឱ្យមានការលំបាកជាច្រើន ដល់ប្រជាពលរដ្ឋមូលដ្ឋានក្នុងការដុតធ្យូង និង ការប្រមូលអុសដុត ដែលជាប្រភពចំណូលមួយដ៏សំខាន់របស់ពួក គាត់បន្ទាប់ពីរយៈពេល៣ ឆ្នាំ នៃគ្រោះរាំងស្ងួត និង ការធ្វើស្រែមិនបានផលមក។[75]

**ទី៤ ផលប៉ះពាល់លើផ្នែកសំខាន់ខាងវប្បធម៌ និងខាងជំនឿរបស់ប្រជាពលរដ្ឋ៖** ការធ្វើសម្បទានដីសេដ្ឋកិច្ចមួយចំនួនគឺបានប៉ះពាល់ដីជាមូលដ្ឋានគ្រឹះសម្រាប់ការរៀបចំសង្គមនៅតំបន់ជនបទនៃប្រទេសកម្ពុជា។ ដីដែលប្រជាពលរដ្ឋមានជំនឿ សាសនា ដោយសារដីនោះត្រូវបានត្រួតត្រាដោយអ្នកតាម្ចាស់ដី ។ ព្រះអាទិទេព ដែលគេហៅថា "អ្នកតា" ដែលចំណែកដីសំខាន់ខ្លាំងណាស់នៅក្នុងទំនៀមទំលាប់នៃប្រទេសកម្ពុជា។ ជំងឺដង្កាត់ និង ជោគវាសនាអាក្រក់ ជារឿយៗត្រូវបានគេជឿថាកើតមកពីទង្វើរបស់អ្នកទាំងនោះ អ្នកតាបានធ្វើការសងសឹកវិញ នៅពេលដែលមាននរណាម្នាក់បានធ្វើការរំខានដល់របៀបរបបសង្គម ប្រព្រឹត្តល្មើសនឹង ក្រមសីលធម៌ ឬ បានចូលរុករានទន្ទ្រានក្នុងតំបន់របស់ខ្លួនដោយមិនបានសុំការអនុញ្ញាតជាមុន។ ជាពិសេសកន្លែងមួយប្រសិនបើមិនមានការរៀបចំចងក្រងជាសៀវភៅប្រវត្តិសាស្ត្រទេ នោះដីធ្លីគឺជាកន្លែងកំណត់ទុកនូវការចងចាំអំពីប្រវត្តិសាស្ត្រអតីតកាលនោះ។ ដីធ្លីគឺជាកន្លែងតំកល់ទុកនូវការចងចាំអំពីប្រវត្តិអតីតកាលដែលប្រជាពលរដ្ឋចាត់ទុកដីធ្លីប្រដូចថាជា សៀវភៅប្រវត្តិសាស្ត្រមួយដែលបើកចំហរហើយជនគ្រប់រូបអាចសិក្សាស្វែងយល់អំពីប្រវត្តិផ្សេងៗ ដែលកើតមាននឹងជាប់ទាក់ទងនឹងទីកន្លែងមូលដ្ឋាននោះ ដូចជាឈ្មោះទីកន្លែង ផ្លូវចាស់ សញ្ញា សំគាល់លើដី និងប្រវត្តិរឿងរ៉ាវផ្សេងៗ ដែលជាប់ទាក់ទងនឹងទីកន្លែងនោះ ។ ប្រជាពលរដ្ឋមូលដ្ឋានយល់

[75] របាយការណ៍ ដីសម្បទានគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ឆ្នាំ២០០៤

ថា ការឈូសឆាយដី គឺជាទិដ្ឋភាពមួយដែលបង្ហាញពីជាការលុបបំបាត់ចោលនូវប្រវត្តិសាស្ត្រ និង ប្រពៃណីរបស់ខ្លួនទៀតផង ។[76] ការប្រើប្រាស់ដីសម្បទាន នាំឲ្យបាត់បង់នូវភស្តុតាងនៃប្រវត្តិសាស្ត្រ និង អារ្យធម៌ដ៏រុងរឿង។

### ៣.១.២.ផលប៉ះពាល់ជាមួយជនជាតិដើមភាគតិច

ការធ្វើសម្បទានដីសេដ្ឋកិច្ចមានផលប៉ះពាល់ដល់ជនជាតិដើមភាគតិចមិនខុសគ្នាប៉ុន្មានទេ ពីប្រជាពលរដ្ឋមិនមែនជាជនជាតិដើមភាគតិច។ ការធ្វើសម្បទានដីសេដ្ឋកិច្ចមានការគំរាមកំហែងយ៉ាងធ្ងន់ធ្ងរដល់សហគមន៍ជនជាតិដើមភាគតិចដែលប៉ះពាល់នឹងឧបសគ្គធំធេង ក្នុងការទទួលស្គាល់ថា ជាក្រុមស្របច្បាប់ និងចុះបញ្ជីដីធ្លីរបស់ខ្លួនជាកម្មសិទ្ធិសមូហភាព។ កង្វះខាតភាពច្បាស់លាស់ជុំវិញស្ថានភាពដីធ្លីកង្វះខាតការអនុវត្តច្បាប់និងបទប្បញ្ញត្តិ នៅក្នុងវិស័យដីធ្លី និងបរិស្ថាន កង្វះការធានាទប់ទល់នឹងការបណ្តេញចេញដោយបង្ខំ កង្វះការទទួលស្គាល់សិទ្ធិរបស់ជនជាតិដើមភាគតិចគឺជាការរួមចំណែកដល់ បរិយាកាសរួមនៃអសន្តិសុខក្នុងការកាន់កាប់ដីធ្លី មានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសិទ្ធិវប្បធម៌របស់ជនដើមភាគតិច។ សហគមន៍ជនជាតិដើមភាគតិចកំពុងប៉ះពាល់នឹងការបាត់បង់ដីធ្លីជាប្រពៃណី និងធនធានធម្មជាតិរបស់ខ្លួន ដោយសារតែសម្បទានដីសេដ្ឋកិច្ច អ្នកទន្ទ្រានយកដីធ្លី និងអ្នកកាប់ឈើ។[77]

បន្ថែមពីនេះនៅក្នុងករណីបញ្ហាជនជាតិដើមភាគតិចខាងលើនេះយើងសង្កេតឃើញថាមានករណីចំនួនពីរ ដែលជាផលប៉ះពាល់ជាមួយជនជាតិដើមភាគតិចពេលធ្វើសម្បទានដីសេដ្ឋកិច្ចក្នុងនោះរួមមានដូចជា៖

**ទី១ ការបាត់បង់នៃដីធ្លីជាទីជម្រកចិញ្ចឹមជីវិត និងធនធានធម្មជាតិកន្លែងវប្បធម៌ និងជំនឿ ប្រពៃណីចំពោះជនជាតិដើមភាគតិច៖** ការបាត់បង់ដីធ្លី និងធនធានព្រៃឈើ គឺជាកត្តាសំខាន់បំផុតសម្រាប់ការចិញ្ចឹមជីវិត វប្បធម៌ និងប្រពៃណីរបស់ជនជាតិដើមភាគតិចកម្ពុជានៅតែមានការកើតឡើង។ វាជាសញ្ញាប៉ះពាល់ខ្លាំងលើរបរការចិញ្ចឹមជីវិតរបស់សហគមន៍ជនជាតិដើមភាគតិចដែលពឹងផ្អែកទាំងស្រុងលើកសិកម្មពនេចរ និងការរកអនុផលព្រៃឈើ ហើយព្រៃគឺជាកត្តាសំខាន់បំផុតសម្រាប់ជីវិតវប្បធម៌ និងជំនឿ ។ ក្រុមហ៊ុនធ្វើសកម្មភាពមិនបានកាត់ឆ្មៀលផលប៉ះពាល់ តាមរូបមន្តស្បែកខ្លា របស់រដ្ឋាភិបាលក្រុមហ៊ុនបានបំផ្លិតបំផ្លាញព្រៃឈើ ដីចម្ការអ្នកភូមិ និងដីសមូហភាព ជាពិសេសដីពាក់ព័ន្ធដីកប់សាកសពដូនតា និងព្រៃសក្ការៈរបស់ជនជាតិដើមភាគតិច។ សហគមន៍ជនជាតិដើមភាគតិចបានសំដែងកង្វល់អំពីវប្បធម៌ របៀបរបបរស់នៅជាប្រពៃណី និងអត្តសញ្ញាណរបស់ពួកគេ ដែលកំពុងទទួលរងការគំរាមកំហែង ។ ពួកគេមានការភ័យខ្លាចថា ការបាត់បង់ដីធ្លីនិងព្រៃឈើ នឹងឈានទៅរកការបាត់បង់វប្បធម៌របស់ពួកគេ ព្រោះថាមនុស្សជំនាន់ក្រោយនឹងមិនមានអ្វីធ្វើជា

[76] របាយការណ៍ដីសម្បទានគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ឆ្នាំ២០០៤

[77] ផ្លូវបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា,សមាគមអាដហុក (ខែកុម្ភៈ ២០១៣)

សំអាងអំពីវប្បធម៌ របស់ខ្លួនឡើយ ។ ដូចតំណាងសហគមន៍ជនជាតិដើមភាគតិចបានគូសបញ្ជាក់ហើយថា ដីធ្លីគឺជាអាយុជីវិត ហើយប្រសិន ជាគ្មានដីធ្លីទេ គឺគ្មានអាយុជីវិត សម្រាប់សហគមន៍ជនជាតិដើមភាគតិចទាំងនោះឡើយ។ ជាពិសេសព្រៃឈើជីវិតនិងអាហាររបស់ជនជាតិដើមភាគតិចពឹងផ្អែកទាំងស្រុងលើព្រៃធម្មជាតិ។[78] ជាក់ស្តែងដូចជាក្រុមហ៊ុនសម្បទានដី Socfin-KCD ក្នុងក្រុងប៊ូស្រា ខេត្តរតនគិរីករណីរំលោភដីធ្លីអាស្រ័យផលរបស់សហគមន៍ និងឈូសឆាយព្រៃអារក្សរបស់ជនជាតិដើមភាគតិចអស់រាប់ពាន់គ្រួសារ។ អ្នកភូមិថា ក្រុមហ៊ុននេះ បានរំលោភដីធ្លីអាស្រ័យផលរបស់ជនជាតិដើមភាគតិចអស់យ៉ាងហោចណាស់ ១០.០០ ហិកតា បំពានតំបន់ទីសក្ការៈបូជា ព្រៃតំណម និងព្រៃកប់សពជាដើម។[79]

**ទី២ ការធ្វើសម្បទានដីសេដ្ឋកិច្ច នៅក្នុងតំបន់រស់នៅជនជាតិដើមភាគតិច៖** នៅខេត្តភាគឦសាន ដូចជាខេត្តរតនគិរីនិងខេត្តមណ្ឌលគិរី មានជនជាតិដើមភាគតិចច្រើនលើសលប់រស់នៅ ហើយក៏មានជនជាតិដើមភាគតិចច្រើនណាស់ដែរនៅខេត្តក្រចេះ និងខេត្តស្ទឹងត្រែង ។ សហគមន៍ក្នុងតំបន់ទាំងនេះ បានកំពុងតែរងសម្ពាធនៃការផ្ទេរកម្មសិទ្ធិដីធ្លី តាមរយៈការដណ្តើមយកដីធ្លីនិងការលក់ដីដោយមានការបង្ខិតបង្ខំឬដោយខុសច្បាប់។[80] ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺជាការផ្ទេរកម្មសិទ្ធិដីធ្លីយ៉ាងឆាប់រហ័ស ហើយសម្បទានទាំងនេះកំពុងតែកំរាមកំហែងដល់ ជីវភាពរស់នៅ វប្បធម៌ និងសុខមាលភាពរបស់សហគមន៍ ជនជាតិដើមភាគតិច ។ សម្រាប់សម្បទានដីសេដ្ឋកិច្ចយ៉ាងតិច ២៥ ហើយត្រូវបានគេឲ្យដឹងថាប៉ះពាល់ដីជនជាតិដើមភាគតិចក្នុងខេត្តកំពង់ធំ ក្រចេះ មណ្ឌលគិរី ឧត្តរមានជ័យ រតនគិរី និងស្ទឹងត្រែង ។ សម្បទាន ដែលបានផ្តល់លើដីជនជាតិដើមភាគតិចរួមមាន នៅក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ និងនៅទឹកធ្លាក់ប៊ូស្រា ខេត្តមណ្ឌលគីរី និងអាជ្ញាប័ណ្ណ រ៉ែជាច្រើន ដែលប៉ះពាល់លើដីជនជាតិដើមភាគតិច ក្នុងខេត្តមណ្ឌលគីរី ពោធិសាត់ និងព្រះវិហារ ។ ជាក់ស្តែងនៅចុងឆ្នាំ២០០៦ អាជ្ញាប័ណ្ណមួយត្រូវបានផ្តល់ឱ្យក្រុមហ៊ុន ប៊ី.អេគ.ភី. ប៊ីលីតុន និងសាជីវកម្មមិតស៊ុយប៊ីស៊ី ដើម្បីធ្វើការរុករករ៉ែបុកស៊ីតលើដីទំហំ ១០០.០០០ ហិកតា ក្នុងខេត្តមណ្ឌលគិរី ដែលត្រួតលើដីសម្បទានរបស់ក្រុមហ៊ុន អ៊ូជីសាន និងលាតសន្ធឹងលើដីប្រពៃណីរបស់ជនជាតិដើមភាគតិច។[81] រឿងមួយករណីទៀតជនជាតិដើមភាគតិចពូនងខេត្តមណ្ឌលគិរីជាង៥០គ្រួសារប្រឈមការបណ្តេញទាំងបង្ខំ និងពលរដ្ឋច្រើនគ្រួសារទៀតប្រឈមនឹងការបាត់បង់ដីសហគមន៍ដែលដូនតាបន្សល់ទុកច្រើនជំនាន់ ក្រោយអាជ្ញាធរអនុវត្តតាមអនុក្រឹត្យ

[78] របាយការណ៍សម្បទានសេដ្ឋកិច្ចនៅកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ចុះខែវិច្ឆកា ឆ្នាំ២០០៤
[79] ផ្លូវរបត់? សិទ្ធិដីធ្លី សិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា,សមាគមអាដហុក (ខែកុម្ភៈ ២០១៣)
[80] សម្រាប់ការវិភាគអំពីការផ្ទេរកម្មសិទ្ធិដីធ្លីរបស់ជនជាតិដើមភាគតិច ក្នុងខេត្តរតនគិរី សូមមើលរបាយការណ៍របស់វេទិកាអង្គការមិនមែន រដ្ឋាភិបាលស្តីពីកម្ពុជា ដែលមានចំណងជើងថា ការផ្ទេរកម្មសិទ្ធិដីធ្លីក្នុងសហគមន៍ជនជាតិដើមភាគតិច - ខេត្តរតនគិរី កម្ពុជា ខែសីហា ឆ្នាំ២០០៦ ដែលអាចរកឃើញតាម http://www.ngoforum.org.kh/Land/Docs/Dos4.htm
[81] របាយការណ៍សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្ស ចុះខែវិច្ឆកា ឆ្នាំ២០០៤

របស់រដ្ឋាភិបាលលើផ្ទៃដី២៥៥ហិកតាដោយធ្វើអនុប្បយោគឱ្យក្រុមហ៊ុនឯកជនមួយ។ រដ្ឋបាលខេត្តមណ្ឌលគិរី បានចេញសេចក្តីប្រកាសមួយនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០២៤នេះ ដោយតម្រូវឱ្យជនជាតិភាគតិចពូនងនៅភូមិពូរាំង ឃុំសែនមនោរម្យ ស្រុកអូររាំង ធ្វើការរុះរើផ្ទះ បង្គោលរបង និងសំណង់ផ្សេងៗរបស់ខ្លួនឱ្យអស់ពីដីចំនួន ២៥៥ហិកតា។

### ៣.១.៣.ផលប៉ះពាល់ជាមួយបរិស្ថានធម្មជាតិ

សម្បទានគោលដៅសេដ្ឋកិច្ចមានផលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថានយ៉ាងខ្លាំងជាអវិជ្ជមាន តាមរយៈគោលដៅក្នុងការប្រើប្រាស់ដីសម្បទានទាំងនោះ ។ ការកាប់ ឆ្ការព្រៃឈើ ដើម្បីយកដីដាំដុះដំណាំកសិ-ឧស្សាហកម្ម របស់សម្បទានិក នៅលើដីសម្បទានជាច្រើន បានបំផ្លិចបំផ្លាញធនធានធម្មជាតិប្រព័ន្ធបរិស្ថាន ជីវចម្រុះ ធ្វើឱ្យដំណាំ និង សត្វគ្រប់ប្រភេទថយចុះ បូករួមមានសំរាមដែលបំពុលបរិស្ថាន ការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត និង សារធាតុគីមីដទៃទៀតដែលធ្វើឲ្យប៉ះពាល់ដី ប្រភពទឹកឲ្យកខ្វក់ក្នុងរយៈពេលយូរទៅអនាគត និង បានធ្វើឲ្យប៉ះពាល់ដល់សុខភាពរបស់សមាជិកសហគមន៍ និង សត្វពាហនៈ របស់ពួកគេថែមទៀតផង។ លើសពីនេះទៅទៀត ជីវចម្រុះដែល រស់នៅក្នុងទឹកនោះ មានត្រី និងសត្វផ្សេងទៀត ក៏ងាប់ដោយសារសារធាតុគីមីនេះដែរ។ បន្ថែមពីនេះការកាប់បំផ្លាញព្រៃឈើគឺមានផលប៉ះពាល់អវិជ្ជមាន ដល់ការបម្រែបម្រួលអាកាសធាតុការឡើងកំដៅផែនដីថែមទៀតផង។ សម្បទានដីរបស់ក្រុមហ៊ុនភាពីម៉ិច ក្នុងស្រុកសាមគ្គីមានជ័យ នៅខេត្តកំពង់ឆ្នាំង ដែលធ្វើការដាំដើមប្រេងខ្យល់ ដែលនាំ ឲ្យមានការបំផ្លិតបំផ្លាញបរិស្ថានយ៉ាងធ្ងន់ធ្ងរ ដូចជាការធ្វើឲ្យស្ទឹងបឹងបួរ រីងហួត ធ្វើឲ្យ កំរិតទឹកក្រោមដីចុះទាប ធ្វើឲ្យដីមានជាតិអាស៊ីដ កាត់បន្ថយប្រព័ន្ធបរិស្ថាន ជីវចម្រុះនៅមូលដ្ឋាន និង ធ្វើឲ្យបាត់បង់គុណភាពដី។[82]

## ៣.២.ដំណោះស្រាយបញ្ហាវិវាទសម្បទានដីសេដ្ឋកិច្ច

វិវាទដីធ្លីដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជាបានកើតមានឡើងស្ទើរពាសពេញផ្ទៃប្រទេស ដែលបង្កជាផលវិបាកយ៉ាងខ្លាំងដល់រាជរដ្ឋាភិបាល និងស្ថាប័នតុលាការ។ វិវាទដីធ្លីគឺជាចំណោទបញ្ហាមួយដែលជាផលវិបាកចម្បងនៃការធ្វើសម្បទានដីសេដ្ឋកិច្ច ក្នុង ចំណោមផលប៉ះពាល់ដទៃទៀត ដូចជា ការប៉ះពាល់ដល់បរិស្ថាន និងក្តីបារម្ភពីការខាតបង់ផ្នែកសេដ្ឋកិច្ច និងអធិបតេយ្យជាតិជាដើម។ ដើម្បីឆ្លើយតបនឹងផលប៉ះពាល់វិវាទដីធ្លីដែលបណ្តាលមកពីសម្បទានដីសេដ្ឋកិច្ចនេះ ដំណោះស្រាយមួយចំនួនត្រូវបានលេចឡើងក្នុងនោះរួមមាន យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ និង យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ។

### ៣.២.២.យន្តការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ

[82] អត្ថបទ "គោលនយោបាយសម្បទានដីសេដ្ឋកិច្ច" ចូលមើលថ្ងៃទី ១៤ ខែមេសា ឆ្នាំ២០២៤

Alternative Dispute Resolution ឬ ADR មានន័យថាជាការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ។ វាសំដៅដល់វិធីផ្សេងៗដែលភាគីដែលមានវិវាទនឹងគ្នា អាចដោះស្រាយវិវាទបានក្រៅអំពីប្រព័ន្ធជំនុំជម្រះដែលមាន តាំងពីមុនមក ដែលមានការពឹងផ្អែកទាំងស្រុងលើតុលាការ។ ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រមូលផ្តុំ ទៅដោយទម្រង់ជាច្រើន នៃនីតិវិធីដោះស្រាយវិវាទ ដែលមួយចំនួនមានលក្ខណៈសាមញ្ញ និងខ្លះទៀតមានលក្ខណៈថ្មីប្លែក។[83] ដូចគ្នានេះដែល វិវាទដែលកើតមានឡើងនៅក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជាការដោះស្រាយវិវាទក្រៅ ប្រព័ន្ធតុលាការត្រូវបានគេយកមកអនុវត្ត មុននឹងឈានទៅដល់ការអនុវត្តការដោះស្រាយវិវាទក្នុងប្រព័ន្ធតុលាការ។ ប្រជាពលរដ្ឋដែលទទួលរងគ្រោះអំពីការផ្តល់សម្បទានដីសេដ្ឋកិច្ចអាចដាក់ពាក្យបណ្តឹងទៅ តាមស្ថាប័នដូចជា ក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ(ពាក្យបណ្តឹងដាក់នៅលេខាធិការដ្ឋាន បច្ចេកទេសនៃក្រសួងកសិកម្ម រុក្ខប្រមាញ់ និងនេសាទ) អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី (ពាក្យបណ្តឹង ដាក់ទៅអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី)។

នៅក្នុងការអនុវត្តដំណាក់កាលដោះស្រាយវិវាទដីធ្លីក្រៅប្រព័ន្ធតុលាការដែលបណ្តាលមកពី ការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះ ប្រជាពលរដ្ឋដែលរងគ្រោះអំពីការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលបានដាក់ពាក្យបណ្តឹងទៅតាមស្ថាប័នពាក់ព័ន្ធហើយនោះ ស្ថាប័នទាំងនោះនឹងធ្វើរបាយការណ៍ជូនអ្នកជំនាញពាក់ព័ន្ធដែលមានសមត្ថកិច្ចដោះស្រាយវិវាទដីធ្លីសម្បទានដីសេដ្ឋកិច្ចដូចជា៖

**គណៈកម្មការសុរិយោដី** ៖ គណៈកម្មការសុរិយោដីត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ៤៧, ៣១ ខែឧសភា ឆ្នាំ២០០២ ដោះស្រាយវិវាទមិនទាន់បានចុះបញ្ជីសុរិយោដីត្រូវបានបែងចែកជាបីថ្នាក់ដូចខាងក្រោម៖

**១.គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ** ៖ ចំពោះការទទួលពាក្យបណ្តឹងបុគ្គលគ្រប់រូបដែលមានវិវាទពាក់ព័ន្ធដីធ្លីមិនទាន់បានចុះបញ្ជីសុរិយោដីអាចដាក់ពាក្យបណ្តឹងផ្ទាល់ទៅគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌបាន។ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមានភារកិច្ចសម្រុះសម្រួលវិវាទ ដែលកើតមានឡើងនៅក្រៅ តំបន់វិនិច្ឆ័យ ការសម្រុះសម្រួលវិវាទ ត្រូវអនុវត្តតាមទម្លាប់ប្រពៃណី និងបច្ចេកទេសសុរិយោដី ។[84] គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌចាត់មន្ត្រីឲ្យចុះស៊ើបអង្កេត ដើម្បីជួបជាមួយគូភាគីវិវាទ សាក្សី អាជ្ញាធរមូលដ្ឋាន និងធ្វើការវាស់វែងកំណត់ទំហំដី និងព្រំប្រទល់ដីវិវាទឲ្យបានច្បាស់លាស់ដើម្បីងាយស្រួលរកដំណោះស្រាយសម្រុះសម្រួលជូនគូវិវាទ។ បន្ទាប់ពីបញ្ចប់ការស៊ើបអង្កេត គណៈកម្មការសុរិយោដីនឹងពិនិត្យមើលថាតើករណីវិវាទនោះស្ថិតក្នុងសមត្ថកិច្ចដោះស្រាយរបស់ខ្លួនឬទេ? ករណីមិនស្ថិត ក្នុងសមត្ថកិច្ចបណ្តឹងនោះត្រូវបាន

[83] សៀវភៅ "ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា ទស្សនៈទានសំខាន់ៗ" រៀបរៀងដោយមេធាវី ស្ទីវិន មើល អូស្ទើរមីគ្លីរ័បោះ ពុម្ពនៅខែមករា ឆ្នាំ២០១០ ទំព័រ១

[84] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈកម្មការសុរិយោដីលេខ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ឧសភា ២០០២ មាត្រា៦

ច្រានចោល ហើយត្រូវជូន ដំណឹងដល់ភាគីវិវាទជា លាយល័ក្ខណ៍អក្សរ។ ករណីភាគីវិវាទមិនពេញចិត្តចំពោះការច្រានចោល នោះ ភាគីវិវាទនោះអាចប្តឹងទៅគណៈកម្មការសុរិយោដីថ្នាក់លើបន្ទាប់ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃ បន្ទាប់ពីភាគីទទួលបានសេចក្តីជូនដំណឹង ឬទម្រង់បែបបទច្រានចោលពាក្យបណ្តឹងនោះ។[85] ក្នុងនោះ ភាគីវិវាទអាច ធ្វើការជ្រើសរើសអ្នកសម្រុះសម្រួល៣រូបនិងទទួលព័ត៌មានអំពីសិទ្ធិរបស់ ខ្លួនក្នុងការជ្រើសរើស បុគ្គលណាម្នាក់ដែលភាគីជឿថាអាចជួយខ្លួនបានក្នុងនាមជាជំនួយការភាគីដែលតួនាទីរបស់ជំនួយការនោះគឺផ្តល់កិច្ចពិគ្រោះយោបល់ដល់ភាគី អំពីដំណើរការប្រព្រឹត្តទៅនៃវិវាទនោះ។ ទោះបីជាយ៉ាងណាក៏ដោយជំនួយការមិនអាចនិយាយ តាងនាមឱ្យភាគី ឬនិយាយជំនួសភាគីនៅពេលណាមួយនៃដំណើរការសម្រុះសម្រួលវិវាទបានឡើយ ។ ប្រសិនបើការដោះស្រាយអាចសម្រេចបានដោយមានការព្រមព្រៀងជាឯកច្ឆន្ទពីភាគីវិវាទ គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌត្រូវធ្វើរបាយការណ៍ជូនគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ហើយត្រូវចម្លងជូនការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌ មួយច្បាប់ ដើម្បីចាប់ផ្តើម ដំណើរការអនុវត្តនីតិវិធីនៃការចុះបញ្ជីក្បាលដីដែលបានដោះស្រាយរួច។ ប្រសិនបើការដោះស្រាយមិនអាចសម្រេចបាន គណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ត្រូវបញ្ជូន វិវាទរួមជាមួយនឹងរបាយការណ៍ជាលាយលក្ខអក្សរ ស្តីពីការសម្រុះសម្រួលជូនគណៈកម្មការសុរិយោដី ថ្នាក់ខេត្ត ក្រុង។[86] គណៈកម្មការសុរិយោដីថ្នាក់ ស្រុកខណ្ឌមានសមត្ថកិច្ចត្រឹមតែសម្រុះសម្រួលវិវាទ ដែលកើតឡើង មិនមានសិទ្ធិធ្វើសេចក្តីសម្រេចទេ។

**២. គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ៖** គណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងនឹងព្យាយាមធ្វើការសម្រុះសម្រួលបន្តទៀតតាម នីតិវិធី ដែលបានកំណត់ក្នុងច្បាប់ដែលបានចូលជាធរមានហើយនោះ។ ចំពោះគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង ដោះស្រាយ វិវាទពីរប្រភេទដែលទាក់ទងវិវាទប្រភេទទីមួយរួមមាន ករណីវិវាទទាំងឡាយដែលបានបញ្ជូនមកដោយផ្ទាល់ ពីគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ ដោយសារតែគណៈកម្មការសុរិយោដីស្រុក ខណ្ឌ មិនមានអំណាចធ្វើ ការសម្រុះសម្រួលវិវាទទាំងនោះដែលមានហេតុផលដូចជាជនម្នាក់ទាមទារដីច្រើនក្បាល ដែលជាកម្មវត្ថុនៃការប្តឹងទាមទាររបស់ភាគីតូចតាចមួយចំនួន ដែរ ភាគីម្ខាងនៃវិវាទគឺជាអជ្ញាធរមានឋានៈខ្ពស់ករណីមានវិវាទពាក់ព័ន្ធនឹងផលប្រយោជន៍របស់ ប្រធានគណៈកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌ នឹង វិវាទពាក់ព័ន្ធដីសាធារណៈរបស់រដ្ឋ។ ប្រភេទវិវាទទីពីរ រួមមាន ករណីវិវាទដែលបានបញ្ជូនមកពីគណៈកម្មការសុរិយោដីស្រុក ខណ្ឌ ដោយសារភាគីវិវាទមិនអាចឈានទៅដល់កិច្ចព្រមព្រៀង។ ប៉ុន្តែចំពោះករណីវិវាទទីពីរនេះ ការសម្រុះសម្រួលដោយគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គឺផ្តល់ឱ្យភាគីវិវាទ នូវ

[85] ប្រកាសស្តីពីគោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដី,លេខ ១១២ដនស/ប្រក,២១ សីហា ២០០២ ប្រការ២០

[86] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈកម្មការសុរិយោដីលេខ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ឧសភា ២០០២ មាត្រា១១

ឱកាសមួយលើកឡើងដើម្បីសម្រុះសម្រួលវិវាទនោះ ហើយដើម្បីឱ្យឈានទៅដល់ការដោះស្រាយមួយដែលជាប្រយោជន៍ទៅវិញទៅមក។ ចំពោះការសម្រុះសម្រួលនៅគណៈកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុង គឺដូចគ្នាសុទ្ធសាធ ទៅនឹងដំណើរការដោះស្រាយវិវាទនៅថ្នាក់ស្រុក ខណ្ឌដែលបានធ្វើការរៀបរាប់ខាងលើ ហើយផ្តល់ឱ្យភាគីវិវាទនូវ ឱកាសម្តងទៀតដើម្បីសម្រុះសម្រួលវិវាទ និងឈានទៅដល់ការព្រមព្រៀងដែលបំរើផលប្រយោជន៍ទៅវិញទៅមកទាំងសងខាង។ ហើយរាល់ដំណោះស្រាយនឹងត្រូវកត់ត្រាទុក និងត្រូវបញ្ជូនទៅការិយាល័យរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងភូមិបាលស្រុក ខណ្ឌដើម្បីចុះបញ្ជីក្បាលដី។ ចំណែកឯវិវាទដែលមិនអាចដោះស្រាយបាននឹងត្រូវដាក់ជូនគណៈកម្មការសុរិយោដីថ្នាក់ជាតិ។ ក្នុងរយៈពេល៦០ (ហុកសិប) ថ្ងៃ បន្ទាប់ពីបានទទួលបណ្តឹងវិវាទរបស់គណៈកម្មការសុរិយោដីខេត្ត ក្រុងត្រូវរៀបចំកិច្ចប្រជុំ រដ្ឋបាលរវាង គណៈកម្មការសុរិយោដីខេត្ត ក្រុង និងភាគីវិវាទ។ ប៉ុន្តែបើការសម្រុះសម្រួលមិនអាចទទួលបានជោគជ័យទេនោះគណៈកម្មការសុរិយោដីថ្នាក់រាជធានី ខេត្ត នឹងមាននីតិវិធីដោយឡែកផ្សេងទៀត គឺការធ្វើ សេចក្តីសម្រេច។[87] ផ្ទុយទៅវិញ បើភាគីវិវាទណាមួយមិនសុខចិត្តចំពោះការសម្រេចរបស់គណៈកម្មការសុរិយោដីថ្នាក់ខេត្តក្រុង ក្នុងរយៈពេល ៣០ (សាមសិប) ថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីទទួលបានសេចក្តីសម្រេចឬទទួលបានព័ត៌មានអំពី សេចក្តីសម្រេចភាគីវិវាទនោះមានសិទ្ធិប្តឹងស្នើសុំគណៈកម្មការសុរិយោដីថ្នាក់ជាតិឲ្យធ្វើសវនាការ។

**៣.គណៈកម្មការសុរិយោដីថ្នាក់ជាតិ** ៖ គណៈកម្មការសុរិយោដីថ្នាក់ជាតិ នឹងព្យាយាមធ្វើការសម្រុះសម្រួលបន្តនូវវិវាទ។ តែបើការសម្រុះសម្រួលមិនអាចទទួលបានជោគជ័យ។ គណៈកម្មការសុរិយោដីថ្នាក់ជាតិនឹងបើកសវនាការសម្រេច។ ទោះបីជាគណៈកម្មការសុរិយោដីថ្នាក់ជាតិបើកសវនាសម្រេចលើវិវាទបែបនោះក៏ដោយក៏នៅ តែបើកផ្លូវឲ្យគូភាគីប្តឹងតវ៉ានឹងសេចក្តីសម្រេចនេះទៅតុលាការក្នុងរយៈពេល៣០ (សាមសិប) ថ្ងៃក្រោយពីបានទទួលសេចក្តីសម្រេច។[88] ប្រសិនបើជោគជ័យក្នុងការសម្រុះសម្រួល ឬសេចក្តីសម្រេចបានដល់សុពលភាព អាចអនុវត្តបាន គណៈកម្មការសុរិយាដីថ្នាក់ជាតិ ត្រូវធ្វើសេចក្តីសម្រេច នោះទៅឱ្យមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្ត ក្រុង ដើម្បីធ្វើការចាត់ចែង ចុះបញ្ជី ក្បាលដីតាមនីតិវិធីដែលបានកំណត់នោះ។

**អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី** ៖ មានតួនាទីបំពេញមុខងារបន្ថែមពីគណៈកម្មការសុរិយោដី និងត្រូវបានផ្តល់សិទ្ធិឱ្យធ្វើសវនកម្មលើករណីទំនាស់ដីធ្លីនានាដែល "ផុតពីដែនយុត្តាធិការ" របស់ គណៈកម្មការសុរិយោដី គឺអាចដោះស្រាយវិវាទពាក់ព័ន្ធនឹងទំនាស់ដីធ្លីទាំងដីដែលបានចុះបញ្ជីសុរិយោដី ឬ ដីមិនទាន់ចុះបញ្ជី

[87] ប្រកាសស្តីពីការធ្វើប្រតិភូកម្មមុខងារជូនអភិបាលនៃគណៈអភិបាលរាជធានី ខេត្ត និងជាប្រធានគណៈកម្មការសុរិយោរាជធានី ខេត្តដើម្បីធ្វើសេចក្តី សម្រេចលើសំណុំរឿងវិវាទដីធ្លីក្នុងយន្តការគណៈកម្មការសុរិយោដី លេខ០៣២ប្រក.ដនស/គសជ,២១ មករា ២០១០ មាត្រា១

[88] អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅគណៈកម្មការសុរិយោដីលេខ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ឧសភា ២០០២ មាត្រា២៣

សុរិយោដីផងដែរ។ អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានមុខងារសំខាន់ៗដូចជាទប់ស្កាត់ និងកាត់បន្ថយទំនាស់ដីធ្លីតាមរយៈការអប់រំផ្សព្វផ្សាយឱ្យសាធារណៈជនបានយល់ដឹងពីផលវិបាកដែលបណ្តាលមកពីទំនាស់ដីធ្លី និងមានវិធាន ការដាក់វិន័យចំពោះជនល្មើសដែលបានរំលោភបំពានលើបញ្ហាដីធ្លីដោយខុសច្បាប់ជាធរមាន។ ទទួលសំណុំ រឿងដីធ្លីដែលហួសពីសមត្ថកិច្ចរបស់គណៈកម្មការសុរិយោដីថ្នាក់ជាតិ និងទទួលពាក្យបណ្តឹងពីគ្រប់មជ្ឈដ្ឋាន ដែលមានពាក់ព័ន្ធទំនាស់ដីធ្លី និងស្វែងយល់ស៊ើបអង្កេត និងដោះស្រាយទំនាស់ដីធ្លី ឃ្លាំមើលការដោះស្រាយ ទំនាស់ដីធ្លីរបស់គណៈកម្មការសុរិយោដី និងអាជ្ញាធរមានសមត្ថកិច្ចគ្រប់ជាន់ថ្នាក់ និងធ្វើរបាយការណ៍អំពីលទ្ធផលការងារនៃការដោះស្រាយទំនាស់ដីធ្លីដាក់ជូនប្រមុខរាជរដ្ឋាភិបាល។[89] ក្នុងពេលដោះស្រាយរបស់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី ក៏មានអគ្គលេខាធិការដ្ឋានជាសេនាធិការចូលរួមផងដែលមានបេសកកម្មជួយអាជ្ញាធរក្នុងការ ដោះស្រាយ សម្របសម្រួលចំពោះរាល់វិវាទដីធ្លីរៀបចំរបាយការណ៍និងផ្សព្វផ្សាយជូនសាធារណជនអំពីលទ្ធផលនៃដំណោះស្រាយទំនាស់ដីធ្លី ដែលអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី បានដោះស្រាយចប់ជាស្ថាពរ។ ជារួមអគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានភារកិច្ចដូចកំណត់ក្នុងមាត្រា ៥ នៃព្រះរាជក្រឹត្យ លេខ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី ២៦ ខែ កុម្ភៈ ឆ្នាំ ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយ ទំនាស់ដីធ្លី ។ ទន្ទឹមនឹងនេះ យោងតាមការសម្រេចរបស់ប្រធានអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី អគ្គលេខាធិការដ្ឋាន នៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី មានសិទ្ធិចេញលិខិតណែនាំឱ្យផ្អាកជាបណ្តោះអាសន្នទីតាំងទំនាស់ មិនឱ្យធ្វើសកម្មភាពផ្សេងៗ ក្រោយពីទទួលពាក្យបណ្តឹង ឬពាក្យសុំអន្តរាគមន៍ពីគូវិវាទ។[90]

### ៣.២.៣.យន្តការដោះស្រាយវិវាទតាមប្រព័ន្ធតុលាការ

បន្ទាប់ពីបានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរួចមក ចំពោះអ្នកដែលមិនសុខចិត្ត គឺអាចមានសិទ្ធិក្នុងការប្តឹងមកតុលាការដែលមានសមត្ថកិច្ចបាន ។ ភាគីមិនសុខចិត្តអាចដាក់ពាក្យបណ្តឹងដាក់ទៅសាលាដំបូង ខេត្ត ក្រុង ដែលសម្បទានដីសេដ្ឋកិច្ចតាំងនៅ។

ស្ថាប័នតុលាការ គឺជាស្ថាប័នដែលឯករាជ្យដែលមានសមត្ថកិច្ចដោះស្រាយគ្រប់រឿងក្តីទាំងអស់ រួមទាំងរឿងក្តីរដ្ឋបាលផងដែរ។[91] វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួច ត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការ។ ចំពោះវិវាទដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី បើយោងតាមការបែងចែកសមត្ថកិច្ចរវាងគណៈកម្មការសុរិយោដី និង

[89] ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ មាត្រា៣

[90] អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ៦៥អនក្រ/បក ១៦ កក្កដា ២០០៦ មាត្រា៣

[91] រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣ មាត្រា១២៨ថ្មី

ស្ថាប័នតុលាការត្រូវបានកំណត់ ដោយប្រកាសអន្តរក្រសួង រវាងក្រសួងយុត្តិធម៌ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ស្តី ពីការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងវិវាទដីធ្លី។ អនុលោមតាមខ្លឹមសារនៃប្រកាសខាងលើនេះ តុលាការ និងគណៈកម្មការសុរិយោដីត្រូវមានសមត្ថកិច្ចរៀងៗខ្លួន តាមការបែងចែក។ គណៈកម្មការសុរិយោដីត្រូវធ្វើការដោះស្រាយវិវាទទាំងឡាយណាដែលពាក់ព័ន្ធទៅនឹងដីមិនទាន់ ចុះបញ្ជីសុរិយោដី លើកលែងតែវិវាទអំពីការបែងចែកមត៌ក រវាងអ្នកទទួលមត៌ក និងវិវាទអំពីកិច្ចសន្យា ទិញលក់ ជួល បញ្ចាំជាដើម ករណីវិវាទប្រភេទនេះស្ថិតនៅក្រោមយុត្តាធិការរបស់តុលាការ។[92] ចំណុចនេះ ធ្វើឱ្យកើតមានចម្ងល់មួយ ចំនួនចំពោះអ្នកច្បាប់ ថាតើវាអាចរំលោភលើអធិបតេយ្យភាពរបស់តុលាការដែរ ឬទេ ? ព្រោះអំណាច តុលាការជាអំណាចឯករាជ្យ។ ជាការពិតណាស់ចំពោះវិវាទពាក់ព័ន្ធនឹងដីធ្លីមិនទាន់ចុះបញ្ជីសុរិយោដី តុលាការក៏មានសមត្ថកិច្ចផងដែរ។ ប្រសិនបើករណីនោះពាក់ព័ន្ធនឹងដីធ្លីដែលមិនទាន់ចុះបញ្ជីភាគីត្រូវតែបញ្ជូនករណីនោះជាដំបូងទៅ កាន់គណៈកម្មាធិការសុរិយោដី ដើម្បីដោះស្រាយជាមុនមុនពេលដែលឈានដល់តុលាការ ជាយន្តការមួយដើម្បីសម្រួលដល់តុលាការ ជៀសវាងការកកស្ទះសំណុំរឿងនៅតុលាការផងដែរ។ ដូច្នេះបន្ទាប់ពីបានដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការរួចមក ចំពោះភាគីវិវាទនៅតែមិនសុខចិត្តចំពោះសេចក្តីសម្រេច ដែលធ្វើឡើងដោយ គណៈកម្មការសុរិយោដី ឬអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីគឺអាចមានសិទ្ធិក្នុងការប្តឹងមកស្ថាប័នតុលាការដែលមានសមត្ថកិច្ច។

ការដោះស្រាយករណីវិវាទនេះឡើងវិញតាមប្រព័ន្ធតុលាការចាប់ពីសាលាដំបូង សាលាឧទ្ធរណ៍ ដល់តុលាការកំពូល។ នីតិវិធីក្នុងការដោះស្រាយវិវាទដីធ្លីតាមផ្លូវតុលាការ មានលក្ខណៈដូចទៅនឹងការដោះស្រាយវិវាទរដ្ឋប្បវេណី ផ្សេងៗទៀតដែរ ដូចជាវិវាទកិច្ចសន្យាលក់ ទិញ វិវាទរដ្ឋបាល និងវិវាទការងារផងដែរ។ នីតិវិធីនៃការដោះស្រាយ ប្រភេទនេះ គឺត្រូវអនុវត្តតាមក្រមនីតិវិធីរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជាដែលបានចុះនៅថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០០៦។

ម្យ៉ាងទៀត សម្រាប់ដីការសម្រេចរបស់តុលាការ គឺជាការសម្រេចបិទផ្លូវតវ៉ា ដោយមានន័យថាបណ្តឹងរបស់ភាគីវិវាទ មិនអាចប្រព្រឹត្តនៅការដោះស្រាយក្រៅប្រព័ន្ធតុលាការបានម្តងទៀតទេ។

[92] ប្រកាសអន្តរក្រសួងស្តីពី ការកំណត់ការកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿង វិវាទដីធ្លី លេខ ០២ ប្រក ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣ មាត្រា៤

# សេចក្តីសន្និដ្ឋាន

គ្រប់រាល់សកម្មភាពទាំងអស់ដែលរាជរដ្ឋាភិបាលបានធ្វើឡើង គឺដើម្បីអភិវឌ្ឍប្រទេសជាតិឲ្យមានការរីកចម្រើនទៅមុខ។ ការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះ គឺជាវិធីសាស្ត្រមួយក្នុងទាក់ទាញអ្នកវិនិយោគធំៗ ឲ្យមកធ្វើការវិនិយោគក្នុងព្រះរាជាណាចក្រកម្ពុជា។ សម្បទានដីសេដ្ឋកិច្ចសំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិកដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម។ ពោលគឺសម្បទាននេះត្រូវឆ្លើយតបនឹងផលប្រយោជន៍សេដ្ឋកិច្ចជាតិ តែយើងសង្កេតឃើញថាដោយរាល់សកម្មភាពនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចទាំងនេះតែងតែមាន ភាពស្មុគស្មាញ និងមានផលប៉ះពាល់ជាមួយប្រជាពលរដ្ឋ ជនជាតិដើមភាគតិច និងបញ្ហាបរិស្ថានដែលនៅក្នុងតំបន់នៃការផ្តល់ដីសម្បទានសេដ្ឋកិច្ច។ ដោយមើលឃើញពីបញ្ហាទាំងនេះ រាជរដ្ឋាភិបាលបានបង្កើតនូវបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការផ្តល់សម្បទានដីសេដ្ឋកិច្ចនេះ ដែលមានដូចជា ច្បាប់ភូមិបាលឆ្នាំ២០០១ និងសេដ្ឋកិច្ចជាពិសេសអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចឆ្នាំ២០០៥ និងលិខិតបទដ្ឋានគតិយុត្តិពាក់ព័ន្ធផ្សេងៗ ដែលមានគោលដៅកំណត់លក្ខខណ្ឌលក្ខណៈវិនិច្ឆ័យ នីតិវិធីយន្តការ និងការរៀបចំស្ថាប័នសម្រាប់ការផ្តួចផ្តើមនិងការផ្តល់សម្បទានដីសេដ្ឋកិច្ចដែលឆ្លើយតបទៅនឹងគោលដៅសង្គម និងសេដ្ឋកិច្ច។

យោងតាមការសិក្សាស្រាវជ្រាវខាងលើ យើងខ្ញុំសូមធ្វើការសន្និដ្ឋានចំពោះបញ្ហាបីចំណុចដែលបានលើកឡើងក្នុងចំណោទបញ្ហានៃការស្រាវជ្រាវនេះ។ ដែលចំណុចទាំងបីនោះរួមមាន៖ ទីមួយ តើការផ្តល់សម្បទានដីសេដ្ឋកិច្ចមានលក្ខណៈដូចម្តេច? ទីពីរ តើមាននីតិវិធីអ្វីខ្លះក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច? ទីបី តើមានដំណោះស្រាយបែបណាខ្លះក្នុងការដោះស្រាយផលប៉ះពាល់ដែលកើតមានទាំងនោះ?

ខាងក្រោមនេះយើងនឹងធ្វើការសន្និដ្ឋានចំពោះបញ្ហាដែលបានលើកឡើងខាងលើនេះ៖

+ទីមួយ ការផ្តល់សម្បទានដីសេដ្ឋកិច្ចមានដូចជា ១. បទប្បញ្ញត្តិទូទៅ ២. គោលការណ៍នៃការផ្តល់សម្បទានដីសេដ្ឋកិច្ច ។

ចំពោះបទប្បញ្ញត្តិទូទៅ នៅពេលដែលមានអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ចនៅឆ្នាំ២០០៥មកអនុវត្តគេសង្កេតឃើញថាបទប្បញ្ញត្តិទូទៅនេះត្រូវបានចែងមុនដំបូងគេត្រង់មាត្រា១នៃអនុក្រឹត្យនេះ។ នៅក្នុងនោះត្រង់ចំណុចបទប្បញ្ញត្តិទូទៅនេះបាននិយាយរៀបរាប់អំពីលក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័នសម្បទានដីសេដ្ឋកិច្ច ពិសេសសម្រាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមានស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ ២០០១ ។

ចំពោះគោលការណ៍នៃការផ្តល់សម្បទានដីសេដ្ឋកិច្ចគឺជាការប្រគល់ដីដែលជាកម្មសិទ្ធិឯកជនរបស់រដ្ឋដោយអាជ្ញាធរមានសមត្ថកិច្ចរបស់រដ្ឋទៅឲ្យរូបវន្តបុគ្គលឬនីតិបុគ្គលដើម្បីកាន់កាប់និងប្រើប្រាស់តាមការកំណត់

នៃច្បាប់។ អ្នកទទួលបានសម្បទានដីពីរដ្ឋាភិបាលត្រូវ មានសិទ្ធិដាំដុះ និងធ្វើអាជីវកម្មកសិឧស្សាហកម្ម។ ហើយមុននឹងឈានដល់ដំណាក់កាលសម្រេចផ្តល់ដីសម្បទានដីសេដ្ឋកិច្ចទៅ ឲ្យសម្បទានិករដ្ឋាភិបាលក៏ត្រូវមានគម្រោងផែនការក្នុងការកំណត់នូវលក្ខខណ្ឌទូទៅមួយចំនួន ដែលតម្រូវ ឱ្យសម្បទានិកត្រូវតែបំពេញមុនការផ្តល់ដីសម្បទានសេដ្ឋកិច្ចមានដូចជា៖ លក្ខណៈវិនិច្ឆ័យលើប្រភេទដី លក្ខណៈសម្បត្តិរបស់សម្បទានិក លក្ខណៈវិនិច្ឆ័យលើសំណើសម្បទានដីសេដ្ឋកិច្ចនិង រយៈពេលនៃទំហំដីការផ្តល់សម្បទានដីសេដ្ឋកិច្ច។

+ទីពីរ ចំពោះនីតិវិធីនៃការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅព្រះរាជាណាចក្រកម្ពុជាត្រូវបានធ្វើឡើងក្នុងរូបភាពពីរផ្សេងគ្នាគឺការផ្តួចផ្តើមគម្រោងដោយអាជ្ញាធរមានសមត្ថកិច្ច និងការផ្តួចផ្តើមគម្រោងដោយអ្នកវិនិយោគ។ បន្ទាប់ពីមានព្រមព្រៀងយល់ស្របគ្នាក្នុងគម្រោងរួចអាជ្ញាធរមានសមត្ថកិច្ចរួមជាមួយវិនិយោគិនត្រូវចុះកិច្ចសន្យាជាមួយគ្នាហើយសម្បទានិកត្រូវគោរពតាមលក្ខខណ្ឌក្នុងពេលអនុវត្តតាមកិច្ចសន្យាសម្បទាន។

+ទីបី ការដោះស្រាយវិវាទដែលមានផលប៉ះពាល់ក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច៖

**ការដោះស្រាយក្រៅប្រព័ន្ធតុលាការ៖** ដូចបានរៀបរាប់ខាងលើវិវាទដែលកើតមានឡើងនៅក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ចនៅកម្ពុជាអាចធ្វើការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការបាន។ សម្រាប់ការដាក់ពាក្យបណ្តឹងក្រៅប្រព័ន្ធតុលាការប្រជាពលរដ្ឋដែលទទួលរងគ្រោះអំពីការផ្តល់សម្បទានដីសេដ្ឋកិច្ច អាចដាក់ពាក្យបណ្តឹងទៅតាម ស្ថាប័នដូចជាក្រសួងកសិកម្មរុក្ខាប្រមាញ់ នេសាទ និងអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី។ សម្រាប់សមត្ថកិច្ចដោះស្រាយវិវាទដីធ្លីសម្បទានដីសេដ្ឋកិច្ចរួមមានគណកម្មការសុរិយោដីថ្នាក់ស្រុក ខណ្ឌមានសមត្ថកិច្ចត្រឹមតែសម្រុះសម្រួលវិវាទប៉ុណ្ណោះ។ សម្រាប់គណកម្មការសុរិយោដីថ្នាក់ខេត្ត ក្រុងនិងថ្នាក់ជាតិប្រសិនបើការ សម្រុះសម្រួលមិនអាចទទួលបានជោគជ័យទេនោះគឺមាននីតិវិធីដោយឡែកផ្សេងទៀតគឺការធ្វើសេចក្តីសម្រេច។ គណៈកម្មការនេះមានភារកិច្ចដើម្បីដោះស្រាយតែវិវាទដីធ្លីណាដែលមិនទាន់ចុះបញ្ជី។ សម្រាប់អាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លីមានតួនាទីដោះស្រាយវិវាទដី និង បំពេញមុខងារបន្ថែមពីគណៈកម្មការសុរិយោដី។ ការដោះស្រាយគឺទំនាស់ដីធ្លីទាំងដីដែលបានចុះ ឬ ដីមិនទាន់ចុះបញ្ជីសុរិយោដីផងដែរ ។

**ការដោះស្រាយក្នុងប្រព័ន្ធតុលាការ៖** សម្រាប់នីតិវិធីស្នើសុំដោះស្រាយទំនាស់ដីធ្លីក្នុងប្រព័ន្ធតុលាការរបស់ប្រទេសកម្ពុជាទាក់ទងនឹងការផ្តល់សម្បទានដីសេដ្ឋកិច្ចគឺនៅពេលដែលភាគីណាមួយមិនសុខចិត្តនិងការធ្វើសេចក្តីសម្រេចការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការភាគីអាចទៅដាក់ពាក្យបណ្តឹង បាននៅសាលាដំបូងខេត្ត ក្រុង ដែលសម្បទានដីសេដ្ឋកិច្ចតាំងនៅ។ វិវាទដីធ្លីដែលបានចុះបញ្ជីសុរិយោដីរួចត្រូវស្ថិតនៅក្នុងសមត្ថកិច្ចរបស់តុលាការ។ ករណីវិវាទដីធ្លីដែលមិនទាន់ចុះបញ្ជីសុរិយោដីតុលាការទទួលដោះស្រាយបន្តបន្ទាប់ពីការដោះស្រាយក្រៅប្រព័ន្ធតុលាការមិនសម្រេច។ រាល់សេចក្តីសម្រេចរបស់តុលាការ គឺជាការសម្រេចបិទផ្លូវតវ៉ា ដោយមានន័យថាបណ្តឹង របស់ភាគីវិវាទ មិនអាចប្រព្រឹត្តនៅការដោះស្រាយក្រៅប្រព័ន្ធតុលាការបានម្តងទៀតទេ។

# អនុសាសន៍

យោងតាមការបកស្រាយទៅលើអត្ថន័យ និងខ្លឹមសារជាច្រើនរួចមក យើងអាចដឹងច្បាស់ថាការផ្តល់ដីសម្បទានដីសេដ្ឋកិច្ចនៅប្រទេសកម្ពុជា គឺជាវិធីសាស្ត្រតែមួយគត់ដែលមិនអាចមើលរំលងបានឡើយ ព្រោះសម្បទានដីសេដ្ឋកិច្ច បានចូលរួមចំណែកជួយលើកស្ទួយកំណើនសេដ្ឋកិច្ចជាតិឲ្យរីកចម្រើន ប៉ុន្តែគោលនយោបាយរបស់រដ្ឋាភិបាលនេះក៏បណ្តាលឲ្យមានផលប៉ះពាល់ដល់ប្រជាពលរដ្ឋ ផលប៉ះពាល់ដល់ជនជាតិដើមភាគតិច និងផលប៉ះពាល់ដល់បរិស្ថានផងដែរ។ល។

ដើម្បីជាដំណោះស្រាយបញ្ហាដែលកើតមានឡើង យើងខ្ញុំទាំងពីរនាក់សូមលើកឡើងនូវមតិយោបល់មួយចំនួនដើម្បីឲ្យការផ្តល់សម្បទានដីសេដ្ឋកិច្ចមានដំណើរការល្អ និងទទួលបានសមិទ្ធផលគួរជាទីពេញចិត្តមានដូចតទៅៈ

- សូមអំពាវនាវដល់រាជរដ្ឋាភិបាល គួរតែធ្វើការសិក្សាពិនិត្យការប្រមាណមើល និងវាយតម្លៃពីផលប៉ះពាល់បន្ថែមដែលអាចកើតមានឡើងនៅពេលមានការផ្តល់សម្បទានដីសេដ្ឋកិច្ចដោយត្រូវបង្កើនការប៉ាន់ប្រមាណអំពីផលប៉ះពាល់ទាំងឡាយនៅពេលមុនការអនុវត្ត ក្នុងអំឡុងពេលអនុវត្តការផ្តល់ដីសម្បទានដីសេដ្ឋកិច្ច និងក្រោយពេលអនុវត្តការផ្តល់ដីសម្បទានដីសេដ្ឋកិច្ច ដោយយោងតាមបទបញ្ញត្តិច្បាប់ជាធរមាន ដើម្បីកាត់បន្ថយផលប៉ះពាល់អវិជ្ជមាន។
- ការទទួលខុសត្រូវខាងស្ថាប័ន និងអាជ្ញាធរដែលមានសមត្ថកិច្ចពាក់ព័ន្ធ ត្រូវត្រួតពិនិត្យ តាមដាននឹងអនុវត្តកិច្ចតាមសន្យាសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់រួចហើយទៅឲ្យវិនិយោគិន ឬក្រុមហ៊ុនឯកជនពិសេសគោលនយោបាយរូបមន្តស្បែកខ្លារបស់រដ្ឋាភិបាល បើសិនមានវិនិយោគិន ឬក្រុមហ៊ុនឯកជនណាមួយមិនបានអនុវត្តតាម ច្បាប់ភូមិបាល និងអនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច និង កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច គួរតែលុបចោល និងដកហូតយកដីសម្បទានដីសេដ្ឋកិច្ចនោះមកវិញ ហើយដាក់ក្រោមការគ្រប់គ្រងរបស់រដ្ឋដោយផ្ទាល់។
- ការទទួលខុសត្រូវរបស់អាជ្ញាធរមានសមត្ថកិច្ចសម្រាប់ការផ្តល់សំណងសមរម្យនិងយុត្តិធម៌ជូនដល់ប្រជាពលរដ្ឋ ឬជនជាតិដើមភាគតិចដែលទទួលរងផលប៉ះពាល់។ ធានាមិនឱ្យមានការទន្ទ្រានលើដីដែលជាកម្មសិទ្ធិ និង ដែលសហគមន៍ប្រើប្រាស់ ។
- ទប់ស្កាត់ឲ្យបានព្រមទាំងធានាថា សម្បទានដី សេដ្ឋកិច្ច មិនត្រូវបានផ្តល់នៅលើដីព្រៃ ឬអតីតតំបន់ព្រៃសម្បទានហើយការពារសិទ្ធិប្រើប្រាស់ព្រៃឈើ និងដីជាប្រពៃណីរបស់សហគមន៍។ ធានាការគោរពច្បាប់ស្តីពីព្រៃឈើ បទបញ្ញាស្តីពីព្រៃឈើ និងច្បាប់ស្តីពីការពារបរិស្ថាននិងការគ្រប់គ្រងធនធានធម្មជាតិ ។

## ឯកសារយោង

- **រដ្ឋធម្មនុញ្ញ**
  - រដ្ឋធម្មនុញ្ញព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ១៩៩៣
- **ច្បាប់ ព្រះរាជក្រឹត្យនិងអនុក្រឹត្យ**
  - ក្រមរដ្ឋប្បវេណីនៃព្រះរាជាណាចក្រកម្ពុជា,លេខ នស/រកម/១២០៧/០៣០,ថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧
  - ច្បាប់ស្តីពីការអនុវត្តក្រមរដ្ឋប្បវេណី នៃ ព្រះរាជាណាចក្រកម្ពុជាលេខនស/រកម/០៥១១/០០៧ចុះថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១១
  - ច្បាប់ភូមិបាល,លេខ នស/រកម/០៨០១/១៤,៣០ សីហា ២០០១
  - ច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ, លេខ នស/រកម/ ១១២០/០៣០, ០៦ ខែតុលា ឆ្នាំ២០២០
  - ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ ១៩៩៦
  - ច្បាប់ស្តីពីវិនិយោគនៃព្រះរាជាណាចក្រកម្ពុជា នស/រកម/១០២១/០១៤ ចុះថ្ងៃទី២៩ ខែកញ្ញា ឆ្នាំ២០២១
  - ព្រះរាជក្រឹត្យស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ នឹងព្រះរាជក្រឹត្យលេខ នស/រកត/១០០៨/១១០៦ ចុះថ្ងៃទី ០៩ ខែ តុលា ឆ្នាំ ២០០៨ ស្តីពីវិសោធនកម្មមាត្រា១ នៃព្រះរាជក្រឹត្យ នស/រកត/០២០៦/០៩៧ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៦ ស្តីពីការបង្កើតអាជ្ញាធរជាតិដោះស្រាយវិវាទដីធ្លី
  - ព្រះរាជក្រឹត្យស្តីពីគោលការណ៍ និងបញ្ញត្តិអន្តរកាលនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ,លេខនស/រកត/០៨/០៦/៣៣៩,០៣ សីហា ២០០៦
  - អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៤៦អនក្រ/បក,២៧ ធ្នូ ២០០៥
  - អនុក្រឹត្យស្តីពីការកែសំរួល អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៣១អនក្រ/បក,១៥ កញ្ញា ២០០៨
  - អនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ,លេខ១១៨អនក្រ/បក, ០៧ តុលា ២០០៥
  - អនុក្រឹត្យស្តីពីការដាក់បញ្ចាំ ការផ្ទេរនូវសិទ្ធិលើការជួលរយៈពេលវែង ឬសិទ្ធិសម្បទានដី សេដ្ឋកិច្ច, លេខ១១៤អនក្រ/បក,២៩ សីហា ២០០៧
  - អនុក្រឹត្យស្តីពីវិធាន និងនីតិវិធីនៃការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ និងរបស់នីតិបុគ្គលសាធារណៈ,លេខ១២៩ អនក្រ/បក,២៧ វិច្ឆិកា ២០០៦
  - អនុក្រឹត្យស្តីពីការរៀបចំ និងការប្រព្រឹត្តទៅ គណៈកម្មការសុរិយោដីលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ឧសភា ២០០២ នឹងអនុក្រឹត្យចុះថ្ងៃទី ២០ ខែមេសា ឆ្នាំ២០០៦ស្តីពីការកែប្រែមាត្រា៥ និង

មាត្រា២៨ នៃអនុក្រឹត្យលេខ ៤៧ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈកម្មការសុរិយោដី

- អនុក្រឹត្យស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់អគ្គលេខាធិការដ្ឋាននៃអាជ្ញាធរជាតិដោះស្រាយទំនាស់ដីធ្លី លេខ ៦៥អនក្រ/បក ចុះថ្ងៃទី ១៦ កក្កដា ២០០៦

➢ **ប្រកាស**

- ប្រកាសអន្តរក្រសួងស្តីពី ការកំណត់ភារកិច្ចរបស់តុលាការ និងគណៈកម្មការសុរិយោដីពាក់ព័ន្ធនឹងរឿង វិវាទដីធ្លី លេខ ០២ ប្រក ០៣ ចុះថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០០៣
- ប្រកាសស្តីពីគោលការណ៍ណែនាំ និង នីតិវិធីរបស់គណៈកម្មការសុរិយោដី, លេខ ១១២ជនស/ប្រក,២១ សីហា ២០០២

➢ **សៀវភៅ និងឯកសារផ្សេងៗ**

- សៀវភៅ "ដំណោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការប្រទេសកម្ពុជា ទស្សនៈទានសំខាន់ៗ"រៀបរៀងដោយមេធាវី ស៊្រីន មើល អូស្ទើរមីក្លឺរ៍ បោះ ពុម្ពនៅ ខែ មករា ឆ្នាំ២០១០
- ផ្លូវបត់?សិទ្ធិដីធ្លីសិទ្ធិលំនៅដ្ឋាននិងសិទ្ធិធនធានធម្មជាតិនៅកម្ពុជា,សមាគមអាដហុក (ខែកុម្ភៈ២០១៣)
- របាយការណ៍ស្តីពីសិទ្ធិដីធ្លី និងសិទ្ធិលំនៅដ្ឋាន២០១១របស់អង្គការអាដហុក (ខែមីនា ឆ្នាំ២០១២)
- ការវិភាគផ្អែកលើសិទ្ធិមនុស្សអំពីសម្បទានដីសេដ្ឋកិច្ចនិងសម្បទានគោលដៅដទៃទៀតនៅព្រះរាជាណាចក្រកម្ពុជា ថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០១២
- កិច្ចសន្យារវាងរដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជាមួយក្រុមហ៊ុនSOPHEAK NIKA ចុះថ្ងៃទី៨ ខែសីហា ឆ្នាំ ២០០៥
- ការវិភាគស្ថិតិស្តីពីវិវាទដីធ្លីនៅកម្ពុជា (ភ្នំពេញ, កម្ពុជា ខែមិថុនា ឆ្នាំ ២០១៦)
- របាយការណ៍ដីសម្បទានគោលដៅសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជាទស្សនៈវិស័យខាងសិទ្ធិមនុស្ស ឆ្នាំ២០០៤
- របាយការណ៍វាយតម្លៃ ស្ថានភាពនិរាករណ៍សម្បទានដីសេដ្ឋកិច្ច៖ករណីសិក្សាពីខេត្តភាគឧត្តរនៃប្រទេសកម្ពុជា
- របាយការណ៍សម្បទានសេដ្ឋកិច្ចនៅកម្ពុជា ទស្សនៈវិស័យខាងសិទ្ធិមនុស្សចុះខែវិច្ឆកា ឆ្នាំ២០០៤

➢ **វេបសាយ និងគេទំព័រ**

- https://opendevelopmentcambodia.net/km/topics/concessions/ ចូលមើលថ្ងៃទី៨ ខែមេសា ឆ្នាំ២០២៤
- គេហទំព័រក្រសួងកសិកម្ម: www.maff.gov.kh/elc, ២០១៥

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ

**ឧបសម្ព័ន្ធទី១៖** អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច, លេខ១៤៦អនក្រ/បក, ចុះថ្ងៃទី ២៧ ខែធ្នូ ឆ្នាំ២០០៥

**ឧបសម្ព័ន្ធទី២៖** អនុក្រឹត្យស្តីពីការកែសំរួល អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច,លេខ១៣១អនក្រ/បក, ចុះថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០០៨

**ឧបសម្ព័ន្ធទី៣៖** អនុក្រឹត្យស្តីពីកិច្ចដំណើរការវាយតំលៃផលប៉ះពាល់បរិស្ថានលេខ, ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩

# ឧបសម្ព័ន្ធទី១

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ១៤៦ អនក្រ.បក

# អនុក្រឹត្យ

## ស្តីពី

## សម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០១/នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខនស/រកម/០១៩៦ ចុះថ្ងៃទី ២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបេតិកភណ្ឌវប្បធម៌
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី១៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣០១/០៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល

- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី ៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លី ដែលមានលក្ខណៈដាច់ដោយដុំ
- បានឃើញអនុក្រឹត្យលេខ ១៩ អនក្រ.បក ចុះថ្ងៃទី ១៩ ខែមីនា ឆ្នាំ២០០៣ ស្តីពីសម្បទានដីសង្គមកិច្ច
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី ០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធី ការបង្កើតការចាត់ថ្នាក់ និងការចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី ១៦ ខែ ធ្នូ ឆ្នាំ ២០០៥ ។

## សម្រេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់លក្ខណៈវិនិច្ឆ័យ នីតិវិធី យន្តការ និងការរៀបចំស្ថាប័ន សម្រាប់ការផ្តួចផ្តើម និងការផ្តល់សម្បទានដីសេដ្ឋកិច្ច សម្រាប់ការតាមដានត្រួតពិនិត្យការអនុវត្តកិច្ចសន្យា និងសម្រាប់ការត្រួតពិនិត្យឡើងវិញលើសម្បទានដីសេដ្ឋកិច្ចដែលបានចុះកិច្ចសន្យាមុនពេលដែលអនុក្រឹត្យនេះចូលជាធរមាន ស្របតាមការកំណត់នៃច្បាប់ភូមិបាលឆ្នាំ ២០០១។

**មាត្រា ២ .-**

ពាក្យទាំងឡាយខាងក្រោមនេះ មានន័យដូចតទៅ÷

- សម្បទានដីសេដ្ឋកិច្ច សំដៅដល់យន្តការសម្រាប់ផ្តល់ដីឯកជនរបស់រដ្ឋ តាមរយៈកិច្ចសន្យាសម្បទានមួយជាក់លាក់ទៅឱ្យសម្បទានិក ដើម្បីប្រើប្រាស់សម្រាប់ធ្វើអាជីវកម្មកសិកម្ម និងកសិ-ឧស្សាហកម្ម
- ការធ្វើអាជីវកម្មកសិ-ឧស្សាហកម្ម សំដៅដល់
    - ការដាំដំណាំស្បៀង ឬ ដំណាំឧស្សាហកម្ម រាប់ទាំងការដាំដើមឈើជាចំការឈើ
    - ការចិញ្ចឹមសត្វ និងវារីវប្បកម្ម
    - ការងារសាងសង់ ដូចជារោងសិប្បកម្ម ឬរោងចក្រ និងការបំពាក់បរិក្ខារនានាសម្រាប់កែច្នៃ

វត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ឬ

• សកម្មភាពរួមគ្នានៃសកម្មភាពមួយចំនួន ឬទាំងអស់ដែលបានរៀបរាប់ខាងលើ

- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សំដៅដល់អាជ្ញាធរដែលមានសិទ្ធិអំណាចតាមផ្លូវច្បាប់ក្នុងការចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ចក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដោយអនុវត្តសិទ្ធិនោះតាមការផ្តល់សិទ្ធិប្រទានពីនាយករដ្ឋមន្ត្រី និងបំពេញភារកិច្ចស្របតាមការចែងក្នុងអនុក្រឹត្យនេះ
- ស្ថាប័នដាក់បញ្ញត្តិ សំដៅដល់អាជ្ញាធរមានអំណាចតាមផ្លូវច្បាប់ក្នុងការចេញ និងដាក់ឱ្យអនុវត្តនូវវិធាន និងបទប្បញ្ញត្តិ ដើម្បីគ្រប់គ្រងលើសកម្មភាព ឬបរិក្ខារដែលជាកម្មវត្ថុនៃកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- លេខាធិការដ្ឋានបច្ចេកទេស សំដៅដល់លេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច ។

**មាត្រា ៣ .-**

សម្បទានដីសេដ្ឋកិច្ចអាចត្រូវបានផ្តល់ឱ្យ ដើម្បីសម្រេចគោលបំណងដូចខាងក្រោម ÷

- អភិវឌ្ឍសកម្មភាពកសិកម្មប្រពលវប្បកម្ម និងកសិ-ឧស្សាហកម្ម ដែលតម្រូវឱ្យមានការវិនិយោគដើមទុនដំបូងក្នុងអត្រាខ្ពស់ និងកម្រិតសមស្រប
- សម្រេចបាននូវការព្រមព្រៀងមួយចំនួនជាក់លាក់ពីអ្នកវិនិយោគ សម្រាប់ការអភិវឌ្ឍដីក្នុងលក្ខណៈសមស្រប និងប្រកបដោយចីរភាព ដោយផ្អែកលើផែនការប្រើប្រាស់ដីនៃតំបន់នោះ
- បង្កើតភាពមានការងារធ្វើនៅជនបទ ក្នុងក្របខ័ណ្ឌនៃការធ្វើប្រពលវប្បកម្ម និងការធ្វើឱ្យមានកាលានុវត្តភាពនៃការរកស៊ីចិញ្ចឹមជីវិតមានលក្ខណៈសម្បូរណ៍បែប និងក្នុងក្របខ័ណ្ឌនៃការគ្រប់គ្រងធនធានធម្មជាតិតាមប្រព័ន្ធអេកូឡូស៊ីសមស្រប
- លើកទឹកចិត្តរាល់ការវិនិយោគក្នុងគម្រោងសម្បទានដីសេដ្ឋកិច្ច និង
- បង្កើតចំណូលរដ្ឋ ឬចំណូលខេត្តក្រុង ឃុំសង្កាត់ តាមរយៈការប្រមូលថ្លៃប្រើប្រាស់ដី ពន្ធ និងកម្រៃលើសេវាពាក់ព័ន្ធ ។

## ជំពូកទី ២

## លក្ខខណ្ឌនានាសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច

**មាត្រា ៤ .-**

សម្បទានដីសេដ្ឋកិច្ច អាចត្រូវបានផ្តល់ឱ្យចំពោះតែដីដែលមានលក្ខណវិនិច្ឆ័យទាំង ៥ ដូចខាងក្រោម ÷

១. ដីដែលត្រូវបានចុះបញ្ជី និងធ្វើចំណាត់ថ្នាក់ ថាជាដីឯកជនរបស់រដ្ឋ ស្របតាមអនុក្រឹត្យស្តីពីការគ្រប់គ្រងដីរដ្ឋ និងអនុក្រឹត្យ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី ឬអនុក្រឹត្យស្តីពីការចុះបញ្ជីដីធ្លីមានលក្ខណៈដាច់ដោយដុំ ។

២. ដីដែលមានផែនការប្រើប្រាស់ដី អនុម័តដោយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ហើយការប្រើប្រាស់មានលក្ខណៈស្របទៅតាមផែនការនោះ ។

៣. ដីដែលបានធ្វើការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមចំពោះការប្រើប្រាស់ និងការអភិវឌ្ឍដីសម្រាប់គម្រោងសម្បទាន ។

៤. ដីដែលមានដំណោះស្រាយចំពោះបញ្ហាតាំងទីលំនៅថ្មីស្របតាមក្របខ័ណ្ឌគតិយុត្ត និងនីតិវិធីជាធរមាន ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធានាថា មិនមានការបង្ខំឱ្យធ្វើការតាំងទីលំនៅថ្មីដោយគ្មានការស្ម័គ្រចិត្តពីអ្នកកាន់កាប់ដីស្របច្បាប់ និងត្រូវធានាចំពោះការគោរពសិទ្ធិមានច្រកចេញចូលទៅកាន់ដីឯកជន ។

៥. ដីដែលមានការពិគ្រោះយោបល់ជាសាធារណៈអំពីគម្រោង ឬ សំណើសម្បទានដីសេដ្ឋកិច្ចជាមួយអាជ្ញាធរដែនដី និងប្រជាពលរដ្ឋដែលនៅក្នុងតំបន់ ។

**មាត្រា ៥ .-**

ការវាយតម្លៃសំណើសម្បទានដីសេដ្ឋកិច្ច ត្រូវផ្អែកលើលក្ខណៈវិនិច្ឆ័យដូចខាងក្រោម ÷

- ការបង្កើនផលិតផលកសិកម្ម និងកសិ-ឧស្សាហកម្ម ដោយប្រើប្រាស់បច្ចេកទេសទំនើប
- ការបង្កើតឱ្យមានការងារធ្វើកាន់តែច្រើន
- ការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិប្រកបដោយចីរភាព
- ការចៀសវាង ឬការកាត់បន្ថយឱ្យនៅតិចបំផុតនូវហេតុប៉ះពាល់អវិជ្ជមានសង្គម
- ការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន
- ការកែច្នៃវត្ថុធាតុដើម ជាកសិផលដែលត្រូវកំណត់នៅក្នុងកិច្ចសន្យាសម្បទាន ។

## ជំពូកទី ៣
## នីតិវិធីសម្រាប់ផ្តួចផ្តើម ការស្នើសុំ និងការផ្តល់សម្បទានដីសេដ្ឋកិច្ច

**មាត្រា ៦ .-**

ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ច មានពីររូបភាពគឺ ÷

១. សំណើមានការអំពាវនាវ ដែលអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាជាអ្នកលើកគម្រោង ដើម្បីអំពាវនាវឱ្យអ្នកវិនិយោគដាក់សំណើ ។

២. សំណើមិនមានការអំពាវនាវ ដែលអ្នកវិនិយោគជាអ្នកលើកគម្រោងស្នើទៅរដ្ឋ ដើម្បីសុំការអនុញ្ញាត ។

### ផ្នែកទី ១
### ការផ្តួចផ្តើមសម្បទានដីសេដ្ឋកិច្ចតាមរយៈការអំពាវនាវឱ្យដាក់សំណើ

**មាត្រា ៧ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ជាអ្នកផ្តួចផ្តើមលើកគម្រោងសម្បទានដីសេដ្ឋកិច្ច តាមជំហានដូចតទៅ÷

១. រៀបចំឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច តាមទម្រង់ដែលត្រូវបង្កើតឡើងដោយ

លេខាធិការដ្ឋានបច្ចេកទេស ហើយដែលត្រូវមានបញ្ចូលព័ត៌មានដូចចែងក្នុងមាត្រា ៨ នៃអនុក្រឹត្យនេះ ។

២. បញ្ជូនឯកសារដំបូងទៅលេខាធិការដ្ឋានបច្ចេកទេស ដើម្បីធ្វើការពិនិត្យសិក្សា និងផ្តល់អនុសាសន៍បឋម ដោយផ្អែកលើមាត្រា ៣ និងមាត្រា ៥ នៃអនុក្រឹត្យនេះ ។

៣. ពិគ្រោះយោបល់ជាមួយគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង និងជាមួយស្ថាប័នដាក់បញ្ញត្តិលើគម្រោងសម្បទានដីសេដ្ឋកិច្ច ។

៤. រៀបចំឱ្យមានការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គមសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ។

៥. ប្រសិនបើការវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម បង្ហាញនូវហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ ត្រូវរៀបចំឱ្យមានការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គមពេញលេញ ។

៦. រៀបចំឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ចដែលមានបញ្ចូលអនុសាសន៍ទាំងអស់ និងរបាយការណ៍នានាដែលជាលទ្ធផលនៃជំហានរៀបរាប់ខាងលើ ជាមូលដ្ឋានក្នុងការរៀបចំឯកសារ ស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើ ដែលមានការអំពាវនាវ ។

**មាត្រា ៨ .-**

ឯកសារដំបូងសម្រាប់ស្នើគម្រោងសម្បទានដីសេដ្ឋកិច្ច ត្រូវមានបញ្ចូលព័ត៌មានដូចខាងក្រោម ៖

១. ការពណ៌នាអំពីដីដែលស្នើឡើង ដូចជាទីតាំង ទំហំ ប្រភេទ លេខសម្គាល់ក្បាលដីដែលចុះក្នុងសៀវភៅគោលបញ្ជីដីធ្លី និងព័ត៌មានទូទៅអំពីតំបន់ដែលដីនោះស្ថិតនៅ ។

២. ផែនការទូទៅអំពីការប្រើប្រាស់ និងការអភិវឌ្ឍន៍ដីសម្រាប់គម្រោងសម្បទាន ។

៣. សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យសម្បទានិកធ្វើ មុនពេលចាប់ផ្តើមសកម្មភាពលើសម្បទានដីសេដ្ឋកិច្ចនោះ ប្រសិនបើមាន ។

៤. សកម្មភាពចាំបាច់ផ្សេងៗដែលតម្រូវឱ្យអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ឬក្រសួង ស្ថាប័នណាមួយធ្វើ មុនពេលចាប់ផ្តើមអនុវត្តសកម្មភាពសម្បទានដីសេដ្ឋកិច្ច ប្រសិនបើមាន ។

៥. ការធានារបស់រដ្ឋ ឬកាតព្វកិច្ចរបស់រដ្ឋ ប្រសិនបើតម្រូវឱ្យមានសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ។

**មាត្រា ៩ .-**

នៅពេលទទួលបានឯកសារពេញលេញសម្រាប់គម្រោងសម្បទានដីសេដ្ឋកិច្ច ពីអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំឯកសារ ដោយមានការអំពាវនាវឱ្យដាក់សំណើសុំសម្បទានដីសេដ្ឋកិច្ច រួមមាន ៖

- សេចក្តីជូនដំណឹង
- ឯកសារ ស្តីពីលក្ខខណ្ឌ និង
- ពាក្យស្នើសុំ ។

**មាត្រា ១០ .-**

លេខាធិការដ្ឋានបច្ចេកទេសត្រូវផ្សព្វផ្សាយឱ្យបានទូលំទូលាយ នូវសេចក្តីជូនដំណឹងឱ្យដាក់សំណើ និងបញ្ជូនសេចក្តីជូនដំណឹងនេះ ទៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ។

សេចក្តីជូនដំណឹងត្រូវបញ្ជាក់ពីរបៀប ទីកន្លែង និងរយៈពេលសម្រាប់ការដាក់សំណើ ដោយកំណត់នូវកាលបរិច្ឆេទទទួល និងឈប់ទទួលពាក្យ ។ ការដាក់សំណើត្រូវមានរយៈពេលយ៉ាងតិច ៦០ (ហុកសិប) ថ្ងៃ គិតចាប់ពីថ្ងៃជូនដំណឹង ។

**មាត្រា ១១ .-**

ឯកសារ ស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើដែលមានការអំពាវនាវ ត្រូវបញ្ចូលខ្លឹមសារដូចខាងក្រោម ៖

- សេចក្តីពណ៌នា អំពីគម្រោងសម្បទានដីសេដ្ឋកិច្ច និងឯកសារគាំទ្រដែលតម្រូវឱ្យដាក់ភ្ជាប់ជាមួយសំណើ
- លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃផ្នែកបច្ចេកទេស ហិរញ្ញវត្ថុ និងពាណិជ្ជកម្មនៃសំណើ និង
- លក្ខខណ្ឌចាំបាច់មួយចំនួនដែលមិនអនុញ្ញាតឱ្យចរចា ។

**មាត្រា ១២ .-**

ពាក្យស្នើសុំសម្រាប់សំណើមានការអំពាវនាវ ត្រូវមានភ្ជាប់ព័ត៌មានទាំងឡាយដូចខាងក្រោម ៖

- ផែនការអាជីវកម្មដែលលំអិតអំពីផែនការប្រើប្រាស់ដី ផែនការវិនិយោគ ផែនការចំណូលចំណាយសម្រាប់ការអភិវឌ្ឍដី និងប្រភពដើមទុនសម្រាប់គាំទ្រដល់គម្រោងសម្បទាន
- ការពណ៌នា អំពីសេចក្តីត្រូវការកម្លាំងពលកម្ម និងប្រភពផ្គត់ផ្គង់កម្លាំងពលកម្មសម្រាប់គម្រោងសម្បទាន
- ព័ត៌មានអំពីបច្ចេកវិទ្យា ឧបករណ៍ គ្រឿងចក្រ ជី ថ្នាំសម្លាប់សត្វល្អិត ប្រភេទដំណាំអាទិភាព ដែលគ្រោងនឹងប្រើប្រាស់
- ការបង្ហាញ ពីហេតុប៉ះពាល់បរិស្ថាន និងសង្គមនៃសកម្មភាពគម្រោងវិនិយោគរបស់ខ្លួន ព្រមទាំងវិធានការទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមាន
- ការពណ៌នា អំពីការផ្សារភ្ជាប់ និងការគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច ប្រសិនបើមាន
- ការពណ៌នា អំពីការផ្សារភ្ជាប់ទៅនឹងការកែច្នៃវត្ថុធាតុដើម ដែលជាកសិផលក្នុងស្រុក ប្រសិនបើមាន
- ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើជូនរដ្ឋ
- ការបង្ហាញព័ត៌មានអំពីការកាន់កាប់ដីសម្បទានសេដ្ឋកិច្ចដោយម្ចាស់សំណើ ប្រសិនបើមាន ស្របតាមការចែងក្នុងមាត្រា ៥៩ នៃច្បាប់ភូមិបាល និង
- កិច្ចធានាណាមួយដែលអ្នកដាក់សំណើចង់បានពីរដ្ឋ ប្រសិនបើមាន ។

**មាត្រា ១៣ .-**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំការប្រជុំជាសាធារណៈ ដើម្បីបំភ្លឺអំពីចំណុចនានានៃឯកសារអំពាវនាវឱ្យដាក់សំណើ យ៉ាងតិច ៣០ (សាមសិប) ថ្ងៃ មុនកាលបរិច្ឆេទបិទការទទួលសំណើ និងត្រូវកត់ត្រាទុកជាឯកសារសាធារណៈនូវការបំភ្លឺដែលបានធ្វើឡើង ។

**មាត្រា ១៤ .-**

លក្ខណវិនិច្ឆ័យសម្រាប់វាយតម្លៃ និងចាត់ថ្នាក់សំណើមានការអំពាវនាវ ត្រូវបញ្ចូលចំណុចដូចខាងក្រោម÷

- កម្រិតបច្ចេកទេសនៃការប្រើប្រាស់ និងការអភិវឌ្ឍដី រួមទាំងភាពសមស្របរបស់ដី
- ការគោរពតាមស្តង់ដារបរិស្ថានជាតិ និងវិធានការសមស្របសម្រាប់ទប់ស្កាត់ ឬកាត់បន្ថយហេតុប៉ះពាល់អវិជ្ជមានដល់បរិស្ថាន និងសង្គម
- លទ្ធភាពដំណើរការប្រតិបត្តិការនៃសំណើ ដោយផ្អែកជាអាទិ៍លើផែនការផ្គត់ផ្គង់ និងតម្រូវការកម្លាំងពលកម្ម ប្រភពហិរញ្ញវត្ថុ និងយុទ្ធសាស្ត្រទីផ្សារនៃផែនការអាជីវកម្ម
- លទ្ធភាពបង្កើតការងារធ្វើ និងការលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ
- ការកែច្នៃវត្ថុធាតុដើម ឬកសិផលក្នុងស្រុក ដែលត្រូវកំណត់ក្នុងកិច្ចសន្យា
- លទ្ធភាពផ្សារភ្ជាប់ និងគាំទ្រទៅវិញទៅមករវាងសម្បទានដីសេដ្ឋកិច្ច និងសម្បទានដីសង្គមកិច្ច
- ចំនួនទឹកប្រាក់ និងរបៀបបង់ថ្លៃប្រើប្រាស់ដីដែលអ្នកដាក់សំណើស្នើឡើង ។

លក្ខណវិនិច្ឆ័យសម្រាប់ការវាយតម្លៃ និងការចាត់ថ្នាក់សំណើ មិនអាចធ្វើការកែប្រែបានឡើយ ក្រោយពីចុះផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើដែលមានការអំពាវនាវ អនុលោមតាមមាត្រា ១០ នៃអនុក្រឹត្យនេះ ។

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំ និងផ្សព្វផ្សាយអំពីការដាក់ពិន្ទុសម្រាប់ការចាត់ថ្នាក់សំណើនីមួយៗតាមលំដាប់ ដោយផ្អែកលើលក្ខណវិនិច្ឆ័យខាងលើ ។

**មាត្រា ១៥ .-**

សំណើត្រូវដាក់នៅលេខាធិការដ្ឋានបច្ចេកទេស ក្នុងស្រោមសំបុត្របិទជិត និងមានចុះហត្ថលេខា ឬបោះត្រារបស់ម្ចាស់សំណើលើស្នាមបិទមុខសំបុត្រ ។

សំណើដែលបានទទួលក្រោយកាលបរិច្ឆេទបិទការទទួលសំណើ ត្រូវបង្វិលឱ្យម្ចាស់សំណើវិញ ដោយមិនត្រូវបើកស្រោមសំបុត្រឡើយ ។

សំណើទាំងអស់ ឬសំណើតែមួយ(០១)ដែលបានទទួល ត្រូវបើកជាសាធារណៈ តាមកាលបរិច្ឆេទដែលបានកំណត់ក្នុងសេចក្តីអញ្ជើញឱ្យដាក់សំណើមានការអំពាវនាវ ។ ម្ចាស់សំណើម្នាក់ៗមានសិទ្ធិចូលរួមមើលការបើកសំណើ ។

លេខាធិការដ្ឋានបច្ចេកទេស ត្រូវកំណត់សំណើណាដែលមានលក្ខណៈឆ្លើយតប ហើយពិនិត្យ និងលើកអនុសាសន៍លើសំណើនោះ ជូនទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដោយផ្អែកលើលក្ខណវិនិច្ឆ័យ ដែលចែងក្នុងមាត្រា ១៤ នៃអនុក្រឹត្យនេះ និងតាមនីតិវិធីដែលមានក្នុងឯកសារ ស្តីពីលក្ខខណ្ឌសម្រាប់ការដាក់សំណើ ។

**មាត្រា ១៦ .-**

បន្ទាប់ពីការពិចារណាលើអនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវធ្វើការវាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើដែលមានលក្ខណៈឆ្លើយតបទាំងអស់ និងរៀបចំរបាយការណ៍វាយតម្លៃសំណើដែលមានលក្ខណៈឆ្លើយតប ហើយផ្តល់របាយការណ៍វាយតម្លៃនោះមួយច្បាប់ឱ្យម្ចាស់សំណើនីមួយៗ ។

**មាត្រា ១៧ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវបានអនុញ្ញាតឱ្យធ្វើការចរចាលើលក្ខខណ្ឌចាំបាច់មួយចំនួន ដែលបានកំណត់ជាមុនថាមិនអនុញ្ញាតឱ្យចរចា នៅក្នុងឯកសារអំពាវនាវឱ្យដាក់សំណើនោះឡើយ ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវអញ្ជើញម្ចាស់សំណើដែលជាប់លំដាប់ថ្នាក់ខ្ពស់ជាងគេ មកធ្វើការចរចាកិច្ចសន្យាសម្បទាន ។ ប្រសិនបើការចរចាមិនអាចឈានដល់ការសម្រេចបានកិច្ចសន្យាសម្បទាន ដោយមកពីអាជ្ញាធរមិនអាចទទួលយកលក្ខខណ្ឌដែលស្នើឡើងចុងក្រោយដោយម្ចាស់សំណើ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវបញ្ឈប់ការចរចាជាមួយម្ចាស់សំណើ ហើយត្រូវអញ្ជើញអ្នកដាក់សំណើដែលជាប់លំដាប់ថ្នាក់បន្ទាប់ មកធ្វើការចរចាកិច្ចសន្យាជាបន្តបន្ទាប់ ។

ប្រសិនបើការចរចាឈានដល់ការសម្រេចបាននូវសេចក្តីព្រាងកិច្ចសន្យាសម្បទាន អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវឱ្យម្ចាស់សំណើបំពេញលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ២៣ នៃអនុក្រឹត្យនេះ ។

ក្នុងករណីដែលមានសំណើតែមួយ(០១) ឬពីរ(០២) លេខាធិការដ្ឋានបច្ចេកទេសក៏ត្រូវតែអនុវត្តតាមនីតិវិធី ដែលមានចែងក្នុងមាត្រាខាងលើដែរ ។

## ផ្នែកទី ២

## ការផ្តួចផ្តើមគម្រោងសម្បទានដីសេដ្ឋកិច្ចតាមរយៈសំណើមិនមានការអំពាវនាវ

**មាត្រា ១៨ .-**

វិធីសាស្ត្រអាទិភាពសម្រាប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច គឺវិធីសាស្ត្រអំពាវនាវឱ្យដាក់សំណើក្នុងលក្ខណៈប្រកួតប្រជែង ប៉ុន្តែអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាសម្បទាន អាចធ្វើការពិចារណាលើសំណើសម្បទានដីសេដ្ឋកិច្ចដែលមិនមានការអំពាវនាវណាមួយបាន ក្នុងករណីម្ចាស់សំណើសន្យាផ្តល់អត្ថប្រយោជន៍ក្នុងលក្ខណៈពិសេស ដើម្បីសម្រេចនូវគោលបំណងនៃសម្បទានដីសេដ្ឋកិច្ច មានជាអាទិ៍ ÷

- ការនាំមកនូវបច្ចេកវិទ្យាថ្មី
- ការផ្សារភ្ជាប់ជាពិសេសរវាងសម្បទានដីសេដ្ឋកិច្ច ទៅនឹងសម្បទានដីសង្គមកិច្ច
- លទ្ធភាពពិសេសក្នុងការរកទីផ្សារកែច្នៃ ឬទីផ្សារនាំចេញ ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មិនត្រូវទទួលយកមកពិចារណានូវសំណើសម្បទានដីសេដ្ឋកិច្ចមិនមានការអំពាវនាវទេ ប្រសិនបើសំណើនោះទាក់ទងទៅនឹងដី ដែលជាកម្មវត្ថុនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ដែលបានផ្សព្វផ្សាយសេចក្តីជូនដំណឹងឱ្យដាក់សំណើរួចហើយ ។

**មាត្រា ១៩ .-**

លេខាធិការដ្ឋានបច្ចេកទេសត្រូវរៀបចំពាក្យសុំសម្រាប់លើកសំណើមិនមានការអំពាវនាវ ដោយបញ្ចូល

សេចក្តីពណ៌នាសង្ខេប អំពីសាវតាផ្នែកអាជីវកម្ម និងហិរញ្ញវត្ថុរបស់ម្ចាស់សំណើ គោលគំនិត ស្តីពីការវិនិយោគដែលស្នើឡើង ព្រមទាំងព័ត៌មានទាក់ទងទៅនឹងទំហំដី និងទីតាំងដី ។

ម្ចាស់សំណើ អាចដាក់ពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្តក្រុង ឬនៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ។ ប្រសិនបើពាក្យសុំសម្រាប់សំណើមិនមានការអំពាវនាវ ត្រូវបានដាក់នៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬនៅអនុគណៈកម្មការវិនិយោគខេត្តក្រុង ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ឬអនុគណៈកម្មការវិនិយោគខេត្តក្រុង ត្រូវបញ្ជូនសំណើនោះទៅអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ក្នុងរយៈពេល ០៧ ( ប្រាំពីរ ) ថ្ងៃ គិតចាប់ពីថ្ងៃបានទទួលពាក្យសុំ ។

ប្រសិនបើអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា សម្រេចធ្វើការពិចារណាសំណើមិនមានការអំពាវនាវ អាជ្ញាធរត្រូវធ្វើការពិគ្រោះយោបល់ដូចមានចែងក្នុងមាត្រា ៧ នៃអនុក្រឹត្យនេះត្រង់ចំណុចទី ៣ ។ បន្ទាប់មក អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាត្រូវរៀបចំបំពេញលក្ខណវិនិច្ឆ័យសម្រាប់ការជ្រើសរើសដីធ្វើសម្បទាន ដូចមានចែងក្នុងមាត្រា ៤ នៃអនុក្រឹត្យនេះ ហើយស្នើឱ្យម្ចាស់សំណើផ្តល់ជូននូវឯកសារលំអិតនៃសំណើ ។

**មាត្រា ២០ ._**

ឯកសារលំអិតនៃសំណើមិនមានការអំពាវនាវត្រូវបញ្ចូលព័ត៌មានដូចខាងក្រោម ÷

- ព័ត៌មានដូចមានចែងក្នុងមាត្រា ១២ នៃអនុក្រឹត្យនេះ និង
- របាយការណ៍នៃការសិក្សាវាយតម្លៃដំបូងអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ។ ប្រសិនបើការសិក្សាវាយតម្លៃដំបូងបង្ហាញថា អាចមានហេតុប៉ះពាល់អវិជ្ជមានកម្រិតមធ្យម ឬខ្ពស់ សំណើនោះត្រូវបញ្ចូលរបាយការណ៍នៃការវាយតម្លៃពេញលេញអំពីហេតុប៉ះពាល់បរិស្ថាន និងសង្គម ។

**មាត្រា ២១ ._**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ដែលបានទទួលសំណើមិនមានការអំពាវនាវ ត្រូវអនុវត្តតាមបែបបទដូចតទៅ ÷

ក. អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវបញ្ជូនឯកសារលំអិតនៃសំណើមិនមានការអំពាវនាវទៅលេខាធិការដ្ឋានបច្ចេកទេស ឬទៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ដើម្បីពិនិត្យ និងផ្តល់អនុសាសន៍ ។

ខ. លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ត្រូវផ្តល់អនុសាសន៍ជូនអាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ថាគួរ ឬមិនគួរធ្វើការចរចាកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អនុលោមតាមលក្ខខណ្ឌដូចមានចែងក្នុងមាត្រា ៣ ដល់មាត្រា ៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ២២ ._**

ការចរចាចុះកិច្ចសន្យាសម្រាប់គម្រោងសម្បទានមិនមានការអំពាវនាវ ត្រូវធ្វើក្នុងរយៈពេលយ៉ាងច្រើន ២៨

(ម្ភៃប្រាំបី)ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃផ្ដើមការចរចា។ បើការចរចាមិនឈានដល់ការសម្រេចសេចក្ដីព្រាងកិច្ចសន្យាសម្បទានក្នុងរយៈពេលកំណត់នេះទេ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យាអាចបញ្ឈប់ការពិចារណាលើសំណើនោះ។

**មាត្រា ២៣ .-**

មុនចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អ្នកដាក់សំណើត្រូវចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ស្របតាមច្បាប់ស្ដីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម នៃព្រះរាជាណាចក្រកម្ពុជា។

**មាត្រា ២៤ .-**

លេខាធិការដ្ឋានបច្ចេកទេស ត្រូវរៀបចំទម្រង់ស្តង់ដារនៃកិច្ចសន្យាសម្បទាន ដែលត្រូវប្រើសម្រាប់រាល់សម្បទានដីសេដ្ឋកិច្ច ដោយត្រូវពិគ្រោះយោបល់ និងកំណត់ប្រកាសរួមរវាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។

## ជំពូកទី ៤
## ការគ្រប់គ្រង និងការកែប្រែកិច្ចសន្យាសម្បទាន

**មាត្រា ២៥ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវទទួលខុសត្រូវក្នុងការធានាឱ្យមានការអនុវត្តកិច្ចសន្យាសម្បទាន ដោយបង្កើតយន្តការ និងនីតិវិធីសម្រាប់ការត្រួតពិនិត្យតាមដានការអនុវត្តកិច្ចសន្យាសម្បទាន និងរាយការណ៍ជាប្រចាំអំពីការគ្រប់គ្រងកិច្ចសន្យាសម្បទាន ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ហើយផ្ដល់ព័ត៌មានដល់លេខាធិការដ្ឋានបច្ចេកទេស ឬគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ។

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីត្រួតពិនិត្យលើការអនុវត្តកិច្ចសន្យាសម្បទានរបស់សម្បទានិក និងទទួលព័ត៌មានពីសម្បទានិក និងពីក្រសួង ស្ថាប័នពាក់ព័ន្ធ ទាក់ទងនឹងការអនុវត្តកិច្ចសន្យាសម្បទាន។

**មាត្រា ២៦ .-**

មុននឹងធ្វើការកែប្រែកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវធ្វើការពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងភាគីចុះកិច្ចសន្យា ដោយអនុលោមតាមបទប្បញ្ញត្តិ និងច្បាប់ជាធរមាន។

**មាត្រា ២៧ .-**

ការពន្យារ ការព្យួរ ការបញ្ចប់កិច្ចសន្យាសម្បទាន ត្រូវកំណត់ក្នុងកិច្ចសន្យាសម្បទាន។

## ជំពូកទី ៥
## យន្តការរដ្ឋបាល និងការអនុវត្តកិច្ចសន្យាសម្បទាន

**មាត្រា ២៨ .-**

យន្តការសម្បទានដីសេដ្ឋកិច្ច មានដូចខាងក្រោម ÷

- អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា

- លេខាធិការដ្ឋានបច្ចេកទេស
- គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង
- ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ
- ក្រុមប្រឹក្សាឃុំសង្កាត់ ។

**មាត្រា ២៩ .-**

រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគចាប់ពី ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀលឡើង ឬមានទំហំដីសម្បទានចាប់ពី ១.០០០ (មួយពាន់) ហិកតាឡើង ។

អភិបាលខេត្ត ក្រុងមានសិទ្ធិ និងទទួលខុសត្រូវក្នុងការផ្តល់សម្បទានដីសេដ្ឋកិច្ច ដែលមានទុនវិនិយោគក្រោម ១០.០០០.០០០.០០០ (ដប់ពាន់លាន) រៀល និងមានទំហំដីសម្បទានក្រោម ១.០០០ (មួយពាន់) ហិកតា ។

**មាត្រា ៣០ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា មានតួនាទី និងភារកិច្ចដូចខាងក្រោម ÷

- ផ្តួចផ្តើម និងរៀបចំឯកសារគម្រោងសម្បទានដីសេដ្ឋកិច្ចសម្រាប់អំពាវនាវឱ្យមានការដាក់សំណើ ឬអាចពិចារណាសំណើគម្រោងសម្បទានដីសេដ្ឋកិច្ច ដែលមិនមានការអំពាវនាវ
- វាយតម្លៃ និងកំណត់បញ្ជីសង្ខេបតាមលំដាប់ថ្នាក់សំណើ
- ចរចាលក្ខខណ្ឌសម្រាប់កិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- ដាក់ឱ្យអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- រាយការណ៍អំពីការគ្រប់គ្រងលើការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ជូនគណៈរដ្ឋមន្ត្រីជារៀងរាល់ ០៦ (ប្រាំមួយ) ខែម្តង និងតាមការចាំបាច់
- សម្របសម្រួល ប្រមូលព័ត៌មាន និងទិន្នន័យពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងការពារជាតិ ចំពោះ ដីក្នុងតំបន់អភិវឌ្ឍន៍យោធា លើលក្ខខណ្ឌដែលត្រូវដាក់បញ្ចូលក្នុងកិច្ចសន្យាសម្បទាន
- ពិនិត្យយោបល់របស់លេខាធិការដ្ឋានបច្ចេកទេសអំពីសំណើកែប្រែកិច្ចសន្យាសម្បទានណាមួយ និង -
- បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣១ .-**

សមាសភាពនៃលេខាធិការដ្ឋានបច្ចេកទេស មានដូចខាងក្រោម ÷

-តំណាងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ : ប្រធាន

| | |
|---|---|
| -តំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ | សមាជិក |
| -តំណាងក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក |
| -តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| -តំណាងក្រសួងមហាផ្ទៃ | សមាជិក |
| -តំណាងក្រសួងបរិស្ថាន | សមាជិក |
| -តំណាងក្រសួងពាណិជ្ជកម្ម | សមាជិក |
| -សមាជិកក្រុមប្រឹក្សាអ្នកច្បាប់ | សមាជិក |

ប្រធាន និងសមាជិកនៃលេខាធិការដ្ឋានបច្ចេកទេស ត្រូវតែងតាំងដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល ។

មន្ត្រីជំនួយការរបស់លេខាធិការដ្ឋានបច្ចេកទេសត្រូវតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមសំណើរបស់លេខាធិការដ្ឋានបច្ចេកទេស ។

លេខាធិការដ្ឋានបច្ចេកទេស មានទីតាំងនៅក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។

**មាត្រា ៣២ .-**

លេខាធិការដ្ឋានបច្ចេកទេស មានភារកិច្ច ÷

- រៀបចំគម្រោងសម្បទានដីសេដ្ឋកិច្ច
- រៀបចំឯកសារអំពាវនាវឱ្យដាក់សំណើសម្បទានដីសេដ្ឋកិច្ច
- ផ្តល់អនុសាសន៍ចំពោះសំណើសម្បទានដីសេដ្ឋកិច្ចទាំងអស់
- តាមដានការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច
- ផ្តល់អនុសាសន៍អំពីការត្រួតពិនិត្យឡើងវិញនូវសម្បទានដែលមានស្រាប់ និង
- បំពេញភារកិច្ចផ្សេងៗទៀតស្របតាមការចែងក្នុងអនុក្រឹត្យនេះ ។

**មាត្រា ៣៣ .-**

គណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង មានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ២៥ នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។

**មាត្រា ៣៤ .-**

ក្រុមការងារដីរដ្ឋថ្នាក់ស្រុកខណ្ឌ មានតួនាទី និងភារកិច្ចដូចមានចែងក្នុងមាត្រា ២៨ នៃអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី ០៧ ខែតុលា ឆ្នាំ ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ ។

**មាត្រា ៣៥ .-**

អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវរៀបចំការពិគ្រោះយោបល់ជាមួយអាជ្ញាធរដែនដី និងតំណាងប្រជាពលរដ្ឋមូលដ្ឋាន ក្រោយពីទទួលបានឯកសារលំអិតនៃគម្រោងសម្បទានដីសេដ្ឋកិច្ចមានការអំពាវនាវ ឬឯកសារ

លំអិតនៃសំណើមិនមានការអំពាវនាវ ដោយបញ្ជូនឯកសារនោះមួយច្បាប់ទៅឱ្យក្រុមប្រឹក្សាឃុំសង្កាត់ ដែលដីសម្បទានតាំងនៅ ដើម្បីពិនិត្យ និងផ្តល់យោបល់ក្នុងរយៈពេលយ៉ាងច្រើន ២៨ (ម្ភៃប្រាំបី) ថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃដែលក្រុមប្រឹក្សាឃុំសង្កាត់បានទទួលសំណៅឯកសារលំអិតនៃគម្រោងសម្បទានមានការអំពាវនាវ ឬឯកសារលំអិតនៃសំណើមិនមានការអំពាវនាវ ។ អាជ្ញាធរមានសមត្ថកិច្ចចុះកិច្ចសន្យា ត្រូវពិចារណាលើមតិយោបល់របស់ក្រុមប្រឹក្សាឃុំសង្កាត់ពាក់ព័ន្ធ ។ ក្នុងករណីបដិសេធយោបល់ក្រុមប្រឹក្សាឃុំសង្កាត់ ត្រូវផ្តល់ហេតុផលច្បាស់លាស់ ។

## ជំពូកទី ៦
## ការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់

**មាត្រា ៣៦ .-**

ចំពោះសម្បទានដីសេដ្ឋកិច្ចដែលបានផ្តល់ឱ្យមុនអនុក្រឹត្យនេះចូលជាធរមាន ហើយដែលកិច្ចសន្យាសម្បទាននោះនៅមានសុពលភាព ÷

- លេខាធិការដ្ឋានបច្ចេកទេសត្រូវបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្នុងរយៈពេល ៩០(កៅសិប) ថ្ងៃបន្ទាប់ពីមានសេចក្តីសម្រេចតែងតាំង និងត្រូវជូនដំណឹងក្នុងរយៈពេល ៣០ (សាមសិប)ថ្ងៃ ដល់ក្រសួង ស្ថាប័ន អាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច និងក្រុមហ៊ុនសម្បទានទាំងអស់ឱ្យបានទូលំទូលាយ ។
- ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីទាំងឡាយដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ឬសម្បទានិកទាំងអស់ត្រូវទទួលខុសត្រូវផ្តល់ព័ត៌មាន និងឯកសារថតចម្លងដែលពាក់ព័ន្ធ ដល់លេខាធិការដ្ឋានបច្ចេកទេសក្នុងរយៈពេល ០៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹង ឬការផ្សព្វផ្សាយសេចក្តីជូនដំណឹង ដើម្បីចុះក្នុងសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ។

**មាត្រា ៣៧ .-**

ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានដែលមានស្រាប់ ត្រូវអនុវត្តនូវវិធានត្រួតពិនិត្យឡើងវិញ តាមស្ថានភាពនៃករណីនីមួយៗ ដូចខាងក្រោម ÷

- ការអនុវត្តរបស់សម្បទានិក ផ្អែកលើលក្ខខណ្ឌនៃកិច្ចសន្យាជាធរមាន ដោយពិចារណាលើកំរិតនៃការវិនិយោគដែលបានធ្វើរួចហើយ និងដែលគ្រោងធ្វើបន្ត
- ប្រាក់ចំណូល និងថ្លៃប្រើប្រាស់ដីតាមកិច្ចសន្យាសម្បទាន
- ធ្វើការពិគ្រោះយោបល់ជាសាធារណៈ ដើម្បីប្រមូលមតិយោបល់អំពីសកម្មភាពសម្បទានដីសេដ្ឋកិច្ច នៅឃុំសង្កាត់ ដែលដីសម្បទាននោះស្ថិតនៅ
- ប្រសិនបើសម្បទានិកម្នាក់កាន់កាប់ដីសម្បទានសរុបលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ត្រូវស្នើឱ្យសម្បទានិកនោះស្ម័គ្រចិត្តកាត់ដីដែលលើសជូនរដ្ឋវិញ ឬប្រសិនបើសម្បទានិកមិនស្ម័គ្រចិត្តកាត់បន្ថយដីសម្បទាននោះទេ ត្រូវព្យាយាមចរចាលើការកាត់បន្ថយ

- ស្នើឱ្យមានការធ្វើនិយ័តកម្មដីនោះ ដូចមានចែងក្នុងមាត្រា ៤២ នៃអនុក្រឹត្យនេះ
- យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស លើសេចក្តីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ
- ក្នុងរយៈពេល ០៦ (ប្រាំមួយ)ខែ បន្ទាប់ពីការជូនដំណឹង ស្តីពីការបង្កើតសៀវភៅកត់ត្រាសម្បទានដីសេដ្ឋកិច្ច ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវដាក់របាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដោយមានភ្ជាប់យោបល់របស់លេខាធិការដ្ឋានបច្ចេកទេស ទាក់ទងនឹងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលខ្លួនបានចុះកិច្ចសន្យា ហើយបន្ទាប់មកទៀត របាយការណ៍នេះត្រូវធ្វើឡើងទៀងទាត់រៀងរាល់ ០៦ (ប្រាំមួយ)ខែម្តង
- នៅក្នុងអំឡុងពេល និងក្រោយពេលបញ្ចប់ការត្រួតពិនិត្យឡើងវិញ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យា ត្រូវបន្តការតាមដានការអនុវត្តកិច្ចសន្យាដែលខ្លួនបានចុះហត្ថលេខា និងមិនត្រូវលុបចោល ឬមានបញ្ហាឱ្យផ្អាកដំណើរការ ហើយរាយការណ៍អំពីការអនុវត្តកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច លើកលែងតែមានសេចក្តីសម្រេចរបស់គណៈរដ្ឋមន្ត្រីផ្ទុយពីនេះ ។

**មាត្រា ៣៨ .-**

នីតិវិធីសម្រាប់ការកាត់បន្ថយទំហំដីសម្បទានសេដ្ឋកិច្ចដែលមានស្រាប់ ដោយស្ម័គ្រចិត្ត ឬដោយការចរចា ដូចមានចែងក្នុងមាត្រា ៥៩ នៃច្បាប់ភូមិបាល ត្រូវអនុវត្តដូចតទៅ ÷

- ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដី ដែលបានចុះកិច្ចសន្យាសម្បទានដីសេដ្ឋកិច្ច ត្រូវស្នើឱ្យសម្បទានិកស្ម័គ្រចិត្តជ្រើសរើសចំណែកណាមួយនៃដីសម្បទានបង្វិលជូនរដ្ឋវិញ ស្របតាមមាត្រា ៤០ នៃអនុក្រឹត្យនេះ
- ប្រសិនបើសម្បទានិកមិនមានឆន្ទៈស្ម័គ្រចិត្តកាត់បន្ថយទំហំដីសម្បទាននោះទេ ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវអញ្ជើញសម្បទានិកមកចរចា អំពីផែនការប្រើប្រាស់ដីសម្បទាន ដោយមានជំនួយពីលេខាធិការដ្ឋានបច្ចេកទេស
- ប្រសិនបើការចរចាមិនសម្រេចបានជោគជ័យនៅក្នុងអំឡុងពេល ០៦ (ប្រាំមួយ)ខែ គិតចាប់ពីថ្ងៃផ្តើមការចរចា ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទានត្រូវរាយការណ៍ ជូនទៅគណៈរដ្ឋមន្ត្រីតាមរយៈលេខាធិការដ្ឋានបច្ចេកទេស
- ប្រសិនបើសម្បទានិកខកខានមិនបានចូលមកចរចាក្នុងរយៈពេល ៤៥ (សែសិបប្រាំ) ថ្ងៃ គិតចាប់ពីកាលបរិច្ឆេទដែលលិខិតអញ្ជើញឱ្យមកចរចាត្រូវបានបញ្ជូនដល់អាស័យដ្ឋាន ឬដល់ដៃសម្បទានិក ក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវរាយការណ៍ជូនគណៈរដ្ឋមន្ត្រី ដើម្បីមានវិធានការ ។

**មាត្រា ៣៩ .-**

គណៈរដ្ឋមន្ត្រី មានសិទ្ធិលើកលែងការកាត់បន្ថយការកាន់កាប់សម្បទានដីសេដ្ឋកិច្ច ដែលមានទំហំសរុបលើសពី ១០.០០០ (មួយម៉ឺន) ហិកតា ក្នុងករណីដូចខាងក្រោម ÷

- ដីសម្បទាននោះត្រូវបានផ្តល់ឱ្យមុនពេលដែលច្បាប់ភូមិបាលឆ្នាំ ២០០១ ចូលជាធរមាន

-ការកាត់បន្ថយដីសម្បទាននោះ នាំឱ្យខូចប្រយោជន៍អាជីវកម្មដែលកំពុងមានដំណើរការនៅពេលដែលច្បាប់ភូមិបាលចូលជាធរមាន។ ការកាប់ឆ្ការដើមឈើ ឬការដុតព្រៃសំអាតដី មិនត្រូវបានចាត់ទុកជាអាជីវកម្មកំពុងដំណើរការ ឬជាការបំពេញតាមលក្ខខណ្ឌនៃការអភិវឌ្ឍដីដែលចែងក្នុងកិច្ចសន្យាឡើយ ។

**មាត្រា ៤០ .-**

យោបល់របស់លេខាធិការដ្ឋានបច្ចេកទេសលើសេចក្ដីព្រាងរបាយការណ៍ត្រួតពិនិត្យឡើងវិញ លើសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់នីមួយៗ ដែលផ្ដល់ជូនទៅក្រសួង ស្ថាប័ន ឬអាជ្ញាធរដែនដីដែលបានចុះកិច្ចសន្យាសម្បទាន ត្រូវមានបញ្ជាក់សេចក្ដី ដូចខាងក្រោម ៖

- កិច្ចសន្យានោះកំពុងដំណើរការដោយពេញលេញ
- កិច្ចសន្យានោះគួរមានការកែប្រែលើចំណុចជាក់លាក់ ដោយបញ្ជាក់អំពីកិច្ចការដែលត្រូវបំពេញដោយភាគីនៃកិច្ចសន្យា ដើម្បីទទួលយកបានទាំងសង្ខាង
- គួរលុបចោលកិច្ចសន្យានោះ ដោយមូលហេតុសម្បទានិកបានបំពានលើកិច្ចសន្យា
- ចំពោះដីសម្បទានលើសពី ១០.០០០ (មួយម៉ឺន)ហិកតា ត្រូវបញ្ជាក់អំពីការស្ម័គ្រចិត្តកាត់បន្ថយទំហំដីដោយសម្បទានិក ឬត្រូវធ្វើការចរចាដើម្បីកាត់បន្ថយ ឬហេតុផលចាំបាច់សម្រាប់ការលើកលែងការកាត់បន្ថយដីសម្បទាន ។ ការជ្រើសរើសដីសម្រាប់កាត់បន្ថយ ត្រូវបញ្ចូលផ្នែកដែលមានទំនាស់ ផ្នែកដែលមិនទាន់បានកាប់ឆ្ការ ផ្នែកដែលមិនទាន់បានអភិវឌ្ឍ និងផ្នែកដែលជាដីសាធារណៈរបស់រដ្ឋ ។

**មាត្រា ៤១ .-**

របាយការណ៍ត្រួតពិនិត្យ អនុសាសន៍របស់លេខាធិការដ្ឋានបច្ចេកទេស និងលទ្ធផលចុងក្រោយនៃការត្រួតពិនិត្យឡើងវិញលើសម្បទាននីមួយៗ ត្រូវរក្សាទុកជាឯកសារសាធារណៈ នៅលេខាធិការដ្ឋានបច្ចេកទេស និងនៅគណៈកម្មាធិការគ្រប់គ្រងដីរដ្ឋថ្នាក់ខេត្តក្រុង ។

**មាត្រា ៤២ .-**

ក្នុងការត្រួតពិនិត្យឡើងវិញនូវសម្បទានដីសេដ្ឋកិច្ចដែលមានស្រាប់ ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ត្រូវធ្វើវិនិយ័តកម្មដីក្នុងតំបន់ដីសម្បទាន ដែលជាកម្មវត្ថុនៃការត្រួតពិនិត្យឡើងវិញ។ ការធ្វើវិនិយ័តកម្មដីមានរាប់បញ្ចូលការកែតម្រូវក្បាលដី ការវិនិច្ឆ័យសិទ្ធិលើដីធ្លីរបស់អ្នកកាន់កាប់ក្បាលដីក្នុងតំបន់ត្រួតពិនិត្យឡើងវិញ និងការចុះបញ្ជីក្បាលដីតាមនីតិវិធីជាធរមាន។

## ជំពូកទី ៧

## ប្រភពធនធាន

**មាត្រា ៤៣ .-**

ថវិកាសម្រាប់ប្រតិបត្តិការរបស់លេខាធិការដ្ឋានបច្ចេកទេស ត្រូវស្ថិតក្នុងកញ្ចប់ថវិការបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ។ ស្របតាមប្រព័ន្ធថវិកាឯកភាព ធនធាន និងថវិការបស់លេខាធិការដ្ឋានបច្ចេកទេសបានមកពីថវិកាជាតិ និងហិរញ្ញប្បទានដែលបានមកពីប្រភពក្នុងស្រុក ឬក្រៅស្រុក ឬពីអ្នកផ្តល់ជំនួយអន្តរជាតិ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៤៤ .-**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា ៤៥ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្តក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី [illegible] ឆ្នាំ២០០៥

ហ៊ុន សែន

**កន្លែងទទួល :**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការដ្ឋាននៃឧត្តមក្រុមប្រឹក្សាកំណែទម្រង់រដ្ឋ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- គ្រប់ក្រសួង ស្ថាប័នកណ្តាល
- គ្រប់សាលាខេត្ត ក្រុង
- ដូចមាត្រា ៤៥
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី២

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ..១៣១..អនក្រ.បក

# អនុក្រឹត្យ

## ស្តីពីការកែសម្រួល

## អនុក្រឹត្យស្តីពីសម្បទានដីសេដ្ឋកិច្ច

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៤/នស/៩៤ ចុះថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំទឹកដី នគរូបនីយកម្ម និងសំណង់
- បានឃើញព្រះរាជក្រមលេខ ជស/រកម/០២៩៨/០៣ ចុះថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ១៩៩៨ ដែលប្រកាសអោយប្រើច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរបស់ខេត្ត-ក្រុង
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសអោយប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០២/០១៦ ចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ២០០២ ដែលប្រកាសអោយប្រើច្បាប់ស្តីពីព្រៃឈើ
- បានឃើញអនុក្រឹត្យលេខ ៤៦ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីនីតិវិធីនៃការកសាងប្លង់សុរិយោដី និងសៀវភៅគោលបញ្ជីដីធ្លី
- បានឃើញអនុក្រឹត្យលេខ ៤៨ អនក្រ.បក ចុះថ្ងៃទី៣១ ខែឧសភា ឆ្នាំ២០០២ ស្តីពីការចុះបញ្ជីដីធ្លី ដែលមានលក្ខណៈដាច់ដោយដុំ

- បានឃើញអនុក្រឹត្យលេខ ១៤៦ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ស្តីពីសម្បទានដីសេដ្ឋកិច្ច
- បានឃើញអនុក្រឹត្យលេខ ៥៣ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីនីតិវិធីការបង្កើតការចាត់ថ្នាក់ និងការ ចុះបញ្ជិកាសម្បត្តិព្រៃឈើអចិន្ត្រៃយ៍
- បានឃើញអនុក្រឹត្យលេខ ១១៨ អនក្រ.បក ចុះថ្ងៃទី០៧ ខែតុលា ឆ្នាំ២០០៥ ស្តីពីការគ្រប់គ្រងដីរដ្ឋ
- យោងតាមសំណូមពរចាំបាច់ចំពោះមុខ

## សម្រេច

**មាត្រា១:** ត្រូវបានដកចេញនូវរាល់ខ្លឹមសារទាំងឡាយណាដែលពាក់ព័ន្ធនឹងការផ្តល់សិទ្ធិជូនខេត្ត-ក្រុង មានសិទ្ធិសំរេចផ្តល់ដីសម្បទានសេដ្ឋកិច្ច ដែលមានចែងក្នុងអនុក្រឹត្យលេខ១៤៦អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ ។

**មាត្រា២:** រាល់ខ្លឹមសារផ្សេងទៀតនៃអនុក្រឹត្យលេខ១៤៦អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០០៥ នៅមានសុពលភាពដដែល ។

**មាត្រា៣:** រាល់បទប្បញ្ញត្តិទាំងឡាយណា ដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវបានចាត់ទុកជាមោឃៈ ។

**មាត្រា៤:** រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ រដ្ឋមន្ត្រី រដ្ឋលេខាធិការ ប្រធានស្ថាប័ន និងអភិបាលខេត្ត-ក្រុងទាំងអស់ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ កញ្ញា ឆ្នាំ ២០០៨.

បានជំរាបជូន

សម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

អនុប្រធាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា

ចម ប្រសិទ្ធ

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

**កន្លែងទទួល**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា
- ដូចមាត្រា ៤ "ដើម្បីអនុវត្ត"
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធទី៣

# អនុក្រឹត្យ

## ស្តីពី

# កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា
លេខៈ ៧២ អនក្រ.បក

# អនុក្រឹត្យ
## ស្តីពី
## កិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែវិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពី ការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២ / នស / ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ២១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពី ការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស / រកម / ១២៩៦ / ៣៦ ចុះថ្ងៃទី ២៤ ខែ ធ្នូ ឆ្នាំ ១៩៩៦ ដែលបានប្រកាសឱ្យប្រើច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គនាថ្ងៃទី ២៣ ខែ កក្កដា ឆ្នាំ ១៩៩៩ ។

## សំរេច

## ជំពូកទី ១

## បទប្បញ្ញត្តិទូទៅ

**មាត្រា ១ .–**

អនុក្រឹត្យនេះមានគោលបំណង ៖

- កំណត់ការវាយតំលៃហេតុប៉ះពាល់បរិស្ថាន លើរាល់គំរោង និងសកម្មភាពរបស់ឯកជន ឬសាធារណៈ ហើយត្រូវបានពិនិត្យ និងវាយតំលៃដោយ ក្រសួងបរិស្ថានមុន ដាក់ជូនរាជរដ្ឋាភិបាលសំរេច

- កំណត់ប្រភេទ និងទំហំគំរោង សកម្មភាពដែលស្នើឡើងព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុង ដំណើរការទាំងឯកជន ទាំងសាធារណៈ ដែលត្រូវវាយតំលៃហេតុប៉ះពាល់បរិស្ថាន

- បំផុសឱ្យមានការចូលរួមពីសាធារណៈជន ក្នុងកិច្ចដំណើរការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ព្រម ទាំង ទទួលយកមតិ យោបល មកធ្វើការពិចារណា ក្នុងកិច្ចដំណើរការអនុម័តគំរោង ។

**មាត្រា ២ .–**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះគំរោងដែលស្នើឡើង ព្រមទាំងសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ ដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ជាក្រសួង-ស្ថាប័នរដ្ឋ ដែលមានចែងនៅក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ លើកលែងតែគំរោងដែលមានលក្ខណៈពិសេស និងចាំបាច់បន្ទាន់ ដែលសំរេចដោយរាជរដ្ឋាភិបាល ។

## ជំពូកទី ២

## ស្ថាប័នទទួលខុសត្រូវ

**មាត្រា ៣ .–**

ក្រសួងបរិស្ថាន មានភារៈកិច្ច ៖

ក.ពិនិត្យ និងវាយតំលៃលើ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដោយសហការជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ

ខ.តាមដាន ឃ្លាំមើល និងចាត់វិធានការ ឱ្យម្ចាស់គំរោងប្រតិបត្តិតាម ផែនការគ្រប់គ្រងបរិស្ថានក្នុងដំណាក់កាលសាងសង់ ប្រតិបត្តិ និងបញ្ចប់គំរោង ដូចមានចែងក្នុង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តរួច ។

**មាត្រា ៤ .–**

ស្ថាប័ន និងក្រសួង ដែលមានសិទ្ធិអនុម័តលើគំរោង មានភារៈកិច្ច ពិនិត្យ និងសំរេចលើគំរោង ដូចមានចែងក្នុងឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ ដែលក្រសួងបរិស្ថានបានពិនិត្យ និងផ្តល់យោបល់លើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ។

**មាត្រា ៥ .–**

អាជ្ញាធរខេត្ត-ក្រុង ដែលមានសិទ្ធិអនុម័តលើគំរោង ខេត្ត-ក្រុង មានភារៈកិច្ច ÷

- បញ្ជូននូវរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន នៃគំរោងដែលជាបុគ្គលឯកជន ជាក្រុមហ៊ុនឯកជន ជាក្រុមហ៊ុនចំរុះរដ្ឋ ឬជាក្រុមហ៊ុនរដ្ឋ ទៅមន្ទីរបរិស្ថានខេត្ត-ក្រុង
- ពិនិត្យ និងសំរេចលើគំរោង បន្ទាប់ពីបានពិចារណាលើយោបល់របស់មន្ទីរ បរិស្ថានថ្នាក់ខេត្ត-ក្រុង ដែល ក្រសួងបរិស្ថានបានប្រគល់សិទ្ធជូន ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

## ជំពូកទី ៣

## តម្រូវការវាយតំលៃហេតុប៉ះពាល់បរិស្ថាន សំរាប់គំរោងស្នើសុំ

**មាត្រា ៦ .–**

ម្ចាស់គំរោងត្រូវធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ចំពោះគំរោងដែលតម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុងឧបសម្ព័ន្ធ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧ .–**

ម្ចាស់គំរោង ត្រូវដាក់ពាក្យសុំពិនិត្យ របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និង របាយការណ៍សិក្សាបុរេលទ្ធភាពទៅក្រសួងបរិស្ថាន ។

**មាត្រា ៨ .–**

ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ និង របាយការណ៍សិក្សាលទ្ធភាពទៅក្រសួងបរិស្ថាន ចំពោះគំរោងដែលអាចបង្កហេតុប៉ះពាល់បរិស្ថានធ្ងន់ធ្ងរ ដល់ធនធានធម្មជាតិ អេកូស៊ីស្តែម សុខភាព និងសុខមាលភាពសាធារណៈ ។

**មាត្រា ៩ .–**

ម្ចាស់គំរោងត្រូវដាក់ពាក្យសុំពិនិត្យរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដូចមានចែងក្នុង មាត្រា ៧ និងមាត្រា ៨ ទៅមន្ទីរបរិស្ថាន ខេត្ត-ក្រុង ចំពោះ គំរោងថ្នាក់ ខេត្ត-ក្រុង ។

**មាត្រា ១០ .–**

គោលការណ៍ណែនាំ ស្តីពីការធ្វើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និង របាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងបរិស្ថាន ។

**មាត្រា ១១ .–**

ម្ចាស់គំរោងត្រូវបង់ថ្លៃសេវាការងារ សំរាប់ការពិនិត្យលើរបាយការណ៍ វាយតំលៃហេតុប៉ះពាល់ បរិស្ថាន និងការតាមដាន ឃ្លាំមើល ការអនុវត្តន៍គំរោង ។ តំលៃសេវាការងារនេះត្រូវកំណត់ដោយ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តាមសំណើរបស់ក្រសួងបរិស្ថាន ដែលត្រូវបញ្ចូលក្នុងថវិកាជាតិ ។

**មាត្រា ១២ .–**

ម្ចាស់គំរោងត្រូវបង់វិភាគទានចូលក្នុងមូលនិធិទាយជូទានបរិស្ថាន សំរាប់កិច្ចការពារបរិស្ថាន ដូច មានចែងក្នុងមាត្រា ១៩ ជំពូកទី៨ នៃច្បាប់ស្តីពី កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធាន ធម្មជាតិ ។

**មាត្រា ១៣ .–**

ពាក្យសុំត្រូវបំពេញដោយម្ចាស់គំរោង និងត្រូវផ្តល់ជូនដោយក្រសួងបរិស្ថាន ចំពោះគំរោង ថ្នាក់ក្រសួង-ស្ថាប័ន និងត្រូវផ្តល់ជូនដោយមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះគំរោងថ្នាក់ ខេត្ត-ក្រុង ។

## ជំពូកទី ៤
## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតំលៃហេតុប៉ះពាល់បរិស្ថាន
## សំរាប់គំរោងស្នើសុំ

**មាត្រា ១៤ .–**

ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៧ ទៅក្រសួងបរិស្ថាន និង ផ្តល់លិខិតចំលង ទៅស្ថាប័នអនុម័តគំរោង ។

**មាត្រា ១៥ .–**

ក្រសួងបរិស្ថានត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៤ ព្រមទាំងចាត់បញ្ជូន យោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាបុរេលទ្ធភាព និងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ពីម្ចាស់គំរោង ។

**មាត្រា ១៦ .–**

ក្នុងករណីដែលក្រសួងបរិស្ថាន តម្រូវឱ្យមានរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ម្ចាស់គំរោងត្រូវរៀបចំ និងបញ្ជូនរបាយការណ៍ ដូចមានចែងក្នុងមាត្រា ៨ ទៅក្រសួងបរិស្ថាន ជាមួយនឹងការដាក់ពាក្យសុំវិនិយោគទៅស្ថាប័នអនុម័តគំរោង ។

**មាត្រា ១៧ .–**

ក្រសួងបរិស្ថាន ត្រូវពិនិត្យរបាយការណ៍ ដូចមានចែងក្នុងមាត្រា ១៦ ព្រមទាំងចាត់បញ្ជូន យោបល់ និងសំណើទៅម្ចាស់គំរោង និងស្ថាប័នអនុម័តគំរោងក្នុងរយៈពេល ៣០ ថ្ងៃ គិតថ្ងៃធ្វើការ ចាប់ពីថ្ងៃដែលក្រសួងបានទទួលរបាយការណ៍សិក្សាលទ្ធភាព និង របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ពីម្ចាស់គំរោង ។

**មាត្រា ១៨ .–**

ក្នុងករណី ក្រសួងបរិស្ថានខកខានមិនបានបញ្ជូនយោបល់ និងសំណើដូចមានចែងក្នុងមាត្រា ១៥ និងមាត្រា១៧ នោះ ស្ថាប័នអនុម័តគំរោងអាចកំណត់ថា គំរោងនោះត្រូវបានបំពេញតាម តម្រូវការនៃអនុក្រឹត្យនេះ ។

**មាត្រា ១៩ .–**

ក្នុងសមត្ថកិច្ច ជាស្ថាប័នអនុម័តគំរោងផង និងជាម្ចាស់គំរោងផងនោះ ម្ចាស់គំរោងត្រូវមានភារៈកិច្ចអនុវត្តតាមកិច្ចដំណើរការ ដូចមានចែងក្នុងជំពូកទី៣ និងជំពូកទី៤ នៃអនុក្រឹត្យនេះ ។

**មាត្រា ២០ .-**

មុនចាប់ផ្តើមការអនុវត្តគំរោង ម្ចាស់គំរោងត្រូវទទួលយោបល់ឯកភាពពីក្រសួងបរិស្ថានលើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង ឬរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

## ជំពូកទី ៥
## បែបបទនៃកិច្ចដំណើរការ ពិនិត្យ វាយតំលៃហេតុប៉ះពាល់បរិស្ថាន ចំពោះសកម្មភាពមានស្រាប់

**មាត្រា ២១ .-**

ក្នុងរយៈពេលយ៉ាងយូរ ០១ ឆ្នាំ បន្ទាប់ពី អនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកក្រសួងបរិស្ថាន ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការ ដែលបានទទួលការអនុម័តពីថ្នាក់ក្រសួង-ស្ថាប័ន ។

**មាត្រា ២២ .-**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី ៣ និងជំពូកទី៤ នៃអនុក្រឹត្យនេះ ក្នុងករណីដែលក្រសួងបរិស្ថាន បានពិនិត្យឃើញថាសកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការ តម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា ២៣ .-**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃ ដែលក្រសួងបរិស្ថានបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការ នៃអនុក្រឹត្យនេះ ។

**មាត្រា ២៤ .–**

ក្នុងរយៈពេលយ៉ាងយូរ ០២ឆ្នាំ បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំធ្វើរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថានដំបូង និងដាក់ពាក្យសុំពិនិត្យរបាយការណ៍នេះ មកមន្ទីរបរិស្ថានខេត្ត-ក្រុង ចំពោះសកម្មភាពមានស្រាប់ និងកំពុងដំណើរការដែលបានទទួលការអនុម័តពីថ្នាក់ ខេត្ត-ក្រុង ។

**មាត្រា ២៥ .–**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវរៀបចំរបាយការណ៍ វាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ យ៉ាងយូរ ៦ ខែ ទៅតាមតម្រូវការដែលមានចែងក្នុងជំពូកទី ៣ និងជំពូកទី ៤ នៃអនុក្រឹត្យនេះ ក្នុងករណីដែលមន្ទីរបរិស្ថានខេត្ត-ក្រុងពិនិត្យឃើញថា សកម្មភាពដែលមានស្រាប់ និងកំពុងដំណើរការតម្រូវឱ្យមានការវាយតំលៃហេតុប៉ះពាល់បរិស្ថានពេញលេញ ។

**មាត្រា ២៦ .–**

ម្ចាស់កម្មសិទ្ធ ឬម្ចាស់ទទួលខុសត្រូវ ត្រូវអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដែលមានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាននោះ ក្នុងរយៈពេល ៦ ខែ គិតចាប់តាំងពីថ្ងៃដែល មន្ទីរបរិស្ថានខេត្ត-ក្រុងបានចេញសេចក្តីជូនដំណឹងថា របាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន បានបំពេញតាមតម្រូវការនៃអនុក្រឹត្យនេះ ។

## ជំពូកទី៦
## លក្ខខ័ណ្ឌ នៃការអនុម័តគំរោង

**មាត្រា ២៧ .–**

ស្ថាប័នអនុម័តគំរោង ត្រូវណែនាំម្ចាស់គំរោង ឬម្ចាស់កម្មសិទ្ធ ឱ្យអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគំរោង ដូចបានរៀបរាប់ក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានអនុម័តដោយក្រសួងបរិស្ថាន ។

**មាត្រា ២៨ .–**

ក្រសួងបរិស្ថាន ត្រូវសហការជាមួយស្ថាប័នពាក់ព័ន្ធចេញបញ្ជាឱ្យផ្អាកសកម្មភាព ចំពោះម្ចាស់កម្មសិទ្ធ

ឬម្ចាស់កម្មសិទ្ធណា ដែលពុំបានអនុវត្តតាមផែនការគ្រប់គ្រងបរិស្ថាននៃគំរោង ដូចបានចែងក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ដែលបានឯកភាពរួចហើយ ។

## ជំពូកទី ៧

## ទោសប្បញ្ញត្តិ

**មាត្រា ២៩ .–**

ម្ចាស់គំរោង ឬម្ចាស់កម្មសិទ្ធដែលខកខានមិនបានផ្តល់ ឬបកស្រាយខុសនូវពត៌មាន ឬមិនបានអនុវត្តផែនការគ្រប់គ្រងបរិស្ថាន ដូចបានពិពណ៌នានៅក្នុងរបាយការណ៍វាយតំលៃហេតុប៉ះពាល់បរិស្ថាន ឬបំពាននឹងបទប្បញ្ញត្តិណាមួយ នៃអនុក្រឹត្យនេះត្រូវផ្តន្ទាទោស ដូចមានចែងក្នុងមាត្រា ២០/២១/ ២២/២៣ និងមាត្រា ២៥ ជំពូកទី៩ នៃច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ ។

**មាត្រា ៣០ .–**

កំណត់ហេតុ និងការធ្វើបណ្តឹងចំពោះជនទាំងឡាយណា ដែលបានប្រព្រឹត្តផ្ទុយ ឬពុំអនុវត្តតាមមាត្រាណាមួយ នៃអនុក្រឹត្យនេះ គឺជាសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន ។

**មាត្រា ៣១ .–**

មន្ត្រីបរិស្ថានរូបណា ដែលមានការធ្វេសប្រហែស ខ្វះការប្រុងប្រយ័ត្ន ឬមិនគោរពបទបញ្ជា របស់ក្រសួង ឬរួមគំនិតនឹងអ្នកព្រព្រឹត្តបទល្មើស ឬជួយសំរួលក្នុងការប្រព្រឹត្តិបទល្មើសនេះ ត្រូវទទួលការផ្តន្ទាទោស ផ្នែករដ្ឋបាល ឬនឹងត្រូវជាប់បទចោទប្រកាន់ចំពោះមុខតុលាការ ។

## ជំពូកទី ៨

## អវសានប្បញ្ញត្តិ

**មាត្រា ៣២ .–**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ៣៣ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួង និងស្ថាប័នពាក់ព័ន្ធ ត្រូវសហការជាមួយក្រសួងបរិស្ថាន ហើយត្រូវទទួលបន្ទុកអនុវត្ត អនុក្រឹត្យនេះតាមភារៈកិច្ចរៀងៗខ្លួន ។

**មាត្រា ៣៤ .–**

អនុក្រឹត្យនេះចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ភ្នំពេញថ្ងៃទី ១១ ខែ សីហា ឆ្នាំ ១៩៩៩

នាយករដ្ឋមន្ត្រី

សែន

**បានជំរាបជូន**

**សម្តេចនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**ម៉ុក ម៉ារ៉េត**

**ចំលងជូន :**

- ខុទ្ទកាល័យព្រះមហាក្សត្រ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- អគ្គលេខាធិការដ្ឋានរាជរដ្ឋាភិបាល
- ដូចមាត្រា ៣៣
- កាលប្បវត្តិ - ឯកសារ

តារាងឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ៧២.អនក្រ.បក ចុះថ្ងៃទី១១..ខែសីហា ឆ្នាំ១៩៩៩

ចំណាត់ថ្នាក់គំរូចឱ្យធ្វើការវាយតំលៃហេតុប៉ះពាល់បរិស្ថាន

| ល.រ | ប្រភេទអាជីវកម្ម | ទំហំ |
|---|---|---|
| ១ | **វិស័យឧស្សាហកម្ម** | |
| ១.១ | **ផ្នែក ស្បៀង, ម្ហូបអាហារ គ្រឿងភេសជ្ជៈ និង ថ្នាំជក់** | |
| ១.១.១ | មូលដ្ឋានកែច្នៃម្ហូបអាហារ និងគ្រឿងកំប៉ុង | ≥ ៥០០ តោន/ឆ្នាំ |
| ១.១.២ | មូលដ្ឋានផលិតភេសជ្ជៈ - ទឹកផ្លែឈើគ្រប់ប្រភេទ | ≥ ១.៥០០ លីត្រ/ថ្ងៃ |
| ១.១.៣ | មូលដ្ឋានផលិតដំណាប់ផ្លែឈើ | ≥ ៥០០ តោន/ឆ្នាំ |
| ១.១.៤ | មូលដ្ឋានផលិតទឹកក្រូច | គ្រប់ទំហំ |
| ១.១.៥ | មូលដ្ឋានផលិតស្រា | គ្រប់ទំហំ |
| ១.១.៦ | មូលដ្ឋានផលិតស្រាបៀរ - អាល់កុល | គ្រប់ទំហំ |
| ១.១.៧ | មូលដ្ឋានផលិតទឹកស្អាត | ≥ ១០.០០០ នាក់ប្រើប្រាស់ |
| ១.១.៨ | មូលដ្ឋានផលិតបារី | ≥ ១០.០០០ កញ្ចប់/ថ្ងៃ |
| ១.១.៩ | មូលដ្ឋានផលិត កែច្នៃសន្លឹកថ្នាំជក់ | ≥ ៣៥០ តោន/ឆ្នាំ |
| ១.១.១០ | មូលដ្ឋានផលិតស្ករស | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១.១១ | មូលដ្ឋានកិនស្រូវ និងគ្រាប់ធញ្ញជាតិ | ≥ ៣.០០០ តោន/ឆ្នាំ |
| ១.១.១២ | មូលដ្ឋានផលិតទឹកត្រី - ស៊ីអ៊ីវ - សៀង - ម្ទេស - ប៉េងប៉ោះ | ≥ ៥០០.០០០ លីត្រ/ឆ្នាំ |
| ១.២ | **ផ្នែកវាយនភ័ណ្ឌ, សំលៀកបំពាក់, និង ផលិតផលស្បែក** | |
| ១.២.១ | រោងចក្រតម្បាញ - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.២ | រោងចក្រកាត់ដេរ - បោកគក់ - បោះពុម្ព - ជ្រលក់ពណ៌ | គ្រប់ទំហំ |
| ១.២.៣ | រោងចក្រសំលាប់ស្បែក - កែច្នៃស្បែក - ធ្វើការស្បែកគោក្របី | គ្រប់ទំហំ |
| ១.២.៤ | រោងចក្រផលិតអេប៉ុង - កៅស៊ូមូស | គ្រប់ទំហំ |
| ១.៣ | **ផ្នែកផលិតផលពីឈើ** | |
| ១.៣.១ | រោងចក្រក្តារបន្ទះ | ≥ ១០០.០០០ [illegible]/ឆ្នាំ ឈើមូល |

| | | |
|---|---|---|
| ១.៣.២ | មូលដ្ឋានផលិតគ្រឿងសង្ហារិម | ≥ ១.០០០ម៉ែត្រ$^{3}$/ឆ្នាំ ឈើមូល |
| ១.៣.៣ | រោងចក្រអារឈើ | ≥ ៥០.០០០ម៉ែត្រ$^{3}$/ឆ្នាំឈើមូល |
| **១.៤** | **ផ្នែកផលិតក្រដាស** | |
| ១.៤.១ | រោងចក្រផលិតក្រដាស | គ្រប់ទំហំ |
| ១.៤.២ | រោងចក្រផលិតម្សៅក្រដាស និងកែច្នៃក្រដាស | គ្រប់ទំហំ |
| **១.៥** | **ផ្នែកគីមី - ផលិតផលពីកៅស៊ូ និងប្លាស្ទិក** | |
| ១.៥.១ | រោងចក្រប្លាស្ទិក | គ្រប់ទំហំ |
| ១.៥.២ | រោងចក្រកៅស៊ូកង់ និងពោះវៀនកង់គ្រប់ប្រភេទ | ≥ ៥០០ តោន/ឆ្នាំ |
| ១.៥.៣ | រោងចក្រកៅស៊ូក្រែប | ≥ ១.០០០ តោន/ឆ្នាំ |
| ១.៥.៤ | រោងចក្រផលិតអាគុយ និងថ្មពិល | គ្រប់ទំហំ |
| ១.៥.៥ | រោងចក្រគីមី | គ្រប់ទំហំ |
| ១.៥.៦ | រោងចក្រផលិតជីគីមី | ≥ ១០.០០០ តោន/ឆ្នាំ |
| ១.៥.៧ | រោងចក្រផលិតថ្នាំសំលាប់សត្វល្អិត | គ្រប់ទំហំ |
| ១.៥.៨ | រោងចក្រផលិតថ្នាំលាបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៥.៩ | រោងចក្រគីមីប្រេងកាត | គ្រប់ទំហំ |
| ១.៥.១០ | រោងចក្រផលិតម្សៅសាប៊ូ - សាប៊ូដុំ - សាប៊ូទឹក | គ្រប់ទំហំ |
| **១.៦** | **ផ្នែកផលិតផលពីរ៉ែ មិនមែនជាលោហៈ** | |
| ១.៦.១ | រោងចក្រស៊ីម៉ងត៍ | គ្រប់ទំហំ |
| ១.៦.២ | រោងចក្រចំរាញ់ប្រេងកាត | គ្រប់ទំហំ |
| ១.៦.៣ | រោងចក្រផលិតឧស្ម័ន | គ្រប់ទំហំ |
| ១.៦.៤ | សំណង់បង្ហូរប្រេង និងឧស្ម័ន | ≥ ២ គ.ម |
| ១.៦.៥ | កន្លែងស្តុកប្រេងឥន្ធនៈសំរាប់ចែកចាយ | ≥ ១.០០០.០០០ លីត្រ |
| ១.៦.៦ | ស្ថានីយប្រេងឥន្ធនៈ | ≥ ២០.០០០ លីត្រ |
| ១.៦.៧ | ការធ្វើអាជីវកម្មរ៉ែ | គ្រប់ទំហំ |

| | | |
|---|---|---|
| ១.៦.៨ | រោងចក្រផលិតកែវ - ឌបគ្រប់ប្រភេទ | គ្រប់ទំហំ |
| ១.៦.៩ | មូលដ្ឋានផលិតឥដ្ឋក្បឿង | ≥ ១៥០.០០០ ដុំ/ខែ |
| ១.៦.១០ | មូលដ្ឋានផលិតឥដ្ឋក្រាល - ឥដ្ឋការ៉ូ | ≥ ៩០.០០០ ដុំ/ខែ |
| ១.៦.១១ | រោងចក្រផលិតថ្មស្អួយ | គ្រប់ទំហំ |
| ១.៦.១២ | មូលដ្ឋានផលិតគ្រឿងសំណង់បេតុង | ≥ ៩០០ តោន/ខែ |
| ១.៦.១៣ | រោងចក្រផលិតខ្លាញ់គោ - ប្រេងម៉ាស៊ីន | គ្រប់ទំហំ |
| ១.៦.១៤ | ការសិក្សាស្រាវជ្រាវអាជីវកម្មរ៉ែប្រេងកាត (ការខួងសាកល្បង , ការធ្វើឱ្យរញ្ជួយដី ) | គ្រប់ទំហំ |
| **១.៧** | **ផ្នែកឧស្សាហកម្មលោហៈ មូលដ្ឋាន** | |
| ១.៧.១ | រោងចក្រផលិតគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.២ | រោងចក្រតំឡើងគ្រឿងយន្ត | គ្រប់ទំហំ |
| ១.៧.៣ | សហគ្រាសជួសជុលគ្រឿងយន្ត និងនាវា | គ្រប់ទំហំ |
| **១.៨** | **ផ្នែកឧស្សាហកម្មកែច្នៃលោហៈ** | |
| ១.៨.១ | រោងចក្រកែច្នៃលោហៈគ្រប់ប្រភេទ - ដែកគោល - លួសបន្លា - សំណាញ់ | ≥ ៣០០ តោន/ខែ |
| ១.៨.២ | រោងចក្រស្លដែក - ដែកថែប - អាលុយមីនីញ៉ូម | គ្រប់ទំហំ |
| ១.៨.៣ | រោងចក្រស្លលោហៈគ្រប់ប្រភេទ | គ្រប់ទំហំ |
| **១.៩** | **ផ្នែកឧស្សាហកម្មផ្សេងៗ** | |
| ១.៩.១ | មូលដ្ឋានកែច្នៃសំណល់ - ដុតសំណល់ | គ្រប់ទំហំ |
| ១.៩.២ | មូលដ្ឋានសំអាតទឹកសំអុយ | គ្រប់ទំហំ |
| ១.៩.៣ | រោងចក្រអគ្គិសនី | ≥ ៥ MW |
| ១.៩.៤ | រោងចក្រវារីអគ្គិសនី | ≥ ១ MW |
| ១.៩.៥ | រោងចក្រផលិតសំឡី | ≥ ១៥ តោន/ខែ |
| ១.៩.៦ | រោងចក្រផលិតចំណីសត្វ | ≥ ១០.០០០ តោន/ឆ្នាំ |

| | | |
|---|---|---|
| ២ | **វិស័យកសិកម្ម** | |
| ២.១ | ព្រៃសម្បទាន | ≥ ១០.០០០ ហិចតា |
| ២.២ | អាជីវកម្មព្រៃគប់ | ≥ ៥០០ ហិចតា |
| ២.៣ | ផ្ទៃដីដែលមានព្រៃឈើ | ≥ ៥០០ ហ.ត |
| ២.៤ | ផ្ទៃដីដំណាំកសិកម្ម - ឧស្សាហកម្ម | ≥ ១០.០០០ ហ.ត |
| ២.៥ | ផ្ទៃដីលិចទឹក និងដីតំបន់ឆ្នេរ | គ្រប់ទំហំ |
| ២.៦ | ប្រព័ន្ធស្រោចស្រព | ≥ ៥.០០០ ហ.ត |
| ២.៧ | ប្រព័ន្ធដោះទឹក | ≥ ៥.០០០ ហ.ត |
| ២.៨ | ផែនេសាទ | គ្រប់ទំហំ |
| ៣ | **វិស័យទេសចរណ៍** | |
| ៣.១ | តំបន់ទេសចរណ៍ | ≥ ៥០ ហ.ត |
| ៣.២ | ទីលានវាយកូនគោល | ≥ ១៨ រន្ធ |
| ៤ | **ហេដ្ឋារចនាសម្ព័ន្ធ** | |
| ៤.១ | ការអភិវឌ្ឍន៍ទីក្រុង | គ្រប់ទំហំ |
| ៤.២ | តំបន់ឧស្សាហកម្ម | គ្រប់ទំហំ |
| ៤.៣ | សំណង់ស្ពានថ្នល់ | ទ្រទំងន់ ≥ ៣០ តោន |
| ៤.៤ | សំណង់អាគារ | កំពស់ ≥ ១២ ម. ឬ<br>ក្រឡាផ្ទៃ ៨.០០០ $ម^{២}$ |
| ៤.៥ | ភោជនីយដ្ឋាន | ≥ ៥០០ កៅអី |
| ៤.៦ | សំណង់សណ្ឋាគារ | ≥ ៦០ បន្ទប់ |
| ៤.៧ | សំណង់សណ្ឋាគារតំបន់ឆ្នេរ | ≥ ៤០ បន្ទប់ |
| ៤.៨ | សំណង់ផ្លូវជាតិ | ≥ 100 គ.ម |
| ៤.៩ | សំណង់ផ្លូវដែក | គ្រប់ទំហំ |
| ៤.១០ | សំណង់កំពង់ផែ | គ្រប់ទំហំ |

| | | |
|---|---|---|
| ៤.១១ | សំណង់អាកាសយានដ្ឋាន | គ្រប់ទំហំ |
| ៤.១២ | ការបូមភក់ - ល្បប់ | ≥ ៥០.០០០ ម$^{២}$ |
| ៤.១៣ | កន្លែងចាក់សំរាមទីក្រុង | ≥ ប្រជាជន ២០០.០០០នាក់ |